សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៦

រៀបរៀងដោយ ៖

និស្សិតឈ្មោះ **ឌី ម៉េង នាង**

សាស្ត្រាចារ្យណែនាំ

**លោក ជិន វណ្ណារ៉ា**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១២

ឆ្នាំសរសេរសារណា ២០១៦

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រអស់រយៈពេល៤ឆ្នាំកន្លងមកនេះ យើងមានការចាប់អារម្មណ៍យ៉ាងខ្លាំងលើមុខវិជ្ជាដែលទាក់ទងនឹងផ្នែកនីតិវិធីរដ្ឋប្បវេណី ។ ហើយដោយបានសង្កេតឃើញថា ប្រជាពលរដ្ឋមួយចំនួនពុំសូវមានការយល់ដឹងឱ្យបានច្បាស់លាស់អំពីនីតិវិធីនៃការធ្វើបណ្តឹងនៃនីតិវិធីរឿងក្តីរឿងក្តីចំនួនទឹកប្រាក់តិចនេះ ប៉ុន្មានទេ ។ ជាងនេះទៅទៀតឯកសារដែលសរសេររៀបរាប់លម្អិតអំពីនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច នេះឯងក៏ពុំសូវសម្បូរបែបប៉ុន្មាននោះទេ ។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកស្រាវជ្រាវជំនាន់ក្រោយ ក៏ដូចជាតម្រូវការរបស់មិត្តអ្នកអាន ការស្រលាញ់ពេញចិត្តផ្ទាល់ខ្លួន ជាពិសេសដើម្បីទុក្ខជាឯកសារក្រោយពេលយើងបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ យើងក៏សម្រេចចិត្តកំណត់យកប្រធានបទស្តីពី "**នីតិវិធីបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច**" ដើម្បីយកមកធ្វើការសិក្សាស្រាវជ្រាវ និង តាក់តែងជាសារណានេះឡើង ។

យើងពិតជាមានមោទនៈភាពយ៉ាងខ្លាំងចំពោះស្នាដៃនេះ ដោយហេតុថាវាជាការស្រាវជ្រាវមួយដែលថ្មី ជានេះទៅទៀតយើងអាចបង្កើតជាស្នាដៃនេះឡើងខណៈពេលដែលយើងមិនដែលរំពឹងទុកថា អាចរកឯកសារ និងសរសេរគ្រប់តាមចំនួនកំណត់របស់សាកលវិទ្យាល័យឡើយ ព្រោះវាជានីតិវិធីដែលលក្ខណៈកម្រ និងមិនមានការអនុវត្តនៅពេលជាក់ស្តែងនៅឡើយទេ ។ ក្នុងស្នាដៃនេះយើងបានសរសេររៀបរាប់អំពីទ្រឹស្តីដែលមានចែងនៅក្នុងច្បាប់ សៀវភៅរបស់អ្នកនិពន្ធ នានា និងឯកសាផ្សេងៗជាច្រើនទៀត ។យើង មានការសង្ឃឹម និងជឿជាក់យ៉ាងមុតមាំក្នុងចិត្តថា ស្នាដៃនេះពិតជាអាចរួមចំណែកក្នុងការផ្តល់នូវចំណេះដឹងផ្នែកច្បាប់ទៅដល់បងប្អូនប្រជាពលរដ្ឋ មិត្តអ្នកអាន សិស្ស និស្សិត អ្នកស្រាវជ្រាវជំនាន់ក្រោយ ហើយក៏ដើម្បីចូលរួមលើកស្ទួយវិស័យវិស័យយុត្តិធម៌ និងនីតិរដ្ឋនៅកម្ពុជាឱ្យកាន់តែ រីកចម្រើនមួយកម្រិតថែមទៀតដែរ ។

ជាចុងក្រោយនេះ យើងសូមការខន្តីអភ័យទោសទុកជាមុនអំពីសំណាក់ សិស្ស និស្សិត មិត្តអ្នកអាន សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ នូវរាល់កំហុសឆ្គងដែលកើតមានឡើងដោយ អចេតនាត្រង់ប្រកាណាមួយ តាមរយៈការប្រើប្រាស់ពាក្យពេចន៍មិនសមរម្យ ឬមិនត្រឹមត្រូវត្រង់ចំណុចណាមួយនៃស្នាដៃនេះ ។ យើងរីករាយ និងទទួលស្វាគមន៍ ហើយក៏ទន្ទឹងរងចាំនូវការរិះគន់ទាំងឡាយដើម្បីស្ថាបនាឱ្យការស្រាវជ្រាវកាន់តែល្អឡើងមួយកម្រិតថែមទៀត ។

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ សូមសម្តែងការគោរពដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះ **លោកឪពុក និង អ្នកម្តាយ** ដែលបានផ្តល់កំណើត **រួមជាមួយ បងប្រុស បងស្រី** បានជួយចិញ្ចឹមបីបាច់ថែរក្សា និងបានផ្តល់នូវសេចក្តីស្រឡាញ់ មេត្តា ករុណា អប់រំទូន្មានកូនឲ្យមានសេចក្តីព្យាយាម និងចេះតស៊ូរនៅ ក្នុងជីវិត ។ ហើយក៏សូមថ្លែងអំណរគុណចំពោះ អ្នកមានគុណដែលបានធ្វើពលិកម្មគ្រប់ការលំបាកសព្វបែបយ៉ាង ដើម្បីផ្គត់ផ្គង់ដល់ការសិក្សារបស់កូន ដើម្បីឱ្យទទួលបាននូវចំណេះដឹងដ៏ប្រពៃថ្លៃថ្លាសម្រាប់ជាស្ពានចម្លង និងវាជាទ្រព្យមិនអាចកាត់ថ្លៃបាន សម្រាប់ខ្លួនឯង និង គ្រួសារ ក៏ដូចជាសង្គមជាតិទៅថ្ងៃអនាគតផង ។

យើងខ្ញុំសូមថ្លែងអំណរអគុណាយ៉ាងខ្ពង់ខ្ពស់ចំពោះ **ឯកឧត្តម លុយ ចណ្ណា** ជាសាកលវិទ្យាធិការ ព្រមទាំងសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានលះបង់នូវរាល់ពេលវេលា និង កម្លាំងកាយ កម្លាំងចិត្ត ក្នុងការដឹកនាំ បង្ហាត់បង្រៀន ដើម្បីផ្តល់នូវចំណេះដឹងថ្មីៗ និងដំបូន្មានល្អៗ ដល់យើងខ្ញុំទាំងអស់គ្នា ។ តាមរយៈគុណោបការៈរបស់អស់លោក ទើបធ្វើឲ្យយើងខ្ញុំទទួលបាននូវចំណេះ ដឹងល្អៗដែលនាំឱ្យយើងអាចបញ្ចប់ការសិក្សាប្រកដោយភាពជោគជ័យនាពេលនេះ ។

ជាពិសេស យើងខ្ញុំសូមថ្លែងអំណរអគុណចំពោះ **លោក ជិន ចណ្ណារា** ជាសាស្ត្រាចារ្យណែនាំ ដែលលោកជាអ្នកដឹកនាំ រូបខ្ញុំបាទនៅក្នុងការស្រាវជ្រាវ ដោយលោកបានចំណាយពេលវេលាដ៏មានតម្លៃ និងលះបង់អស់ពីកម្លាំងកាយ និងកម្លាំងចិត្ត ដើម្បីជួយណែនាំផ្តល់នូវដំបូន្មាន កែសម្រួល និងតម្រង់ទិសយើងខ្ញុំរហូតដល់សារណានេះទទួលបានជោគជ័យគួរជាទីមោទនៈនាពេលនេះ ។

ជាកិច្ចបញ្ចប់ យើងខ្ញុំជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្តអ្នកអានជួបប្រទះតែសំណាងល្អ ទទួលបាននូវភាពជោគជ័យក្នុងជីវិត និងមានសុខភាពល្អ ជាពិសេសសូមឱ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម**..........១
**ជំពូកទី១ : ប្រវត្តិ និង គោលគំនិត នីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច**
**ផ្នែកទី ១ ៖ ប្រវត្តិនៃនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច**..........៤
កថាខណ្ឌទី ១ ៖ ប្រវត្តិ នៃនីតិវិធីមុនឆ្នាំ២០០៦..........៤
កថាខណ្ឌទី ២ ៖ ការកើតមានជាក្រមនីតិវិធីរដ្ឋប្បវេណី..........៥
**ផ្នែកទី ២ ៖ គោលគំនិត នៃ នីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច**..........៧
កថាខណ្ឌទី ១ ៖ អត្ថន័យ នៃនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច..........៧
កថាខណ្ឌទី ២ ៖ គោលបំណង នៃនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច..........៨
**ជំពូកទី២ : លំហូរ នីតិវិធីនៃរឿងក្តីចំនួនទឹកប្រាក់តិក**
**ផ្នែកទី ១ ៖ ពាក្យបណ្តឹងនៃរឿងក្តីចំនួនទឹកប្រាក់តិច**៩
កថាខណ្ឌទី ១ ៖ ការដាក់ពាក្យបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច..........៩
ក. របៀបដាក់ពាក្យបណ្តឹងដែលធ្វើជាលិខិតលាយល័ក្ខណ៍អក្សរ..........៩
ខ. របៀបដាក់ពាក្យបណ្តឹងដែលធ្វើដោយផ្ទាល់មាត់..........១១
កថាខណ្ឌទី ២ ៖ ល័ក្ខខណ្ឌ នៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច..........១២
១. កម្មវត្ថុនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច..........១២
២. សមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹង..........១៣
៣. តុលាការដែលមានសមត្ថកិច្ច..........១៤
៣.១. តុលាការដែលមានសមត្ថកិច្ចផ្តាច់មុខ..........១៥
៣.១.១. តុលាការដែលមានសមត្ថកិច្ចផ្តាច់មុខតាមភារៈកិច្ច..........១៦
៣.១.២. តុលាការដែលមានសមត្ថកិច្ចផ្តាច់មុខតាមដែនដី..........១៦
៣.២. សមត្ថកិច្ចតុលាការតាមជម្រើស..........១៧
៣.២.១. សមត្ថកិច្ចតុលាការដែលកើតឡើងដោយគ្មានការតវ៉ាពីចុងចម្លើយ..........១៧
៣.២.២. សមត្ថកិច្ចតុលាការដែលជ្រើសដោយតុលាការថ្នាក់លើ..........១៨
កថាខណ្ឌទី ៣ ៖ ការបញ្ជូននូវពាក្យបណ្តឹង..........១៨

១. វិធីបញ្ជូនពាក្យបណ្ដឹង ............ ១៩

១.១. ការបញ្ជូនដោយប្រគល់ ............ ១៩

ក. ការបញ្ជូនដោយជួបប្រទះ ............ ២០

ខ. ការបញ្ជូនដោយបង្គ្រប់កិច្ច ............ ២០

គ. ការបញ្ជូនដោយទុកចោល ............ ២០

១.២. ការបញ្ជូទៅបរទេស ............ ២០

១.៣. ការបញ្ជូនតាមការផ្សាយជាសារធារណ: ............ ២១

ក. ល័ក្ខខណ៍នៃការបញ្ជូនតាមការផ្សាយជាសាធារណ: ............ ២១

ខ. របៀបបញ្ជូនតាមការផ្សាយជាសាធារណ: ............ ២២

គ. អនុភាពនៃការបញ្ជូនតាមការផ្សាយជាសាធារណ: ............ ២២

២. របាយការណ៍នៃការបញ្ជូន ............ ២៣

**ផ្នែកទី ២ ៖ ការជ្រើសរើសនីតិវិធី និង វិនិច្ឆ័យនៃរឿងក្ដីទឹកចំនួនប្រាក់តិច** ............ ២៤

កថាខណ្ឌទី ១ ៖ ការកំណត់នីតិវិធីរឿងក្ដីចំនួនទឹកប្រាក់តិច ............ ២៤

១. ការកំណត់នីតិវិធីដោយដើមចោទ ............ ២៤

២. ការកំណត់នីតិវិធីដោយចុងចម្លើយ ............ ២៥

៣. ការកំណត់នីតិវិធីដោយតុលាការ ............ ២៥

៤. អនុភាពនៃការផ្ទេរទៅនីតិវិធីបណ្ដឹងធម្មតា ............ ២៦

កថាខណ្ឌទី ២ ៖ ការជំនុំជម្រះទៅលើនីតិវិធីរឿក្ដីចំនួនទឹកប្រាក់តិច ............ ២៦

កថាខណ្ឌទី ៣ ៖ លក្ខណ:ពិសេសនៃរឿងក្ដីចំនួនទឹកប្រាក់តិច ............ ២៨

១. ការមិនធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ............ ២៨

២. ការមិនធ្វើនីតិវិធីផ្សះផ្សា ............ ២៩

៣. ការទាញហេតុផលដោយផ្ទាល់មាត់ធ្វើតែមួយថ្ងៃ ............ ២៩

៤. ការហាមឃាត់ចំពោះការធ្វើបណ្ដឹងតប ............ ២៩

៥. ការចំពោះការធ្វើបណ្ដឹងឧបាស្រ័យ ............ ៣០

**ជំពូកទី ៣ ៖ ការបញ្ចប់នីតិវិធី បណ្ដឹងរឿងក្ដីចំនួនទឹកប្រាក់តិច** ............ ៣២

**ផ្នែកទី ១ ៖ របៀបនៃការបញ្ចប់នីតិវិធីបណ្ដឹង** ............ ៣២

កថាខណ្ឌទី ១ ៖ ការបញ្ចប់បណ្ដឹងដោយស្វ័យប្រវត្តិ ............ ៣២

កថាខណ្ឌទី ២ ៖ ការបញ្ចប់នីតិវិធីបណ្ដឹងតាមរយ:តុលាការ ............ ៣៣

កថាខណ្ឌទី ៣ ៖ ការបញ្ចប់នីតិវិធីបណ្ដឹងដោយភាគី....................................................៣៤
១ ៖ ការបញ្ចប់នីតិវិធីបណ្ដឹងដោយការដក់ពាក្យបណ្ដឹង..........................................៣៤
២ ៖ ការបញ្ចប់បណ្ដឹងដោយការលះបង់ការទាមទារ ..................................................៣៦
៣ ៖ ការបញ្ចប់នីតិវិធីបណ្ដឹងដោយការទទួលស្គាល់ការទាមទារ ................................៣៦
៤ ៖ការបញ្ចប់នីតិវិធីបណ្ដឹងតាមរយៈការសះជាតាមផ្លូវបណ្ដឹង ..................................៣៧
**ផ្នែកទី ២ ៖ ការអនុវត្តនូវសេចក្ដីសម្រេចបញ្ចប់បណ្ដឹង** ............................................៣៧
កថាខណ្ឌទី ១ ៖ ការអនុវត្តសេចក្ដីសម្រេចដោយស្ម័គ្រចិត្ត .............................................៣៨
កថាខណ្ឌទី ២ ៖ ការអនុវត្តនូវសេចក្ដីសម្រេចដោយតុលាការអនុវត្ត................................៤០
**សេចក្ដីសន្និដ្ឋាន** .......................................................................................................៤២
**អនុសាសន៍** ..............................................................................................................៤៤
**ឯកសារយោង**
**ឧបសម្ព័ន**

# សេចក្តីផ្តើម

ប្រទេសកម្ពុជា ធ្លាប់បានឆ្លងកាត់សង្គ្រាមអស់រយៈពេលជាច្រើនឆ្នាំកន្លងមកហើយ ប្រព័ន្ធយុត្តិធម៌ក៏ត្រូវបានបំផ្លាញយ៉ាងដំណំ ។ ជាពិសេសនៅរបបកម្ពុជាប្រជាធិបតេយ្យ ប្រព័ន្ធយុត្តិធម៌ត្រូវបានបំផ្លាញទាំងស្រុង ។ ប្រជាពលរដ្ឋត្រូវរងនូវការកាប់សំលាប់ និងការរំលោភបំពានសិទ្ធិសេរីភាពដោយគ្មានការជំនុំជម្រះរកយុត្តិធម៌នោះទេ ជាងនេះទៅទៀតក្នុងរបបនេះគេមិនអនុញ្ញាតឱ្យមាននូវកម្មសិទ្ធិឯកជនឡើយ ។ ក្រោយឆ្នាំ១៩៧៩ ប្រព័ន្ធយុត្តិធម៌ក៏ពុំសូវមានការរីកចម្រើនអ្វីដែរ លុះអំឡុងឆ្នាំ១៩៩៣ មកដល់ពេលបច្ចុប្បន្ននេះយើងសង្កេតឃើញថា វិស័យយុត្តិធម៌របស់ ប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ។ ដោយគិតចាប់តាំងពីឆ្នាំ១៩៩៣ មកប្រព័ន្ធតុលាការមានបែងចែកជាបីថ្នាក់គឺ សាលាដំបូង សាលាឧទ្ធរណ៍ និងតុលាការកំពូល ។

ប្រទេសកម្ពុជាយើងនាពេលបច្ចុប្បន្ននេះ គឺជាប្រទេសកំពុងអភិវឌ្ឍនទៅលើគ្រប់វិស័យ ជាពិសេសវិស័យយុត្តិធម៌នេះតែម្តង ហើយណាមួយប្រជាជនក៏មានការយល់ដឹងនៅមានកំរិតនៅឡើយ ។ ដោយសារវិស័យយុត្តិធម៌ តាមរយៈតុលាការដែលជាអ្នកអនុវត្ត ដោយផ្អែកទៅលើច្បាប់ដែលច្បាប់នោះមានចែងទុកជាមុន ។ ដោយសារនៅប្រទេសកម្ពុជាយើងមានច្បាប់យ៉ាងច្រើនដែលប្រភេទផ្សេងៗគ្នា វាក៏ជាកត្តាមួយ ដែលធ្វើអោយប្រជាជនមានការយល់ដឹងនៅមានកំរិតទៅលើវិស័យច្បាប់ ។

ច្បាប់អាចកើតឡើងតាមរបៀបពី គឺតាមរយៈសេចក្តីព្រាងច្បាប់របស់រដ្ឋសភា និង តាមរយៈសេចក្តីស្នើច្បាប់ដែលធ្វើឡើងដោយរាជរដ្ឋាភិបាល ។ ច្បាប់នេះ គឺមុនដំបូងធ្វើដោយក្រសួងសាមីដែលដែលខ្លួនចង់ឱ្យមានច្បាប់ដើម្បីបំពេញនូវចំណុចដែលខ្វះខាត់ ដែលទាក់ទងនិងមុខងាររបស់ខ្លួន ដោយមានធ្វើកាប្រជុំនៅក្នុងក្រសួងសមីនេះតែម្តង ហើយក្រោយពីប្រជុំនៅក្រសួងសាមីរួចហើយនោះ គឺត្រូវមានការប្រជុំជាអន្តរក្រសួង ដែលមានការចូលរួមរបស់ក្រសួងនានាដែលពាក់ព័ន្ធ និង មានការប្រជុំធំ គឺប្រជុំពេញអង្គ ដែលមានការដឹកនាំដោយគណៈរដ្ឋមន្ត្រី ហើយក្រោយពីប្រជុំពិភាក្សាទៅលើសេចក្តីស្នើរច្បាប់ចប់សព្វហើយនោះ ច្បាប់នោះគឺត្រូវបានដាក់ជូនរដ្ឋសភាពិនិត្យ និងធ្វើការអនុម័ត ។ ក្រោយពីរដ្ឋសភារួចហើយ គឺត្រូវដាក់ជូនព្រឹទ្ធិសភាធ្វើការពិនិត្យជាលើកទីពីរ ហើយក្រោយពីសភាទាំងពីរជាន់បានធ្វើការពិនិត្យ និងអនុម័តចប់រួចរាល់ហើយនោះ គឺច្បាប់នេះត្រូវបានដាក់ជូនព្រះមហាក្សត្រ ដើម្បីឡាយព្រះហស្ថ និងប្រកាសឱ្យប្រើ ។ ហើយច្បាប់ដែលប្រកាសឱ្យប្រើនោះ និងចូលជាធរមានក្នុងរយៈពេល ១០ ថ្ងៃ នៅរាជធានីភ្នំពេញ និងរយៈពេល ២០ ថ្ងៃនៅទូទាំងប្រទេស ។

ទោះបីជាច្បាប់នៅប្រទេសកម្ពុជាមានចំនួនយ៉ាងច្រើនក៏ដោយ ក៏គេអាចធ្វើការបែងចែកវាបានទៅតាមតួនាទីរបស់វាផងដែរ ។ ដោយច្បាប់ ដែលមានតួនាទីសម្រាប់គ្រប់គ្រង់ទៅលើវិស័យសាធារណៈ ឬមួយទំនាក់ទំនង សារធារណៈ គឺគេចាត់វាចូលទៅក្នុង **នីតិសាធារណៈ** រីឯច្បាប់ដែលមានតួនាទីទៅលើវិស័យឯកជន ឬទំនាក់ទំនងឯកជន គឺគេបានចាត់វាចូលទៅក្នុង **នីតិឯកជន**។ ការដែលធ្វើការបែងចែកបែបនេះ វាធ្វើឱ្យមានចម្ងល់ថា ច្បាប់នីតិវិធីវាស្ថិតនៅក្នុង នីតិមួយណាទៅ ?

ច្បាប់នីតិវិធីវាជានីតិចំរុះ ព្រោះវាគ្រាន់តែជាវិធាន ឬជាបែបបទ ឬ របៀបរបប ឬជាគន្លង ដែលសម្រាប់ទុកឱ្យតុលាការជាដាច់ខាត់បើមិនធ្វើការអនុវត្តនោះទេវា និងធ្វើឱ្យនីតិវិធីដែលតុលាការបានធ្វើនោះក្លាយជាមោឃៈភាពជាមិនខាន ។

ចំពោះច្បាប់នីតិវិធីនេះ គឺមានច្បាប់នីតិវិធីខាងនីតិសាធារណៈ គឺ **ច្បាប់នីតិវិធីព្រហ្មទណ្ឌ** និងច្បាប់នីតិវិធីខាង នីតិឯកជន គឺមាន **ច្បាប់នីតិវិធីរដ្ឋប្បវេណី** ដែលជាវិធាន ដែលគ្រប់គ្រងនៅផ្នែកនីតិឯកជននេះ ។ ហើយច្បាប់ ច្បាប់នីតិវិធីរដ្ឋប្បវេណីនេះ វាមានសារៈសំខាន់ណាស់ នៅក្នុងវិស័យនីតីវិធីឯកជននេះ ហើយច្បាប់នីតិវិធីនេះ គឺមិនសូវមានអ្នកណាលើកយក មកសិក្សា ឱ្យមានភាពលំអិតនោះទេ ។ ហើយនៅក្នុងច្បាប់នីតិវិធីរដ្ឋប្បវេណីនេះវាលក្ខណៈពិសេសច្រើន ដោយច្បាប់នីតិវិធីរដ្ឋប្បវេណីបានធ្វើការបែងចែកជា នីតិវិធីនៃការជម្រះក្តីលើកទី១ និងមាន បទបញ្ញត្តិពិសេសស្តីពីរឿងក្តីចំនួនទឹកប្រាក់តិច ដែលនីតិវិធីនេះ មិនទាន់មានអ្នកណាលើកយកមកសិក្សា និងធ្វើការបកស្រាយឱ្យសិស្ស និស្សិត ឬឱ្យប្រជាជនមានការយល់ដឹងអំពីនីតិវិធីបណ្តឹងរឿក្តីចំនួនទឹកប្រាក់តិចនេះឡើយ ។

ហេតុដូច្នេះហើយ ដោយសង្កេតឃើញថាមានបញ្ហាអសកម្មទាំងនេះហើយ ទើបជម្រុញទឹកចិត្តឱ្យយើងខ្ញុំលើកយកប្រធានបទស្តីពី “ **នីតិវិធីបណ្តឹងនៃរឿងក្តីចំនួនទឹកប្រាក់តិច** ” ដើម្បីយកមកធ្វើការពន្យល់ និងធ្វើការស្រាយបំភ្លឺ ។ ពេលដែលយើងធ្វើការលើកយកប្រធានបទស្តីពីនីតិវិធីបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច មកនិយាយនោះនឹងមានចម្ងល់ចោទឡើងថា ៖

- តើអ្វីទៅជានីតិវិធីបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ហើយដើម្បីធ្វើនីតិវិធីបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចនេះគឺធ្វើយ៉ាងដូចម្តេច និងត្រូវមាននីតិវិធីក្នុងការជំនុំជម្រះយ៉ាងដូចម្តេចខ្លះ ?

ដោយសង្កេតឃើញថាប្រជាជនភាគច្រើន ក៏ដូចជាសិស្ស និស្សិតមួយចំនួន ពុំសូវមានការយល់ដឹងអំពីនីតិវិធីនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចនោះទេហេតុនេះហើយទើបបានជាយើងខ្ញុំសម្រេចកំណត់យកប្រធានបទស្តីពី **នីតិវិធីបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច** យកមកធ្វើការ

ស្រាវជ្រាវ ដើម្បីដោះស្រាយចម្ងល់នេះជូនមហាជនក្នុងការសិក្សាស្រាវជ្រាវ ។ ជាងនេះទៅទៀត គឺដើម្បីបង្កើនចំណេះដឹង និងទុក្ខជាឯកសារសម្រាប់សិស្ស និស្សិតជំនាន់ក្រោយៗទៀតធ្វើការសិក្សា និងស្រាវជ្រាវបន្ថែមទៀត ។

ប្រធានបទនេះ គឺមានសារៈសំខាន់ ដើម្បីរួមចំណែកក្នុងការពង្រីកចំណេះដឹងផ្នែកច្បាប់ជូនដល់សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវ ជាពិសេសប្រជាជនកម្ពុជាដែលពុំសូវ ឬពុំមានការយល់ដឹងអំពីនីតិវិធីនៃការធ្វើបណ្តឹង និងនីតិវិធីនៃការជំនុំជម្រះលើរឿងក្តីចំនួនទឹកប្រាក់តិច ។ យើងខ្ញុំជឿជាក់ថាស្នាដៃនេះនឹងអាចចូលរួមចំណែកលើកស្ទួយនីតិរដ្ឋនៅកម្ពុជាឱ្យកាន់តែប្រសើរឡើងមួយកម្រិតថែមទៀត តាមរយៈការចូលរួមចំណែកលើកស្ទួយវឌ្ឍនភាព នៃចំណេះដឹងផ្នែកច្បាប់ដល់ប្រជាជន ។

សារណានេះត្រូវបានធ្វើការបែងចែកជា ៣ ជំពូក ដែល **ជំពូកទី១** និយាយអំពីប្រវត្តិ និងគោលគំនិត ដែលជាសញ្ញាញទូទៅនីតិវិធីបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ។ ចំណែកឯ **ជំពូកទី២** បង្ហាញអំពីលំហូរនីតិវិធីនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ហើយត្រូវបានបែងចែកជា ២ ផ្នែកធំៗ គឺ ផ្នែកទី១ និយាយពីពាក្យបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច និង ផ្នែកទី២ គឺ ការជ្រើសរើសនីតិវិធី និងវិនិច្ឆ័យនៃរឿងក្តីចំនួនទឹកប្រាក់តិច រីឯ **ជំពូកទី៣** និយាយអំពី ការបញ្ចប់នីតិវិធីនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ដែលត្រូវបានបែងចែកជា ២ ផ្នែកគឺ ផ្នែកទី១ ការបញ្ចប់នីតិវិធីបណ្តឹង និងផ្នែកទី២ ការអនុវត្តនូវសេចក្តីសម្រេចបញ្ចប់បណ្តឹង ។

# ជំពូកទី ១ ៖ ប្រវត្តិ និង គោលគំនិត

ជាដំបូង ដើម្បីធ្វើការសិក្សាស្វែងយល់ទៅលើប្រធានបទណាមួយនោះ តួយ៉ាង ដូចជាការសិក្សាទៅលើនីតិវិធី នៃបណ្តឹងលើអង្គសេចក្តីធម្មតា ឬមួយទៅលើនីតិវិធីនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចក៏ដោយ គឺយើងត្រូវធ្វើការសិក្សាទៅលើការកកើតមាននូវនីតិវិធីទាំងនេះ គឺប្រវត្តិ( ផ្នែកទី ១ ) និងយើងត្រូវបង្ហាញថា ហេតុអ្វីបានជាចាំបាច់ត្រូវបង្កើតវា គឺគោលបំណងដែលបង្កើតវា ( ផ្នែកទី ២ ) ។

## ផ្នែកទី ១ ៖ ប្រវត្តិ នៃនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច

ដោយឡែកនៅ ប្រធានបទរបស់យើង គឺយើងសិក្សាទៅនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច នោះយើង ក៏ត្រូវធ្វើការសិក្សាទៅលើប្រវត្តរបស់វា ( កថាខ័ណ្ឌទី ១ ) និងធ្វើការសិក្សាទៅលើគោលបំណងរបស់វាផងដែរ ( កថាខ័ណ្ឌទី ២ ) ដែលនិងបង្ហាញដូចខាងក្រោមនេះ ។

### កថាខ័ណ្ឌទី១ ៖ ប្រវត្តិ នៅ មុនឆ្នាំ ២០០៦

នៅក្នុងប្រទេសកម្ពុជា ច្បាប់គឺត្រូវបានកំណត់ អំពីឋានានុក្រម ហើយយោងទៅតាម មាត្រា ១៥០ ថ្មីនៃរដ្ឋធម្មនុញ គឺបានកំណតថា រដ្ឋធម្មនុញ្ញជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ។ ច្បាប់ និង សេចក្តីសម្រេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនិងរដ្ឋធម្មនុញ្ញជាដាច់ខាត ។ ម្យ៉ាងទៀតបើតាមទ្រឹស្តី សាជីជ្រុងរបស់ កែលសិន គឺបានកំណត់អំពីឋានានុក្រមនៃច្បាប់ដែរមាន:

- រដ្ឋធម្មនុញ្ញ
- សន្ធិសញ្ញាអន្តជាតិ ។ល។
- ច្បាប់ ដែលអនុម័តដោយរដ្ឋសភា
- ព្រះរាជក្រម ព្រះរាជក្រឹត្យ

នៅក្រោមរដ្ឋធម្មនុញ្ញ គឺមានច្បាប់ ហើយច្បាប់នេះទៀតសោត គឺត្រូវបានបែងចែកជា២ ប្រភេទ

ទី១ ច្បាប់សាធារណៈ គឺជាវិធានទាំងឡាយណាដែលសម្រាប់រៀបចំស្ថាប័នរដ្ឋ និងសម្រាប់គ្រប់គ្រងទំនាក់ទំនងក្នុងរដ្ឋឱ្យមានសណ្តាប់ធ្នាប់ និង បុគ្គលិករដ្ឋជាមួយប្រជាពលរដ្ឋ ដូចជា រដ្ឋធម្មនុញ្ញ នីតិ-ព្រហ្មទណ្ឌ ។ និងទី២ គឺច្បាប់នៃនីតិឯជន ដែលវាជាច្បាប់សម្រាប់គ្រប់គ្រងរវាងទំនាក់ទំនងរបស់បុគ្គលឯកជន និងបុគ្គលឯកជន និងដើម្បីការពារផលប្រយោជន៍របស់បុគ្គលឯកជននេះ ផងដែរ ដូចជា នីតិរដ្ឋប្បវេណី នីតិការងារ និងនីតិពាណិជ្ជកម្ម ។

ចំណែកឯ ច្បាប់នីតិវិធីវិញ គឺជាសំណុំវិធានពាក់ពន្ធ័ ជាមួយនិងការជម្រះក្តីគ្រប់ប្រភេទ ( នីតិវិធីរដ្ឋប្បវេណី នីតិវិធីព្រហ្មទណ្ឌ ) នីតិវិធីនេះក៏ត្រូវបានគេចាត់ទុកជានីតិចម្រុះ ឬនីតិរួមផងដែរ ។

នីតិវិធីវាមិនបានចូលរួមក្នុងការកំណត់នូវល័ក្ខខណ្ឌនៃនីតិឯកជន ឬនីតិសាធារណៈ នោះទេ គឺវាគ្រាន់តែជាបទដ្ឋានសម្រាប់ឱ្យស្ថាប័នមានសមត្ថកិច្ច ( តុលាការ ) ជាវិធានសម្រាប់អនុវត្តន៍នៅក្នុងការវិនិច្ឆ័យសេចក្តី តែប៉ុណ្ណោះ ។ ចំពោះនីតិវិធីរដ្ឋប្បវេណី ក៏ជាវិធានសម្រាប់ឱ្យតុលាការ យកទៅអនុវត្តន៍នៅក្នុងការវិច្ឆ័យរឿងក្តីរដ្ឋប្បវេណី ដែលជានីតិឯកជន ។ នៅក្នុងនីតិឯកជននេះប្រទេសកម្ពុជាយើងបានចង់ក្រងជាក្រមនីតិរដ្ឋប្បវេណី ដែលកើតជារូបរាងឡើងនៅក្នុងអំឡុង ឆ្នាំ១៩២០ មកម្ល៉េះ។

ប៉ុន្តែ ចំពោះការសិក្សាទៅលើនីតិវិធីរដ្ឋប្បវេណីវិញ ប្រទេសកម្ពុជាយើងមិនបានគូសបញ្ជាក់ ឬបានបន្សល់ទុក ការចង់ក្រងទៅជា ក្រមនីតិវិធីរដ្ឋប្បវេណី នៅក្នុងអំឡុង ឆ្នាំ១៩២០ ដូចក្រមនីតិរដ្ឋប្បវេណីនោះទេ ។ ណាមួយប្រទេសកម្ពុជាយើង បានឆ្លងកាត់សង្គ្រាមជាង ២ ទសវត្ស និងឆ្លងរបបនៃការគ្រប់គ្រងផ្សេងៗគ្នា នេះវាគឺជាកត្តាមួយ ដ៏ធំដែលនាំឱ្យមានការរាំងស្ទះនៅក្នុងការចង់ក្រង ក្រមនីតិវិធីរដ្ឋប្បវេណីឡើង ។

តែក្រោយមក ក៏មានការលេចឡើងនូវ សញ្ញាណនៃនីតិវិធីរដ្ឋប្បវេណីនៅក្នុងអំឡុង ឆ្នាំ១៩៨៤ ដែរជារបប សាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ដែលមានជាដំបូងនោះ វាមានលក្ខណៈគឺជា សារាចរស្តីពីសេចក្តីណែនាំអំពីនីតិវិធីរដ្ឋប្បវេណី លេខ ០៤ សរច ៨៤ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ១៩៨៤ ។ (ឧបសម្ព័ន្ធ )

## កថាខ័ណ្ឌទី ២៖ ការកើតមានជាក្រមនីតិវិធីរដ្ឋប្បវេណី

ក្រោយពីបានឆ្លងកាត់របបនៃការគ្រប់គ្រង់ជាច្រើន នៅក្នុងអំឡុងពេលជាង ២ទសវត្សនោះ ប្រទេសកម្ពុជា ក៏បានទទួលបានសុខសន្តិភាព ក្នុងឆ្នាំ ១៩៩៣ ។ ហើយក៏ជាឆ្នាំ ដែលប្រទេសកម្ពុជាបានបង្កើតឱ្យមានរបបលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្សសារជាថ្មី គឺការបង្កើតឱ្យមានការបោះជ្រើសរើសតំណាងរាស្ត្រ ( រដ្ឋសភា ) ដើម្បីបង្កើតច្បាប់អនុម័តច្បាប់ រួមជាមួយនឹងសន្ធិសញ្ញា អនុសញ្ញា ផ្សេងៗទៀតនៅមុនពេលដែលដាក់ជូនព្រះមហាក្សត្រឡាយព្រះហត្ថលេខា និង ប្រកាសឱ្យប្រើច្បាប់នោះ ។

ប្រទេសកម្ពុជា ក្រោយពីបានសុខសន្តិភាព ក៏មានទំនាក់ទំនងអន្តរជាតិ ការទូតជាមួយប្រទេសនៅក្នុងតំបន់ និងក្រៅតំបន់ ជាពិសេសជាមួយប្រទេសជប៉ុនតែម្តង ។ ណាមួយប្រទេសកម្ពុជាទើបតែទទួលបាននូវសន្តិភាព ហើយស្ទើរតែគ្រប់វិស័យ ប្រទេសយើង គឺមានភាពទន់ខ្សោយជាពិសេស គឺវិស័យយុត្តិធម៌ ។ ម្យ៉ាងដោយមានកិច្ចសហប្រត្តិការជាមួយប្រទេសជប៉ុនោះ ប្រទេសជប៉ុនក៏បានជួយផ្គត់ផ្គង់ទាំងថវិការ រួមជាមួយបច្ចេកទេសនៅក្នុងការបង្កើតវិធានច្បាប់សម្រាប់គ្រប់គ្រង់នូវរាល់ទំនាក់ទំនងរវាងបុគ្គលឯកជន និងបុគ្គលឯកជន ជាពិសេសសម្រាប់ឱ្យតុលាការយកវិធាននោះទៅដោះស្រាយនូវរាល់ទំនាស់ ដែលកើតឡើងរវាងបុគ្គលឯកជន និងបុគ្គលឯកជននោះ ។

វិស័យច្បាប់ ដែលសម្រាប់គ្រប់គ្រង់ទំនាក់ទំនងរវាងបុគ្គលឯកជន និងបុគ្គលឯកជននេះ គឺហៅថា **ច្បាប់ប្បវេណី** ។

ច្បាប់ប្បវេណីនេះ ដែលទទួលបានជំនួយពីប្រទេសជប៉ុននោះរួមមានៈ

១. ច្បាប់សារធាតុ គឺ ក្រមនីតិរដ្ឋប្បវេណី

២. ច្បាប់នីតិវិធី ហើយច្បាប់នីតិវិធីនេះ គឺមានបីប្រភេទផ្សេងទៀត

- ទីមួយ ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ដែលត្រូវបានរដ្ឋសភាអនុម័ត កាលពីថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១០ នឹង ច្បាប់នេះបានប្រកាសឱ្យប្រើនៅថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០១០ ។
- ទីពីរ ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដែលច្បាប់នេះត្រូវបានរដ្ឋសភាអនុម័ត កាលពី ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ ហើយច្បាប់នេះបានប្រកាសឱ្យប្រើនៅថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០១០ ។
- ទីបី ក្រមនីតិវិធីរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០០៦ ហើយក្រមនេះបានប្រកាសឱ្យប្រើ ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦ ។ ហើយក្រមនេះប្រកាសឱ្យអនុវត្ត នៅរាជធានីភ្នំពេញ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៧ នឹងប្រកាសឱ្យអនុវត្តនៅទូទាំងប្រទេស នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧ ។

ក្រមនីតិវិធីរដ្ឋវេណីនៃព្រះរាជាណាចក្រកម្ពុជា បានលេចឡើងជារូបរាងនៅក្នុង ឆ្នាំ២០០៦ ហើយក្រមនីតិវីធីនេះគឺត្រូវបានធ្វើការបែងចែក ជា ៩គន្ថី និងមាន ចំនួន ៥៨៨ មាត្រា

.គន្ថីទី ១ បទប្បញ្ញត្តិទូទៅ និង មាន ៥ ជំពូក

.គន្ថីទី ២ នីតិវិធីនៃការជម្រះក្តីលើកទី១ និង មាន ៩ ជំពូក

.គន្ថីទី ៣ បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ និង មាន ៤ ជំពូក

.គន្ថីទី ៤ ការជំនុំជម្រះសាជាថ្មី គឺ ជំពូកទោល

.គន្ថីទី ៥ នីតិវិធីដាស់តឿន គឺ ជំពូកទោល

.គន្ថីទី ៦ នីតិវិធីអនុវត្តដោយបង្ខំ គឺ មាន ៤ ជំពូក

.គន្ថីទី ៧ ការចាត់ចែងរក្សាការពារ គឺ មាន ៣ ជំពូក

.គន្ថីទី ៨ អន្តរប្បញ្ញត្តិ គឺ ជំពូកទោល

.គន្ថីទី៩ អវសានប្បញ្ញត្តិ គឺមានតែ ជំពូកទោល

នេះគឺជាទំហំនៃក្រមនីតិវិធីរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជាយើង ។ ចំពោះបទប្បញ្ញត្តិពិសេសស្តីពីរឿងក្តីចំនួនទឹកប្រាក់តិច គឺ ស្ថិតនៅក្នុងជំពូកទី ៧ នៃគន្ថីទី ២ ដែរមានចែងក្នុងក្រមនីតិវិធីនេះផងដែរ ។

## ផ្នែកទី ២៖ គោលគំនិត នៃរឿងក្តីទឹកប្រាក់តិច

ច្បាប់នីតិវិធីរដ្ឋប្បវេណី គឺជានីតិទូទៅ មានន័យថា ច្បាប់នេះត្រូវបានយកទៅអនុវត្ត ដោយគ្មានការបែងចែក គ្មានការកម្រិតពីទំហំក្នុងការអនុវត្ត រួមទាំងបុគ្គល និងទីកន្លែង សាសនា សញ្ជាតិ គឺយកទៅអនុវត្ត លើមនុស្សទូទៅទាំងអស់ដែលនៅក្នុងដែនសមត្ថកិច្ចរបស់ប្រទេសកម្ពុជា ។ ម្យ៉ាងវិញទៀត បណ្តឹងរដ្ឋប្បវេណីមានគោលបំណងឱ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណីដោយផ្អែកច្បាប់ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន ។ ហើយជនគ្រប់រូបត្រូវបានធានានូវសិទ្ធិពឹងពាក់តុលាការចំពោះវិវាទរដ្ឋប្បវេណី។[1] ទោះបីជារឿងក្តីខ្លះមានកម្មវត្ថុនៃការទាមទារច្រើន ឬមួយតិចក៏ដោយ ក៏តុលាការធ្វើការសម្រេចសេចក្តីដោយផ្អែកទៅលើច្បាប់នឹងត្រូវធានាសិទ្ធិចំពោះជនគ្រប់រូបដែលបានមក ពឹងពាក់តុលាការ ។

ដោយសង្កេតឃើញថា ការជម្រះក្តីតាមនីតិវិធីធម្មតា គឺមានច្រើនដំណាក់កាល ដូចជានីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ការផ្សះផ្សាក្នុងនីតិវិធីត្រៀម នឹង មាននីតិវិធីទាញហេតុផលផ្ទាល់មាត់ ដែលជានីតិវិធីចុងក្រោយ ដើម្បីឈានដល់ការសម្រេចសេចក្តីដោយការចេញសាលក្រម ។ ដោយហេតុថា ការវិនិច្ឆ័យតាមនីតិវិធីបណ្តឹងធម្មតាបែបនេះធ្វើឱ្យមានការចំណាយពេលវេលា និងថវិការអស់ច្រើន ម្យ៉ាងទៀត ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាយើង នៅមានកម្រិតទាបនៅឡើយនោះ ហេតុនេះហើយ ទើបក្រមនីតិវិធីរដ្ឋប្បវេណីរបស់ប្រទេសកម្ពុជាបានចង់ក្រងឱ្យមាននូវបទបញ្ញត្តិពិសេសស្តីពីរឿងក្តីចំនួនទឹកប្រាក់តិចនេះឡើង ។

### កថាខ័ណ្ឌទី ១ ៖ អត្ថន័យនៃនីតិវិធីបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច

រវាងបុគ្គលឯកជន និងបុគ្គលឯកជននៅពេលណាដែលកើតមានវិវាទ គឺពួកគេនឹងរត់ទៅរកតុលាការឱ្យដោះស្រាយវិវាទរបស់ពួកគេ ។ តុលាការដោះស្រាយវិវាទរដ្ឋប្បវេណីនេះ គឺដោយផ្អែកទៅលើច្បាប់ ។ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់បុគ្គលឯកជន គឺជនគ្រប់រូបត្រូវបានធានានូវសិទ្ធិពឹងពាក់តុលាការចំពោះវិវាទផ្នែករដ្ឋប្បវេណី ។ [2] ហើយការដោះស្រាយវិវាទនេះទៀតសោត គឺមិនបានកំណត់ថាវាមានតម្លៃច្រើន ឬមួយតម្លៃកម្មវត្ថុមានចំនួនតិចនោះឡើយ ។ ហើយកាលណា តម្លៃកម្មវត្ថុនៃបណ្តឹងមានចំនួនតិច គឺគេត្រូវដោះស្រាយតាមនីតិវិធីពិសេស បើកម្មវត្ថុនៃបណ្តឹងនោះវាស្របទៅតាមលក្ខខណ្ឌ ដែលច្បាប់កំណត់អំពីកម្មវត្ថុនោះក្នុងកំរិតមួយជាក់លាក់ ដោយឡែកនីតិវិធីបណ្តឹងរឿងក្តីដែលមានចំនួនទឹកប្រាក់តិចនេះ គឺជាបណ្តឹងដែលមានកម្មវត្ថុនៃ

[1] មាត្រា២ ក្រមនីតិវិធីរដ្ឋប្បវេណី

[2] មាត្រា២ ក្រមនីតិវិធីរដ្ឋប្បវេណី

ការទាមទារមានតម្លៃជាទឹកប្រាក់មិនលើសពី ១.០០០.០០០ (មួយលាន) រៀល ។[3] នៅក្នុងន័យនេះ តម្លៃកម្មវត្ថុនៃបណ្ដឹង គឺសំដៅទៅលើកម្មវត្ថុចម្បងនៃការទាមទារតែប៉ុណ្ណោះ ម្យ៉ាងទៀតតម្លៃកម្មវត្ថុនៃបណ្ដឹងត្រូវបានធ្វើការគណនា ដោយផ្អែកលើមូលដ្ឋាននៃផលប្រយោជន៍ ដែលទាមទារនៅក្នុងបណ្ដឹង ហើយក្នុងករណីដែលមានការទាមទារច្រើនចំណុចនៅក្នុងណ្ដឹងតែមួយតម្លៃសរុប នៃការទាមទារទាំងនោះ ត្រូវចាត់ទុកជាតម្លៃកម្មវត្ថុនៃបណ្ដឹង ។ ក្នុងករណី ដែលការទាមទារទៅលើសំណងនៃការខូចខាតប្រាក់ធានាសងក្នុងករណីបំពានកិច្ចសន្យា ឬសោហ៊ុយ គឺជាកម្មវត្ថុបន្ទាប់បន្សំនៃបណ្ដឹង នោះតម្លៃកម្មវត្ថុទាំងនោះមិនត្រូវបូកសរុបទៅក្នុងការគណនាតម្លៃកម្មវត្ថុ នៃបណ្ដឹងឡើយ ។[4]

## កថាខ័ណ្ឌទី ២ ៖ គោលបំណង នៃនីតិវិធីរឿងក្ដីទឹកប្រាក់តិច

នីតិវិធីរឿងក្ដីចំនួនទឹកប្រាក់តិចវាក៏ជាផ្នែកមួយ នៃនីតិវិធីជំនុំជំរះលើអង្គសេចក្ដីធម្មតាផងដែរតែដោយសារនីតិវិធីរឿងក្ដីចំនួនទឹកប្រាក់តិច ច្បាប់បានកំណត់កម្មវត្ថុនៃបណ្ដឹងច្បាស់លាស់ ។ លើសពីនេះទៀតច្បាប់ ក៏បានកំណត់អំពីរគោលបំណងយ៉ាងច្បាស់ថា " នីតិវិធីរឿងក្ដីចំនួនទឹកប្រាក់តិចមានគោលបំណង ដើម្បីដោះស្រាយវិវាទដ៏ឆាប់រហ័សតាមនីតិវិធីសង្ខេប " ។[5] ដោយឈរទៅលើគោលបំណង នៃការដោះស្រាយដោយឆាប់រហ័ស និងសង្ខេប គឺដោយហេតុថាការដោះស្រាយតាមនីតិវិធីធម្មតានេះមានការចំណាយពេលវេលាទៅលើ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ការផ្សះផ្សានៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល រួមជាមួយនឹងការចំណាយទៅលើ សោហ៊ុយប្រាក់ប្រដាប់ក្ដី សោហ៊ុយក្នុងការធ្វើដំណើរ សោហ៊ុស្នាក់នៅសោហ៊ុយប្រាក់ម៉ោងធ្វើការ និងថ្លៃចំណាយផ្សេងៗ ។ ហើយចំពោះការកំណត់គោលបំណងបែបនេះ គឺជួយសម្រួលដល់ប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រ និងចង់បានយុត្តិធម៌ពីតុលាការ ។ ណាមួយកម្មវត្ថុ នៃការទាមទារមានចំនួនតិច ហើយអាចនៅពេលបញ្ចប់នីតិវិធីភាគីទាំងពីរត្រូវខាតបង់ ។

ទោះបីមានគោលបំណងឱ្យរហ័ស និងសង្ខេបក៏ដោយ ក៏តុលាការដែលជាស្ថាប័នអនុវត្តច្បាប់ត្រូវវិនិច្ឆ័យឱ្យបានលម្អិត ដោយយកចិត្តទុកដាក់ឱ្យបានគ្រប់ជ្រុងជ្រយ និងភាពច្បាស់លាស់ដើម្បីឱ្យភាគីទទួលបានយុត្តិធម៌ពិតប្រាកដ ។ ម៉្យាងវិញទៀត តុលាការត្រូវប្រឹងប្រែងធ្វើយ៉ាងណាដើម្បីរ៉ាប់រងបណ្ដឹងរដ្ឋប្បវេណីឱ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌និងឆាប់រហ័ស ឯភាគីត្រូវអនុវត្តបណ្ដឹងរដ្ឋប្បវេណីដោយសុចរិតនិងភាពស្មោះត្រង់[6] នេះគឺជា**គោលការណ៍ដឹកនាំនីតិវិធីរបស់តុលាការ** ។

[3] មាត្រា ២២៤ នីតិវិធីរដ្ឋប្បវេណី
[4]មាត្រា៦០ ក្រមនីតិវិធីរដ្ឋប្បវេណី
[5] មាត្រា២២៣ ក្រមនីតិវិធីរដ្ឋប្បវេណី
[6] មាត្រា ៤ ក្រមនីតិវិធីរដ្ឋប្បវេណី

# ជំពូកទី ២ ៖ លំហូរ នៃនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច

ចំពោះនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច គឺតុលាការអាចលើកយកសំណុំរឿងនោះមកជំនុំជំរះបានដោយហេតុថាភាគីបានដាក់ពាក្យបណ្តឹងមកតុលាការ (ផ្នែកទី១) និងក្រោយពីបានដាក់ពាក្យបណ្តឹងហើយនោះ ភាគីក៏អាចធ្វើការជ្រើសរើសនីតិវិធី នៃបណ្តឹងរឿងក្តីទឹកប្រាក់បានថែមទៀត (ផ្នែកទី២) ។

## ផ្នែកទី ១ ៖ ពាក្យបណ្តឹងនៃរឿងក្តីចំនួនទឹកប្រាក់តិច

ដូចដែលបានរៀបរាប់ខាងលើហើយថានីតិវិធីរឿងទឹកចំនួនប្រាក់តិច គឺជានីតិវិធីដែលមានលក្ខណៈពិសេស យ៉ាងណាមិញ ចំពោះការដាក់ពាក្យនៃរឿងក្តីចំនួនទឹកប្រាក់តិច ( កថាខ័ណ្ឌទី១) នេះក៏មានលក្ខណៈពិសេសជាងនីតិវិធី នៃបណ្តឹងធម្មតាដោយមានការដាក់ពាក្យបណ្តឹងដោយធ្វើជាលាយល័ក្ខណ៍អក្សរ ( ក ) និង ការដាម់ពាក្យបណ្តឹងដោយផ្ទាល់មាត់ ( ខ ) ផងដែរ ។ ហើយដើម្បីឱ្យពាក្យបណ្តឹងអាចមានសុពលភាពត្រូវបំពេញលក្ខខណ្ឌ ( កថាខ័ណ្ឌទី២ ) និង ដើម្បីអនុត្តនីតិវិធីនៃបណ្តឹងទៅបានឱ្យស្របច្បាប់នោះ គឺទាល់តែមានការបញ្ជូននូវពាក្យបណ្តឹង ( កថាខ័ណ្ឌទី៣ ) នេះដែរ ។

### កថាខ័ណ្ឌទី១ ៖ ការដាក់ពាក្យបណ្តឹងនៃរឿងក្តីចំនួនទឹកប្រាក់តិច

ពាក្យបណ្តឹងនៃរឿងក្តីចំនួនទឹកប្រាក់តិចអាចដាក់ជូនឱ្យតុលាការទទួលយកទៅវិនិច្ឆ័យបានតាមរបៀបពីរ៖

#### ១. របៀបដាក់ពាក្យបណ្តឹង ដែលធ្វើជាលិខិតលាយល័ក្ខណ៍អក្សរ

នៅក្នុងការដាក់ពាក្យបណ្តឹងជាធម្មតាពាក្យបណ្តឹង គឺត្រូវធ្វើឡើងជាទម្រង់លាយល័ក្ខណ៍អក្សរ គឺមានរបៀបដាក់ពាក្យបណ្តឹង និង ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹង ដូចខាងក្រោម៖

១. ការប្តឹង ត្រូវធ្វើដោយដាក់ពាក្យបណ្តឹងជាលាយល័ក្ខណ៍អក្សរទៅតុលាការ ។

២. នៅក្នុងលិខិត នៃពាក្យបណ្តឹងត្រូវសរសេរបញ្ជាក់នូវចំណុចខាងក្រោមនេះ

ក. ឈ្មោះ ឬនាមករណ៍ និងអសយដ្ឋានរបស់ភាគី ហើយនិងឈ្មោះ និងអសយដ្ឋានរបស់អ្នកតំណាង ដែលច្បាប់បានកំណត់ ។

ខ. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ និងអង្គហេតុចាំបាច់ដើម្បបញ្ជាក់នូវការទាមទារ ។

៣. នៅក្នុងពាក្យបណ្ដឹង ក្រៅពីចំណុច ដែលបានកំណត់នៅក្នុងចំណុច ខ នៃកថាខ័ណ្ឌទី ២ ខាងលើនេះ ដើមចោទគប្បីសរសេរឱ្យបានច្បាស់លាស់នូវអង្គហេតុ ដែលជាមូលហេតុនៃការទាមទារ និងតាមចំណុចដែលត្រូវបញ្ជាក់ភស្តុតាង គប្បីសរសេរបញ្ជាក់នូវអង្គហេតុសំខាន់ៗ ក្នុងចំណោមអង្គហេតុទាំងមូលដែលទាក់ទងនឹងអង្គហេតុ ដែលជាមូលហេតុនៃការទាមទារ និងភស្តុតាង ។

៤. ពាក្យបណ្ដឹងដែលមានសរសេរអំពីមធ្យោបាយតទល់ ឬ ការពារខ្លួនត្រូវចាត់ជាឯកសារត្រៀមផងដែរ ។[7]

នេះគឺជាអ្វីដែលដើមចោទសរសេរនៅក្នុងទម្រង់ពាក្យបណ្ដឹង ។ ចំពោះការសរសេរពាក្យបណ្ដឹងរឿងក្ដីទឹកចំនួនប្រាក់តិចនេះពុំចាំបាច់ស្របតាមលក្ខខ័ណ្ឌដូចមានចែងក្នុងចំណុច ខ កថាខ័ណ្ឌទី២ នៃមាត្រា ៧៥ នេះក៏ជាការគ្រប់គ្រាន់ហើយ កាលបើមានការបង្ហាញឱ្យបានច្បាស់លាស់អំពីចំណុចសំខាន់ នៃវិវាទនោះ ។[8] ហើយកថាខ័ណ្ឌនេះ បានបង្ហាញអំពី អង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ ហើយអង្គហេតុចាំបាច់ដែលបញ្ជាក់នូវការទាមទារនេះគឺវាជាអង្គហេតុ ដែលបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ដែលដើមចោទមានចំពោះចុងចម្លើយ ដូចជាដើមចោទបានធ្វើការទាមទារអំពីអត្ថិភាពនៃសិទ្ធិរបស់ខ្លួនចំពោះចុងចម្លើយ ដោយផ្អែកទៅលើកិច្ចសន្យាខ្ចីបរិភោគ ឬដោយកិច្ចសន្យាលក់ទិញជាដើម ។

ប្រសិនបើ ពាក្យបណ្ដឹងមានការខ្វះខាតនោះ ក្នុងករណីនេះក្រឡាបញ្ជីអាចធ្វើការផ្ដល់យោបល់ ចំពោះពាក្យបណ្ដឹងដែលមានចំណុចខ្វះខាតនោះ ដែលត្រូវកែតម្រូវ តែបើភាគីពុំធ្វើការកែតម្រូវនោះ ក្រឡាបញ្ជីមិនមានសិទ្ធិធ្វើការកែតម្រូវពាក្យបណ្ដឹង និងមិនមានសិទ្ធិលើកចោលពាក្យបណ្ដឹងនោះទេ មាន តែចៅក្រមទេដែលមានសិទ្ធិក្នុងការលើពាក្យបណ្ដឹងចោលបាន ។[9]

ការដាក់ពាក្យបណ្ដឹងជាលាយល័ក្ខខណ្ឌ៍អក្សរវាផ្ដល់អត្ថប្រយោជន៍ គឺឱ្យតុលាការយល់ដឹងច្បាស់ពីខ្លឹមដែលដើមចោទសុំឱ្យតុលាការចេញសាលក្រម និងអាចឱ្យតុលាការយល់ដឹងច្បាស់ពីអត្ថិភាព និងនត្ថិភាពនៃសិទ្ធិក្នុងការទាមទាររបស់ដើមចោទ លើសពីនេះទៀតវាជាឯកសារត្រៀមក្នុងករណីពាក្យបណ្ដឹងមានសរសេរពីមធ្យោបាយតទល់ និងមធ្យោបាយការពារខ្លួន ។

[7] មាត្រា ៧៥ ក្រមនីតិវិធីរដ្ឋប្បវេណី

[8] មាត្រា ២២៥ កថាខណ្ឌទី ២ ក្រមនីតិវិធីរដ្ឋប្បវេណី

[9] មាត្រា ៧៨ ក្រមនីតិវិធីរដ្ឋប្បវេណី

## ២. របៀបដាក់ពាក្យបណ្តឹងដែលធ្វើដោយផ្ទាល់មាត់

ដូចដែលបានរៀបរាប់ខាងលើ ចំពោះពាក្យបណ្តឹងនៃរឿងក្តីចំនួនទឹកប្រាក់តិច គឺមានលក្ខណៈពិសេសដែលអាចឱ្យដើមចោទធ្វើការៈ

១. ការដាក់ពាក្យបណ្តឹងនៃរឿងក្តីចំនួនទឹកប្រាក់តិច អាចធ្វើពាក្យបណ្តឹងដោយផ្ទាល់មាត់បាន។

២. ចំពោះការដាក់ពាក្យបណ្តឹង នៃរឿងក្តីចំនួនទឹកប្រាក់តិច ទោះបីជាមានបញ្ញត្តិនៅក្នុងចំណុច ខ កថាខ័ណ្ឌទី ២ នៃមាត្រា ៧៥ នៃក្រមនេះក៏ដោយ ក៏ជាការគ្រាប់គ្រាន់ហើយ កាលបើមានការបង្ហាញឱ្យច្បាស់លាស់អំពីចំណុចសំខាន់ៗនៃវិវាទនោះ ។

៣. នៅពេលដែលដើមចោទដាក់ពាក្យបណ្តឹងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវកត់ត្រានូវសេចក្តីថ្លែងការណ៍របស់ដើមចោទទៅក្នុងកំណត់ហេតុ ។ ក្នុងករណីនេះ កំណត់ហេតុនោះត្រូវចាត់ទុកជាពាក្យបណ្តឹង ។ [10]

ហើយតាមភាពជាក់ស្តែង ទាក់ទិននឹងកំណត់ហេតុនេះច្បាប់ពុំបានចែងឱ្យបានច្បាស់ពីទម្រង់អប្បរមារថាត្រូវសរសេរបែបណានោះទេ ។ ដូចនេះ ទម្រង់នៃកំណត់ហេតុអាចត្រូវសរសេរតាមបែបណាក៏បានដែរ តែត្រូវដឹងថាកំណត់ហេតុសរសេរពីរបញ្ហារឿងក្តីចំនួនទឹកប្រាក់តិច ។ ចំណុចនេះវាជា កាតព្វកិច្ចរបស់ក្រឡាបញ្ជី ក្នុងការកត់ត្រាយកព័ត៌មានទាំងអស់ដែលចាំបាច់ និងអ្វីដែលក្រឡាបញ្ជីបានស្តាប់ ឮពីដើមចោទ ។

ជាចុងក្រោយក្រឡាបញ្ជីដែលបានធ្វើការកត់ត្រានោះ ត្រូវចុះហត្ថលេខានៅលើកំណត់ហេតុនោះដោយខាន់ពុំបាន ពីព្រោះការចុះហត្ថលខារបស់ក្រឡាបញ្ជីបញ្ជាក់ពីការទទួលខុសត្រូវរបស់សាមី ក្រឡាបញ្ជី រូបនោះទៅលើកំណត់ហេតុថា ខ្លួនជាអ្នកធ្វើកំណត់ហេតុនោះពិប្រាកដមែន រីឯដើមចោទការចុះហត្ថលេខា ឬ ផ្តិតស្នាមមេដៃ អាចធ្វើក៏បាន ឬ មិនធ្វើក៏បាន ពីព្រោះថាឆ្លើយតបនិងចំណុចនេះ ពុំមានមាត្រាណាមួយចែងឱ្យបានច្បស់លាស់នោះទេ ។

ហើយអត្ថប្រយោជន៍ដែលច្បាប់អនុញ្ញាតឱ្យមានការធ្វើបណ្តឹងដោយផ្ទាល់មាត់នោះ គឺដោយហេតុថា ភាគច្រើនបំផុតប្រជាជនដែលជួបវិវាទរឿងក្តីចំនួនទឹកប្រាក់តិចជាប្រជាជនក្រីក្រ និងចំពោះការយល់ដឹងទៅលើវិស័យច្បាប់ក៏នៅមានកម្រិត ដូច្នេះ ដើម្បីធ្វើឱ្យមានភាពងាយស្រួលនោះ គឺ ច្បាប់បានផ្តល់សិទ្ធិឱ្យដើមចោទគ្រាន់តែធ្វើការនិយាយទៅប្រាប់ ក្រឡាបញ្ជីជាការស្រេច ។

[10] មាត្រា ២២៥ ក្រមនីតិវិធីរដ្ឋប្បវេណី

## កថាខណ្ឌទី ២ ៖ លក្ខណ្ឌ នៃបណ្ដឹងរឿងក្ដីចំនួនទឹកប្រាក់តិច

ជាទូទៅចំពោះរឿងក្ដីដែលបានធ្វើការប្ដឹងទៅតុលាការ ដែលជាស្ថាប័នដែលមានសមត្ថកិច្ច នៅក្នុងការវិនិច្ឆ័យក្ដីនោះ គឺត្រូវបំពេញនូវលក្ខខ័ណ្ឌមួយចំនួនផងដែរ បើពុំនោះទេ ការសម្រេចក្ដីនោះ នឹងមិនអាចដំណើរការទៅបានឡើយ ហើយលក្ខខ័ណ្ឌនោះរួមមាន៖

### ១. កម្មវត្ថុនៃបណ្ដឹង

បណ្ដឹងអាចធ្វើឡើងបាន ក្នុងករណីបណ្ដឹងនោះមានកម្មវត្ថុជាវិវាទតាមផ្លូវច្បាប់ជាក់ស្ដែង និងដែលវិវាទនោះអាចដោះស្រាយបានដោយសាលក្រម ។ [11]ការប្ដឹងទៅតុលាការ គឺដើម្បីឱ្យតុលាការសម្រេចទៅលើកម្មវត្ថុនៃការទាមទារណាមួយ ហើយកម្មវត្ថុនៃការទាមទារតាមផ្លូវបណ្ដឹងនេះ គឺអាចធ្វើបាននៅពេលបច្ចុប្បន្ន និងមានភាពស្របច្បាប់ផងដែរ ។ ដោយឡែកចំពោះបណ្ដឹងនៃរឿងក្ដីចំនួនទឹកប្រាក់តិច គឺជាបណ្ដឹងទាមទារឱ្យផ្ដល់តាវការលិក ដែលវាគឺជាចំនួនទឹកប្រាក់ដែលមិនលើសពី ១.០០០.០០០ (មួយលាន) រៀល ដែលជាកម្មវត្ថុនៃបណ្ដឹង ។ ម្យ៉ាងទៀតការទាមទារនេះគឺដោយផ្អែកទៅ អង្គហេតុដែលបញ្ជាក់នូវការទាមទារដែលស្របច្បាប់ ជាអាទិ៍ ការទាមទារដោយមូលហេតុនៃការកើតមាននូវតាមកិច្ចកិច្ចសន្យាខ្ចីបរិភោគ ដែលអាចអោយតុលាការទទួលយកមកធ្វើការវិនិច្ឆ័យ និង សម្រេចដោយសាលក្រមទៅបាន ។

ដោយឡែកដូចជា បណ្ដឹងដែលទាក់ទងទៅនិងកិច្ចសន្យាលេងល្បែងស៊ីសង និង បណ្ដឹងទាមទារប្រាក់ដែលបានមកពីកិច្ចសន្យាលក់ដូរគ្រឿងញៀន គឺវាជាបណ្ដឹងត្រឹមត្រូវ តែកម្មវត្ថុនៃបណ្ដឹងគឺ ច្បាប់មិនទទួលស្គាល់ព្រោះ តែកម្មវត្ថុនៃបណ្ដឹងវាផ្ទុយទៅនិងមាត្រា ៧៤ នៅក្នុង ករណីមានបណ្ដឹងផ្ទុយនឹងច្បាប់ ហើយចំពោះចំណុចដែលខ្វះខាតនោះមិនអាចធ្វើការកែតម្រូវបានទេ តុលាការអាចលើកបណ្ដឹងនោះចោលដោយសាលក្រម ដោយមិនឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់បានទេ ។ [12]

### ២. សមត្ថភាពក្នុងការធ្វើសកម្មភាពបណ្ដឹង

ជាបន្តទៅទៀតនេះ សមត្ថភាពក្នុងការធ្វើសកម្មភាពបណ្ដឹង គឺ មានន័យមិនដូចគ្នាទៅនឹងសមត្ថភាពភាគីទេ ។ ភាគី ជាជនដែលទាមទារសាលក្រម ឬ សាលដីកានៅក្នុងនាមរបស់ខ្លួន ។ ភាគី គឺ ជាប្រធាននៃនីតិវិធីបណ្ដឹងរដ្ឋប្បវេណី មិនគ្រាន់តែជាកម្មវត្ថុ (កម្មវត្ថុនៃការពិនិត្យ ) ទេ ។ ចំពោះរឿងក្ដីរដ្ឋប្បវេណី គឺជារបបមួយដើម្បីដោះស្រាយវិវាទរវាងបុគ្គលឯកជន និង បុគ្គលឯកជនតាមរយៈការកំណត់ជាស្ថាពរនូវ អត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ និង កាតព្វកិច្ច ឬ ទំនាក់ទំនងគតិយុត្តិ

[11] មាត្រា ៧៤ ក្រមនីតិវិធីរដ្ឋប្បវេណី

[12] មាត្រា ៨១ ក្រមនីតិវិធីរដ្ឋប្បវេណី

តាមផ្លូវនីតិឯកជន ហើយជាអាទិ៍សូម្បីទារកក្នុងគភ៌ ក៏មានសមត្ថភាពទទួលសិទ្ធិជាភាគីនៃបណ្តឹងស្តីពីបណ្តឹងទាមទារសំណងការខូចខាតដោយផ្អែកតាមអំពើអនីត្យានុកូល ឬស្តីពីបណ្តឹងពាក់ព័ន្ធនឹងសន្តតិកម្ម និងអច្ច័យទាន[13] ហេតុនេះហើយការកំណត់ឱ្យជនដែលអាចធ្វើជាប្រធាននៃបណ្តឹងដែលមានសិទ្ធិនៅក្នុងនីតិឯកជន ដែលជាប្រធាននៃរឿងក្តី គឺជាការសមរម្យ ។

ម្យ៉ាងទៀត បុគ្គលដែលមានសម្ថភាពធ្វើសកម្មភាពដោយខ្លួនឯង តាមច្បាប់ រដ្ឋប្បវេណី ( ជាទូទៅ គឺចំពោះនីតិជន ត្រូវបានកំរិតចាប់ពីអាយុ ១៨ ឆ្នាំឡើងទៅ[14] ឬ បើជាអនីតិជនគឺជននោះត្រូវទទួលបាននូវអត្តាធិនភាព គឺត្រូវបានច្បាប់ចាត់ទុកថា បានដល់នីតិភាព[15] ) គឺអាចដាក់ពាក្យបណ្តឹងដោយខ្លួនឯងបាន ដោយតាំងខ្លួជាដើមចោទ ឬ អាចធ្វើការឆ្លើយដោះសារចំពោះបណ្តឹងដោយតាំងខ្លួនជាចុងចម្លើយ ឬ ធ្វើការសារភាពតាមផ្លូវបណ្តឹងផ្សេងទៀតដែលជាចាំបាច់ ។ [16] ការដែលភាគីនៃបណ្តឹងមានសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹង វាគឺជាលក្ខខ័ណ្ឌនៃបណ្តឹងមួយហើយតុលាការត្រូវស្រាវជ្រាវនូវចំណុចនេះដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

ប្រសិនបើ ភាគីម្ខាង ឬភាគីទាំងសងខាងកង្វះសមត្ថភាពធ្វើសកម្មភាពបណ្តឹងនោះតុលាការត្រូវចេញសាលក្រមលើកបណ្តឹងនោះ ដោយសារតែមិនស្របនិងលក្ខខ័ណ្ឌច្បាប់បានកំណត់ ។ ក្នុងករណីដែលភាគី ពុំមានសមត្ថភាពធ្វើសកម្មភាពតែបើតុលាការមិនបានដឹង ហើយចេញសាលក្រម ឬ សាលដីកា ភាគីណាម្ខាងទៀតក៏អាចប្តឹងទាមទារឱ្យលុបចោលសាលក្រម ឬសាលដីកានោះតាមរយៈបណ្តឹងឧបាស្រ័យទៅតុលាកាជាន់ខ្ពស់បាន ( បណ្តឹងឧទ្ធរណ៍ ឬ បណ្តឹងសាទុក្ខ ) នៅពេលសាលក្រម ឬ សាលដីកានោះមិនទានចូលជាស្ថាពរ តែបើវាចូលជាស្ថាពរហើយនោះវានិងកើតមាននូវអជ្ញាអស់ជំនុំ គឺមិនអាចប្តឹងលុបចោលបានឡើយ ។

ដើម្បីបង្ការបញ្ហារនេះកុំឱ្យកើតមានឡើង ចំពោះអនីតិជន និងជននៅក្រមអាណាព្យាបាលទូទៅនោះ និងជននេះ អាចធ្វើសកម្មភាពបណ្តឹងមានសុពលភាពទៅបាន លុះត្រាតែ ត្រូវបានធ្វើដោយអ្នកតំណាងដែលច្បាប់បានកំណត់ ។ ប៉ុន្តែ បញ្ញត្តិមិនត្រូវយកមកអនុវត្តឡើយ ចំពោះអនីតិជនដែលអាចធ្វើសកម្មភាពដោយឯករាជ្យ ។ [17] ហើយការបញ្ញត្តិបែបនេះ គឺដើម្បីជួយសង្គ្រោះដល់ជនដែលត្រូវបានកម្រិតសមត្ថភាព និងម្យ៉ាងទៀតវាក៏ស្របទៅនិង គោលបំណងដែរថា ជនគ្រប់រូប

[13] មាត្រា ៩ និង មាត្រា ១១៩៩ កថាខណ្ឌទី ២ ក្រមនីតិរដ្ឋប្បវេណី
[14] មាត្រា ១៧ ក្រមនីតិរដ្ឋប្បវេណី
[15] មាត្រា ២២ ក្រមនីតិរដ្ឋប្បវេណី
[16] មាត្រា ៣២ កថាខណ្ឌទី ១ ក្រមនីតិវិធីរដ្ឋប្បវេណី
[17] មាត្រា ៣២ កថាខណ្ឌទី ២ ក្រមនីតិវិធីរដ្ឋប្បវេណី

ត្រូវបានធានានូវសិទ្ធិពឹងពាក់តុលាការឱ្យធ្វើការដោះស្រាយវិវាទចំពោះរឿងរដ្ឋប្បវេណី[18] ហើយនេះជាគោលការណ៍ នៃសិទ្ធិពឹងពាក់តុលាការផងដែរ ។

ជាធម្មតាអ្នកតំណាងដោយអាណត្តិត្រូវតែជាមេធាវី ដោយឡែក ចំពោះនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិចអ្នកតំណាងដោយអាណត្តិមិនចាំបាច់ជាមេធាវីនោះទេ នៅក្នុងករណី ដែលតុលាការអនុញ្ញាតឱ្យមានការតំណាងដោយតតិយជនដែលមិនមែនជាមេធាវី នៅក្នុងរឿងក្តីដែលមានកម្មវត្ថុនៃបណ្តឹងតិចជាង ១.០០០.០០០ ( មួយលាន ) រៀល ។[19]

### ៣. តុលាការដែលមានសមត្ថកិច្ច

តុលាការនៅកម្ពុជា គឺត្រូវបានបែងចែកជាពីរជាន់ និងបីថ្នាក់ ហើយតុលាការថ្នាក់ទីមួយ គឺសាលាដំបូងរាជធានី-ខេត្ត-ក្រុង លើសពីនេះទៅទៀត សាលាដំបូងគឺមានសមត្ថកិច្ចនៅលើដែនដីដែលខ្លួនតាំងនៅ ។ តុលាការ ដែលមានសមត្ថកិច្ច គឺជាតុលាការដែលអាចទទួលដោយស្របច្បាប់នូវពាក្យបណ្តឹង វិនិច្ឆ័យលើរឿងក្តី ហើយចេញសាលក្រម ឬសាលដីកាបាន ។ [20] សមត្ថកិច្ចតុលាការ ក៏ជាល័ក្ខណ្ឌមួយផងដែរដើម្បីឱ្យបណ្តឹងមានសុពលភាពតាមផ្លូវច្បាប់ ហើយតុលាការដែលបានទទួលពាក្យបណ្តឹងអាចធ្វើការពិនិត្យភស្តុតាងចំពោះបញ្ហា ដែលទាក់ទងនឹងសមត្ថកិច្ចសាលាជម្រះក្តីដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។ [21] បើតុលាការ ដែលបានទទួលពាក្យបណ្តឹងនោះអសមត្ថកិច្ច ឬដោះស្រាយវិវាទនោះមិនត្រឹមត្រូវនោះវានាំឱ្យមានបណ្តឹងទៅសាលាឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខនោះសាលាឧទ្ធរណ៍នឹងពិនិត្យ ហើយមោឃៈរាល់សេចក្តីសម្រេចរបស់សាលាដំបូង ។ ម៉្យាងទៀត តុលាការដែលមានសមត្ថកិច្ចនេះគេអាចធ្វើការបែងចែកជា តុលាការដែលមានសមត្ថកិច្ចផ្តាច់មុខ និងតុលាការ ដែលមានសមត្ថកិច្ចតាមការជ្រើសរើសរបស់គូរភាគី ។

### ៣.១. តុលាការដែលមានសមត្ថកិច្ចផ្តាច់មុខ

តុលាការដែលមានសមត្ថកិច្ចផ្តាច់មុខនេះ គឺច្បាប់បានកំណត់យ៉ាងជាក់ច្បាស់ថាគ្មានតុលាការណាមួយមានសិទ្ធិទទួលពាក្យបណ្តឹង និងចេញសាលក្រម ដើម្បីបង្កើតឱ្យមានអានុភាពបានឡើយ ក្រៅពីរតុលាការដែលច្បាប់បានកំណត់ទុកជាមុន ថាជាតុលាការដែលមានសមត្ថកិច្ចផ្តាច់មុខ ។ ហើយតុលាការដែលមានសមត្ថកិច្ចផ្តាច់មុខនេះ គេអាចធ្វើការបែងដូចខាងក្រោមៈ

[18] មាត្រា ២ កថាខណ្ឌទី ២ ក្រមនីតិវិធីរដ្ឋប្បវេណី
[19] មាត្រា ៥៣ កថាខណ្ឌទី ១ ចំណុច គ ក្រមនីតិវិធីរដ្ឋប្បវេណី
[20] មាត្រា ៧ ក្រមនីតិវិធីរដ្ឋប្បវេណី
[21] មាត្រា ១៦ ក្រមនីតិវិធីរដ្ឋប្បវេណី

### ៣.១. ១. តុលាការដែលមានសមត្ថកិច្ចផ្តាច់មុខតាមភារៈកិច្ច

ការកំណត់តុលាការទៅតាមភារៈកិច្ចនេះ គឺគេធ្វើការកំណត់ទៅតាមមុខងារ នៃតុលាការនីមួយៗនោះក្នុងការសម្រេចសេចក្តី ។ ចំពោះសមត្ថកិច្ចតុលាការតាមភារៈកិច្ចនេះ គឺគេធ្វើការកំណត់យ៉ាងច្បាស់ អំពីភារៈកិច្ចរបស់តុលាការ ដូចជារឿងព្រហ្មទណ្ឌនោះ គឺជាសមត្ថកិច្ចរបស់តុលាការព្រហ្មទណ្ឌ ហើយវិវាទនៅក្នុងរឿងរដ្ឋបាល គឺជាសមត្ថកិច្ចរបស់តុលាការរដ្ឋបាល រីឯតុលាការពាណិជ្ជកម្ម គឺមានសមត្ថកិច្ចនៅក្នុងការដោះស្រាយទំនាស់រវាងពាណិជ្ជករ និង ពាណិជ្ជករ ។ ចំពោះវិវាទដែលកើតឡើងរវាង កម្មករនិយោជិក និង និយោជក ដែលវាជាវិវាទរឿងការងារនោះ គឺជាសមត្ថកិច្ចរបស់តុលាការ ការងារ ។ តុលាការទាំងនេះ គឺ រាជរដ្ឋាភិបាលមានគំរោងបង្កើតនៅពេលឆាប់ៗខាងមុខនេះ ។

ដោយឡែកតុលាការតាមមុខងារនេះទៀតសោតនៅក្នុងតុលាការរដ្ឋប្បវេណី គឺរឿងក្តីរដ្ឋប្បវេណីដូចគ្នាតែអាចធ្វើការបែងចែងតុលាការដែលមានសមត្ថកិច្ចផ្តាច់មុខ ដែលមានចែងនៅក្នុងច្បាប់យ៉ាងច្បាស់ ដូចជាបណ្តឹងទាមទារឱ្យជំនុំជំរះសារជាថ្មី ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់តុលាការដែលបានចេញសាលក្រម ឬសាលដីកា ដែលជាកម្មវត្ថុនៃការជំនុំជម្រះសារជាថ្មី ។ [22] និងពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន មាត្រា ៣២០ កថខណ្ឌទី២ ( កថាខ័ណ្ឌទី២ មានដល់ទៅចំនួន ២ ) ។ សមត្ថកិច្ចដែលបានកំណត់នៅក្នុង គន្ថីទី៦ ការអនុវត្តដោយបង្ខំ គឺជាសមត្ថកិច្ចផ្តាច់មុខ ។[23] និងជាចុងក្រោយនោះ គឺសមត្ថកិច្ចតុលាការដែលកំណត់នៅ គន្ថីទី៧ ការចាត់ចែងរក្សាការពារវាក៏ច្បាប់បានកំណត់ថាជាសមត្ថកិច្ចផ្តាច់មុខផងដែរ ។[24]

### ៣.១.២. តុលាការដែលមានសមត្ថកិច្ចផ្តាច់មុខតាមដែនដី

សមត្ថកិច្ចតុលាការផ្តាច់មុខតាមដែនដីនេះគឺមានការកំណត់ពីយ៉ាង ទីមួយ សមត្ថកិច្ចដែនដីដែលតាមលំនៅឋាន និងទីពីរ សមត្ថកិច្ចដែនដីដែលកំណត់តាមទ្រព្យសម្បត្តិ ។

**ទីមួយ:** បណ្តឹងចំពោះចុងចម្លើយដែលបានកំណត់ក្នុងចំណុចខាងក្រោមនេះ ត្រូវដាក់ពាក្យបណ្តឹងនៅសាលាដំបូង ដែលមានសមត្ថកិច្ចជម្រះក្តីនៅទីកន្លែងដែលបានកំណត់នៅចំណុចនីមួយៗខាងក្រោម:

ក. ចំពោះរូបវន្តបុគ្គល

---

[22] មាត្រា ៣០៩ កថាខណ្ឌទី ២ ក្រមនីតិវិធីរដ្ឋប្បវេណី

[23] មាត្រា ៣៩៦ ក្រមនីតិវិធីរដ្ឋប្បវេណី

[24] មាត្រា ៥៣៣ ក្រមនីតិវិធីរដ្ឋប្បវេណី

- លំនៅឋានរបស់ចុងចម្លើយ ។

- ទីសំណាក់ បើពុំមានលំនៅឋាន ឬមានលំនៅឋានមិនពិតប្រាកដ នៅព្រះរាជាណាចក្រកម្ពុជា។

- លំឋានចុងក្រោយ បើពុំមានទីសំណាក់ ឬទីសំណាក់មិនពិតប្រាកដ ។

ខ. នីតិបុគ្គលក្នុងប្រទេស

- ទីតាំងនៃទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មជាចម្បង ។

- លំនៅឋានរបស់អ្នកតំណាង ឬ របស់អ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារចម្បង បើគ្មានទីស្នាក់ការ ឬទីកន្លែងអាជីវកម្មទេ ។

គ. នីតិបុគ្គលបរទេស

- ទីតាំងនៃទីស្នាក់ការ ឬទីកន្លែងអាជីវកម្មជាចម្បង ។

- ទីលំនៅឋានរបស់អ្នកតំណាងប្រចាំព្រះរាជាណាចក្រកម្ពុជា ឬរបស់អ្នកទទួលខុសត្រូវភារកិច្ចចាត់ចែងការងារជាចម្បងក្នុងព្រះរាជាណាចក្រកម្ពុជា បើគ្មានទីស្នាក់ការ ឬទីកន្លែងអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ។[25]

**ទីពីរ:** ក្រៅពីសមត្ថកិច្ចដែនដីដែលបានកំណត់ខាងលើ អាចប្តឹងនៅតុលាការដែលមានសមត្ថកិច្ចនៅទីកន្លែងដែលបានកំណត់ក្នុងចំណុចនីមួយៗ ក៏បានដែរ៖

ក. បណ្តឹងទាមទារឱ្យអនុវត្តកាតព្វកិច្ច កន្លែងដែលត្រូវអនុវត្តកាតព្វកិច្ច ។

ខ. បណ្តឹងទាមទារឱ្យបង់ប្រាក់ដោយរូបបិយាណត្តិ ឬមូលប្បទានប័ត្រ កន្លែងបង់រូបិយាណត្តិ ឬមូលប្បទានប័ត្រ ។

គ. បណ្តឹងទាមទារឱ្យអនុវត្តកាតព្វកិច្ច ចំពោះបុគ្គលដែលពុំមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា ឬលំនៅឋានមិនពិតប្រាកដ ទីកន្លែងដែលកម្មវត្ថុនៃការទាមទារនោះ ឬវត្ថុនៃប្រាតិភោគដែលធានាលើការទាមទារនោះ ឬទ្រព្យរបស់ចុងចម្លើយដែលអាចរឹបអូសបានស្ថិតនៅ ។

[25] មាត្រា ៨ ក្រមនីតិវិធីរដ្ឋប្បវេណី

ឃ. បណ្តឹងទាមទារឱ្យអនុវត្តកាតព្វកិច្ចចំពោះនីតិបុគ្គល ដែលពុំមានទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មក្នុងព្រះរាជាណាចក្រកម្ពុជា ឬទីស្នាក់ការ ឬទីកន្លែងអាជីវកម្មមិនពិតប្រាកដៈ កន្លែងដែលកម្មវត្ថុនៃការទាមទារ ឬកម្មវត្ថុនៃប្រាតិភោគដែលធានាលើការទាមទារនោះ ឬទ្រព្យរបស់ចុងចម្លើយដែលអាចរឹបអូសបានស្ថិតនៅ ។

ង. បណ្តឹងចំពោះបុគ្គល ដែលមានទីស្នាក់ការ ឬទីកន្លែងអាជីវកម្ម ដែលទាក់ទងនឹងសកម្មភាពការងាររបស់ទីស្នាក់ការ ឬទីកន្លែងអាជីវកម្មនោះ : ទីតាំងនៃទីស្នាក់ការ ឬ ទីកន្លែងអាជីវកម្មនោះ ។

ច. បណ្តឹងទាក់ទងអំពើអនីត្យានុកូលៈ កន្លែងដែលអំពើអនីត្យានុកូលនោះកើតឡើង ។

ឆ. បណ្តឹទាក់ទងនឹងអចលនវត្ថុៈ កន្លែងដែលអចលនវត្ថុនោះស្ថិតនៅ ។

ជ. បណ្តឹងទាក់ទងនឹងការចុះបញ្ជីៈ កន្លែងដែលត្រូវចុះបញ្ជីនោះ ។

ឈ. បណ្តឹងទាក់ទងនឹងមតិកៈ និវាសនដ្ឋានរបស់មតកជន នៅពេលសន្តតិកម្មត្រូវបានចាប់ផ្តើម ឬទីសំណាក់ បើពុំមាននិវាសនដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជា ឬមាននិវាសនដ្ឋានមិនពិតប្រាកដ ឬនិវាសនដ្ឋានចុងក្រោយ បើមតកជននោះពុំមានទីសំណាក់ក្នុងព្រះរាជាណាចក្រកម្ពុជា ឬទីសំណាក់មិនពិតប្រាកដ ។ [26]

### ៣.២. សមត្ថកិច្ចតាមជម្រើស

យើងក៏អាចកំណត់យកសមត្ថកិច្ចរបស់តុលាការតាមរយៈការដាក់ពាក្យបណ្តឹងដែលខ្លួនឯងយល់ឃើញថាមានការចំណាយថវិកាតិចតួច និងមានការចំណេញពេលវេលានិងសុវិត្ថិភាពនៅក្នុងការធ្វើដំណើរ ដោយយល់ឃើញពីហេតុផលបែបនេះទើបច្បាប់អនុញ្ញាតឱ្យមានការជ្រើសរើសសមត្ថកិច្ចតុលាការ ។ ម្យ៉ាងទៀត សមត្ថកិច្ចតុលាការនេះក៏អាចមានការកំណត់ផងដែរ ដោយតុលាការថ្នាក់លើ ដោយហេតុថាមានវិវាទអំពីសមត្ថកិច្ចរបស់តុលាការថ្នាក់ក្រោម ព្រោះតុលាការថ្នាក់លើមានសិទ្ធិអំណាចនៅក្នុងការធ្វើអធិបញ្ញាមកតុលាការថ្នាក់ក្រោម ។

#### ៣.២.១.សមត្ថកិច្ចតុលាការដែលកើតឡើងដោយគ្មានការតវ៉ាពីចុងចម្លើយ

សមត្ថកិច្ចតុលាការដែលកើកឡើងដោយគ្មានការតវ៉ាពីចុងចម្លើយ គឺជាសមត្ថកិច្ចដែលកើតឡើងដោយសកម្មភាពឆ្លើយតបរបស់ចុងចម្លើយ ។ ហើយការឆ្លើយតបនេះពុំមែនឆ្លើយតបតវ៉ាអំពីសមត្ថកិច្ចតុលាការនេះទេ គឺនៅពេលដែលចុងចម្លើយបានធ្វើសេចក្តីដោះសាអំពីអង្គហេតុនៅក្នុង

[26] មាត្រា ៩ ក្រមនីតិវិធីរដ្ឋប្បវេណី

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬបានឆ្លើយទាញហេតុផលអំពីអង្គសេចក្តីនៅក្នុងការទាញហេតុផលផ្ទាល់មាត់រួចហើយ នៅក្នុងការជំនុំជម្រះលើកទី១ ដោយគ្មានការតវ៉ាអំពីកំហុសនៃសមត្ថកិច្ចសាលាជម្រះក្តីនោះ តុលាការនេះត្រូវមានសមត្ថកិច្ចជម្រះក្តី ។[27] សមត្ថកិច្ចតុលាការដែលគ្មានការតវ៉ាពីចុងចម្លើយនេះគឺត្រូវបាបទទួលស្គាល់ចំពោះសមត្ថកិច្ចមិនផ្តាច់មុខតែប៉ុណ្ណោះ[28] និងត្រូវទទួលស្គាល់ចំពោះសមត្ថចកិច្ចតាមដែនដីផងដែរ ។

### ៣.២.២. សមត្ថកិច្ចដែលជ្រើសដោយតុលាការថ្នាក់លើ

ជាទូទៅសមត្ថកិច្ចរបស់តុលាការ គឺត្រូវបានធ្វើការកំណត់ដោយច្បាប់ ប៉ុន្តែ ក៏មានករណីដែលតុលាការដែលមានសមត្ថកិច្ចមិនអាចអនុវត្តនូវសិទ្ធិជម្រះក្តីបានដោយសារច្បាប់ ឬហេតុការណ៍ពិត ឬ ករណីដែលសមត្ថកិច្ចសាលាជម្រះក្តីមិនអាចកំណត់បានដោយសារដែនសមត្ថកិច្ចតុលាការមិនពិតប្រាកដ នោះតុលាការកំពូលត្រូវកំណត់តុលាការដែលមានសមត្ថកិច្ច ដោយដីកាសម្រេចតាមពាក្យសុំ។ [29] ករណីដែលមិនអាច អនុវត្តនូវសិទ្ធិក្នុងការសម្រេចសេចក្តីរបស់តុលាការ ដោយសារច្បាប់ ដូចជាចៅក្រមនៅសាលាជម្រះក្តីដកខ្លួន ឬ មួយមានជម្ងឺធ្ងន់ធ្ងរ អវត្តមាន ដែលនាំឱ្យការសម្រចក្តីមិនអាចដំណើការទៅបាន ។ និងករណីដែលមិនអាចអនុវត្តសិទ្ធិក្នុងការសម្រេចសេចក្តីបានដោយហេតុការណ៍ពិត ដូចជាទីតាំងរបស់តុលាការទទួលរងនូវគ្រោះធម្មជាតិក្នុងអំឡុងពេលយូរ ដោយមិនអាចជម្នះបាន ។

## កថាខ័ណ្ឌទី ៣ ៖ ការបញ្ជូនពាក្យបណ្តឹង

នៅក្រោយពីពេល ដែលដាក់ពាក្យបណ្តឹង គឺពាក្យបណ្តឹងនោះត្រូវធ្វើការបញ្ជូនទៅចុងចម្លើយជាចាំបាច់ ។ [30] បន្ទាប់ពីបានទទួលពាក្យបណ្តឹង និងពិនិត្យឃើញថា ពាក្យបណ្តឹងនោះត្រឹមត្រូវតាមច្បាប់ហើយ តុលាការត្រូវធ្វើការបញ្ជូននូវ ពាក្យបណ្តឹង និងដីកាកោះ ឬឯកសារផ្សេងទៀតទៅចុងចម្លើយ ។

ការបញ្ជូន គឺជាការជូនដំណឹងដែលធ្វើឡើងតាមវិធីដែល ច្បាប់បានកំណត់ ដើម្បីជូនដំណឹងអំពីខ្លឹមសារ នៃឯកសារដែលត្រូវធ្វើការបញ្ជូនតាមផ្លូវបណ្តឹងចំពោះភាគី និងអ្នកដ៏ទៃទៀតដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍ ។ រីឯការជូនដំណឹង គឺជាវិធីដែលមានលក្ខណៈទូលាយ និងងាយស្រួលជាងវិធីនៃការបញ្ជូន ដោយហេតុថាការជូនដំណឹងមន្ត្រីប្រតិបត្តិការបញ្ជូនអាចប្រើគ្រប់

[27] មាត្រ ១៤ ក្រមនីតិវិធីរដ្ឋប្បវេណី
[28] មាត្រា ១៥ ក្រមនីតិវិធីរដ្ឋប្បវេណី
[29] មាត្រា ១២ ក្រមនីតិវិធីរដ្ឋប្បវេណី
[30] មាត្រា ៧៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

មធ្យោបាយ (ដូចជា តាមទូរស័ព្ទ អ៊ីម៉ែល សំបុត្រជាដើម) ដើម្បីឱ្យអ្នកដែលត្រូវទទួលការបញ្ជូនបាន ដឹង ក្នុងនោះនីតិវិធីនៃការបញ្ជូនក៏ជាមធ្យោបាយមួយនៃការជូនដំណឹងផងដែរ ។

ការបញ្ជូនពាក្យបណ្តឹងតាមនីតិវិធីបែបនេះ គឺដើម្បីធានានូវគោលការណ៍ចំពោះមុខដែលត្រូវធ្វើការកោះហៅភាគី និងធ្វើការសាកសួរមុនធ្វើកាត់សេចក្តី ។ ហើយការបញ្ជូនត្រូវធ្វើឡើងដោយមន្ត្រីទទួលបន្ទុក កិច្ចការបញ្ជូន គឺក្រឡាបញ្ជី និងមន្ត្រីប្រតិបត្ត កិច្ចការបញ្ជូន មានដូចជា: បុគ្គលិកប្រៃសណីយ៍ អាជ្ញាសាលា ឬ ក្រឡាបញ្ជី ។ [31]

### ១. វិធីការបញ្ជូន

ដើម្បីធ្វើការបញ្ជូនត្រឹមត្រូវតាមច្បាប់ លុះត្រាតែវិធីនៃការបញ្ជូននោះធ្វើឡើងស្របទៅតាមច្បាប់ ។ នៅក្នុងបញ្ញត្តិច្បាប់ វិធីនៃការបញ្ជូនមាន ៣ របៀបសំខាន់ៗ គឺការបញ្ជូនដោយប្រគល់ការបញ្ជូនទៅបរទេស និងការបញ្ជូនតាមការផ្សាយជាសាធារណៈ ។

### ១. ១. ការបញ្ជូនដោយប្រគល់

ជាគោលការណ៍ការបញ្ជូនដោយប្រគល់ ត្រូវធ្វើឡើងដោយការប្រគល់នូវឯកសារដែលត្រូវធ្វើការបញ្ជូនទៅឱ្យជនដែលត្រូវទទួលការបញ្ជូននោះ[32] ។ ហើយការប្រគល់នោះត្រូវធ្វើឡើងនៅលំនៅឋាន ឬទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការរបស់ជនដែលត្រូវទទួលការបញ្ជូននោះ ។ ពាក្យថាលំនៅឋាន គឺជាកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ ក្នុងករណីដែលទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ទេ ទីសំណាក់ត្រូវចាត់ទុកជាលំនៅឋាន[33] ។ ចំពោះការបញ្ជូនទៅអ្នកតំណាងដែលច្បាប់បានកំណត់អាចធ្វើទៅនៅទីកន្លែងអាជីវកម្ម ឬទីស្នាក់ការរបស់អ្នកតំណាងនោះ ។

ទោះជាយ៉ាងនេះក្តី ប្រសិនបើ មានការជូនដំណឹងអំពីទីកន្លែងដែលត្រូវធ្វើការបញ្ជូន ឬជូនដំណឹងអំពីការផ្លាស់ប្តូរទីកន្លែងនោះ នោះត្រូវធ្វើការបញ្ជូនទៅទីកន្លែងដែលបានជូនដំណឹងនោះ ។ ការជូនដំណឹងខាងលើនេះត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ក្នុងករណីដែលពាក្យបណ្តឹង ដែលបានបញ្ជាក់អំពីទីកន្លែងដែលត្រូវធ្វើការបញ្ជូន ឬអ្នកដែលទទួលការបញ្ជូនក៏ត្រូវចាត់ទុកថាភាគីបានជូនដំណឹងជាលាយល័ក្ខណ៍អក្សរអំពីទីកន្លែង[34] ។

ការបញ្ជូនដោយប្រគល់ត្រូវបានបែងចែកជា ៣ គឺការបញ្ជូនដោយជួបប្រទះ ការបញ្ជូនដោយបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោល ។

---

[31] មាត្រា ២៤៦ កថាខណ្ឌទី ២ ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[32] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៤៧ កថាខណ្ឌទី

[33] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៤, ៣៥

[34] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥០

### ១.១.១. ការបញ្ជូនដោយជួបប្រទះ

ការបញ្ជូនដោយជួបប្រទះ ជាការប្រគល់នូវឯកសារដែលត្រូវធ្វើការបញ្ជូននោះ ទៅអ្នកដែលត្រូវទទួលការបញ្ជូននៅទីកន្លែងដែលជួបប្រទះជននោះ ។ ជាគោលការណ៍ ការបញ្ជូនត្រូវធ្វើឡើងនៅទីកន្លែងដែលបានជូនដំណឹង ប៉ុន្តែប្រសិនបើជនដែលត្រូវទទួលការបញ្ជូននោះពុំច្បាស់លាស់ថាមានលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ការបញ្ជូនអាចធ្វើបាននៅទីកន្លែងដែលបានជួបប្រទះជននោះ ។ ការបញ្ជូនដោយជួបប្រទះនេះអាចធ្វើទៅបានក្នុងករណីដែលជននោះមិនបានប្រកែកទទួលការបញ្ជូននោះ[35] ។

### ១.១.២. ការបញ្ជូនដោយបង្គ្រប់កិច្ច

ការបញ្ជូនដោយបង្គ្រប់កិច្ច ជាការបញ្ជូនដោយប្រគល់នូវឯកសារ ដែលត្រូវធ្វើការបញ្ជូនទៅជនដ៏ទៃទៀតផ្សេងពីអ្នកដែលត្រូវទទួលការបញ្ជូន នៅកន្លែងដែលត្រូវទទួលការបញ្ជូននោះ ។ មានន័យថា ក្នុងករណី ដែលមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូននៅទីកន្លែងដែលត្រូវធ្វើការបញ្ជូនទេ នោះមន្ត្រីប្រតិបត្តិកិច្ចការបញ្ជូនអាចប្រគល់ឯកសារដែលត្រូវធ្វើការបញ្ជូនទៅអ្នកបម្រើ ឬអ្នកផ្សេងទៀតដែលធ្វើការនៅទីនោះ ឬអ្នកដែលនៅជាមួយដែលមានការយល់ដឹងសមរម្យក្នុងការទទួលការប្រគល់ឯកសារនោះបាន[36] ។ អ្នកដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារ គឺជាអ្នកដែលអាចយល់ដឹងច្បាស់អំពីសារៈសំខាន់នៃការបញ្ជូន និងអត្ថន័យនៃឯកសារដែលបានទទួល ហើយមានសមត្ថភាពអាចយកឯកសារនោះទៅប្រគល់ឱ្យជនដែលត្រូវទទួលការបញ្ជូននោះ ។

### ១.១.៣. ការបញ្ជូនដោយទុកចោល

ការបញ្ជូនដោយទុកចោល ជាការបញ្ជូដោយទុកឯកសារដែលត្រូវធ្វើការបញ្ជូននៅកន្លែងបញ្ជូននោះ ។ ប្រសិនបើ ជនដែលត្រូវទទួលការបញ្ជូន ឬអ្នកបម្រើ ឬអ្នកផ្សេងដែលធ្វើការនៅទីនោះ ឬអ្នកដែលនៅជាមួយដែលមានការយល់ដឹងសមរម្យបានប្រកែកមិនព្រមទទួលការបញ្ជូនដោយគ្មានមូលហេតុត្រឹមត្រូវមន្ត្រីប្រតិបត្តិកិច្ចការបញ្ជូនអាចទុកឯកសារនោះនៅកន្លែង ដែលត្រូវបញ្ជូននោះបាន[37] ។

### ១. ២. ការបញ្ជូនទៅបរទេស

ករណីជនដែលត្រូវទទួលការបញ្ជូនមានទីលំនៅនៅបរទេស ហើយពុំមានទីសំណាក់ ឬទីកន្លែងអាជីវកម្ម ឬទីស្នាក់ការដែលអាចបញ្ជូនបាននៅក្នុងប្រទេសកម្ពុជាទេ ការបញ្ជូនអាចធ្វើបានតាមវិធី ៖

[35] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/0៧0៦/0២១, 0៦ កក្កដា ២00៦, មាត្រា២៥១

[36] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/0៧0៦/0២១, 0៦ កក្កដា ២00៦, មាត្រា២៥២ កថាខណ្ឌទី១

[37] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/0៧0៦/0២១, 0៦ កក្កដា ២00៦, មាត្រា២៥២ កថាខណ្ឌទី២

- ករណីជនដែលត្រូវទទួលការបញ្ជូនជាជនជាតិបរទេស គប្បីបញ្ជូនដោយប្រគល់ឱ្យទៅក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនៃប្រទេសនោះជាអ្នកអនុវត្តការបញ្ជូន ។
- ករណីជនដែលត្រូវទទួលការបញ្ជូនជាជនជាតិខ្មែរ តែរស់នៅបរទេសគប្បីបញ្ជូនដោយប្រគល់ឱ្យឯកអគ្គរាជទូត ភារធារី ឬកុងស៊ុលរបស់ប្រទេសកម្ពុជាប្រចាំប្រទេសនោះជាអ្នកអនុវត្តការបញ្ជូន ។

មុននឹងបញ្ជូនតុលាការគប្បីមើល សន្ធិសញ្ញា ឬអនុសញ្ញា ឬកិច្ចព្រមព្រៀងផ្សេងៗទៀតរវាងប្រទេសនោះ និងប្រទេសកម្ពុជាអំពីការជួយគ្នាផ្នែកច្បាប់ជាមុនសិន ព្រោះករណីខ្លះក្នុងលិខិតតូបករណ៍អន្តរជាតិទាំងនោះមានចែងអំពីនីតិវិធីនៃការបញ្ជូន [38] ។

### ១. ៣. ការបញ្ជូនតាមការផ្សាយជាសាធារណៈ

ការបញ្ជូនតាមការផ្សាយជាសាធារណៈ អាចធ្វើឡើងដោយការបិទប្រកាសនៅកន្លែងបិទប្រកាសរបស់តុលាការ ឬកន្លែងដែលតុលាការទទួលស្គាល់ថាសមស្រប អាជាប៉ុស្តិ៍ សាលាឃុំ ឬសាលាសង្កាត់ជាដើម ។ ដែលត្រូវប្រកាសថាក្រឡាបញ្ជីជាអ្នករក្សាទុកនូវឯកសារ ដែលត្រូវធ្វើការបញ្ជូន ហើយអាចប្រគល់ឱ្យជនដែលត្រូវទទួលការបញ្ជូននោះនៅពេលណាក៏បាន ( ក្នុងម៉ោងធ្វើការ ) ។

#### ១.៣.១. លក្ខខ័ណ្ឌនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ

ដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបានលុះត្រាតែមានលក្ខខ័ណ្ឌដូចខាងក្រោម[39]៖

- ទោះបីប្រឹងប្រែងស្រាវជ្រាវរកលំនៅឋាន ឬទីសំណាក់របស់ភាគី ឬទីកន្លែងផ្សេងទៀតយ៉ាងណាក៏មិនអាចរកឃើញ ។
- ដឹងពីទីកន្លែងដែលត្រូវបញ្ជូន ប៉ុន្តែការបញ្ជូនមិនអាចធ្វើបានទោះជាព្យាយាមបញ្ជូនតាមរបៀបនៃការបញ្ជូនដោយបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោលក៏ដោយ ។
- តុលាការមិនអាចធ្វើការបញ្ជូនទៅបរទេសដោយប្រគល់កិច្ចការបញ្ជូននោះ ។
- តុលាការមិនបានទទួលលិខិតបញ្ជាក់ ពីការបញ្ជូនពីក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ច នៅបរទេសក្នុងអំឡុងពេល ៦ខែ ចាប់ពីពេលបញ្ជូននោះ ។
- មានពាក្យសុំពីភាគី ដែលស្នើសុំឱ្យតុលាការធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ ហើយត្រូវបានតុលាការអនុញ្ញាត ។ ប៉ុន្តែ ដើម្បីជៀសវាងការយឺតយ៉ាវតុលាការក៏អាចបង្គាប់ឱ្យក្រឡាបញ្ជីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈដោយឆន្ទានុសិទ្ធិបាន ទោះបីជាគ្មានពាក្យសុំក៏ដោយ ។

---

[38] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥៣

[39] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥៥

ចំពោះការបញ្ជូនជាលើកទី២ តាមការផ្សាយជាសាធារណៈទៅភាគីដដែល ត្រូវធ្វើឡើងដោយឆន្ទានុសិទ្ធិ[40] ។ មានន័យថា ប្រសិនបើធ្លាប់បានបញ្ជូនទៅភាគីណាមួយតាមការបញ្ជូនតាមការផ្សាយជាសាធារណៈ នោះការបញ្ជូនលើកក្រោយៗទៀតតុលាការអាចសម្រេចធ្វើការបញ្ជូនតាម វិធីផ្សាយជាសាធារណៈដោយឆន្ទានុសិទ្ធិ ។ ប៉ុន្តែ ចំពោះការបញ្ជូនទៅបរទេសត្រូវតែមានពាក្យសុំរបស់ភាគីរាល់លើកនៃការផ្សាយជាសារធារណៈ ។

## ១.៣.២ . របៀបបញ្ជូនតាមការផ្សាយជាសាធារណៈ

ការបញ្ជូនតាមការផ្សាយជាសាធារណៈត្រូវធ្វើឡើងតាមវិធីដូចតទៅ [41] ៖

- ក្រឡាបញ្ជីត្រូវបិទប្រកាសនៅកន្លែងបិទប្រកាសរបស់តុលាការ ឬកន្លែងដែលតុលាការទទួលស្គាល់ថាសមរម្យ ត្រូវប្រកាសថា ក្រឡាបញ្ជីរក្សាទុកនូវឯកសារដែលត្រូវធ្វើការបញ្ជូន និងអាចប្រគល់ឱ្យជនដែលត្រូវទទួលការបញ្ជូននោះនៅពេលណាក៏បាន ។
- ចំពោះការបញ្ជូនដីកាកោះ ត្រូវបិទដីកាកោះនោះនៅកន្លែងសម្រាប់បិទប្រកាសតែម្តង ។
- តុលាការអាចចុះក្នុងរាជកិច្ច ឬក្នុងសារព័ត៌មានដោយផ្សាយថា បានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ ។
- ចំពោះការបញ្ជូតាមការផ្សាយជាសាធារណៈដែលត្រូវធ្វើនៅបរទេស ក្រឡាបញ្ជីមិនចាំបាច់ផ្សាយក្នុងរាជកិច្ច ឬសារព័ត៌មានក៏បាន ដោយគ្រាន់តែជូនដំណឹងថាបានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈរួចហើយ ។

## ១.៣.៣ . អានុភាពនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ

ការបញ្ជូនតាមការផ្សាយជាសាធារណៈនឹងមានអានុភាពនៅក្រោយអំឡុងពេល ២សប្តាហ៍ ដោយគិតចាប់ពីថ្ងៃ ដែលបានបានបិទប្រកាសនោះ ។ ក៏ប៉ុន្តែ ការបញ្ជូនតាមការផ្សាយជាសាធារណៈជាលើកទី២ នឹងមានអានុភាពនៅថ្ងៃបន្ទាប់នៃថ្ងៃបិទប្រកាសនោះ ។ អានុភាពនៅទីនេះ មានន័យថា ការបញ្ជូនមានសុពលភាព ហើយត្រូវចាត់ទុកថាអ្នកដែលត្រូវទទួលការបញ្ជូនបានទទួលការបញ្ជូននោះ ។ ចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈដែលត្រូវធ្វើនៅបរទេសនឹងមានអានុភាពជាការបញ្ជូននៅក្រោយអំឡុងពេល ៦សប្តាហ៍បន្ទាប់ពីថ្ងៃបិទប្រកាស[42] ។

[40] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥៥ កថាខណ្ឌទី៤

[41] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥៦

[42] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥៧

## ២ . របាយការណ៍នៃការបញ្ជូន

នៅក្រោយពេលដែលបានប្រតិបត្តិកិច្ចការបញ្ជូនត្រឹមត្រូវតាមនីតិវិធីរួចរាល់ហើយ មន្ត្រីប្រតិបត្តិការបញ្ជូនត្រូវធ្វើរបាយការណ៍អំពីការបញ្ជូននោះ ហើយផ្ញើទៅតុលាការដើម ។ របាយការណ៍នៃការបញ្ជូនត្រូវតែសរសេរនូវចំណុចដូចជា[43] ៖

- សញ្ញាណនៃរឿងក្តី និងឯកសារដែលបានធ្វើការបញ្ជូន : ត្រូវសរសេរអំពីឈ្មោះសំណុំរឿង លេខ និងកាលបរិច្ឆេទដែលបានចុះ ហើយក៏ត្រូវសរសេរវាយឈ្មោះឯកសារដែលបានធ្វើការបញ្ជូននោះផងដែរ ។
- ឈ្មោះជនដែលត្រូវទទួលការបញ្ជូន : ដោយហេតុថាឯកសារនៃការបញ្ជូនត្រូវធ្វើទៅចំពោះបុគ្គលណាមួយច្បាស់លាស់ហេតុនេះហើយ ត្រូវសរសេរចង្អុលបង្ហាញឱ្យចំឈ្មោះអ្នកដែលត្រូវទទួលការបញ្ជូននោះ ។
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងដែលបានធ្វើការបញ្ជូន ។
- វិធីនៃការបញ្ជូន : នៅក្រោយពេលដែលបានធ្វើការបញ្ជូនមន្ត្រីប្រតិបត្តិការបញ្ជូនត្រូវសរសេរចង្អុលប្រាប់ពីវិធីដែលខ្លួនបានបញ្ជូនតាមវិធីដូចជា បញ្ជូនដោយជួបប្រទះ ឬប្រគល់ជាដើម ។
- ចំណាត់ការរបស់មន្ត្រីប្រតិបត្តិការបញ្ជូន ក្នុងករណីដែលជនដែលត្រូវទទួលការបញ្ជូនមិនចេះអក្សរ : ត្រូវសរសេរបញ្ជាក់ថា ខ្លួនបានអានឱ្យជននោះស្តាប់ និងបានពន្យល់ ។
- ហត្ថលេខា ឬស្នាមមេដៃរបស់របស់អ្នកដែលបានទទួលឯកសារ : ការធ្វើបែបនេះ គឺដើម្បីបង្ការការប្រកែកថាខ្លួនមិនបានទទួលឯកសារដែលនាំឱ្យបាត់បង់ឯកសារ ហើយក៏ជាការបញ្ជាក់អំពីភាពត្រឹមត្រូវនៃការបញ្ជូនផងដែរ ។
- ហេតុការណ៍ដែលមិនព្រមទទួលការបញ្ជូន ជនដែលត្រូវទទទួលការបញ្ជូន ឬអ្នកដែលត្រូវទទួលការប្រគល់ឯកសារបញ្ជូនដោយបង្គ្រប់កិច្ច ប្រកែកមិនព្រមទទួល : ក្នុងករណីដែលជនដែលត្រូវទទទួលការបញ្ជូន ឬអ្នកដែលត្រូវទទួលការប្រគល់ឯកសារបញ្ជូនដោយ បង្គ្រប់កិច្ចប្រកែកមិនព្រមទទួលត្រូវសរសេរអំពីមូលហេតុនៃការប្រកែកនោះ ។
- ហេតុការណ៍ នៅក្នុងករណីដែលបានធ្វើការបញ្ជូនដោយបង្គ្រប់កិច្ច ឬបញ្ជូនដោយទុកចោល : ត្រូវសរសេរអំពីមូលហេតុដែលធ្វើការបញ្ជូនតាមការបញ្ជូនដោយបង្គ្រប់កិច្ច ឬការបញ្ជូនដោយទុកចោល ។
- ហត្ថលេខារបស់អ្នកដែលបានប្រតិបត្តិការបញ្ជូន ។

ក្នុងករណីដែលបានព្យាយាមធ្វើការបញ្ជូនតែមិនអាចសម្រេចបាន មន្ត្រីទទួលបន្ទុកការបញ្ជូនត្រូវធ្វើរបាយការណ៍អំពីហេតុការណ៍នោះ និងសរសេរអំពីវិធីនៃការបញ្ជូន និងចុះហត្ថលេខារបស់អ្នកដែលបានប្រតិបត្តិការបញ្ជូន ហើយដាក់ជូនទៅតុលាការ ។

[43] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៥៤

## ផ្នែកទី ២ ៖ ការជ្រើសរើសនីតិវិធី និង ការវិនិច្ឆ័យក្ដី នៃរឿងក្ដីចំនួនទឹកប្រាក់តិច

ដូចដែលបានអធិប្បាយខាងលើហើយថា នីតិវិធីរឿងក្ដីចំនួនទឹកប្រាក់តិចជានីតិវិធីដែលមានលក្ខណៈពិសេសចាប់តាំងពីដាក់ពាក្យបណ្ដឹង ឥឡូវក៏មានការផ្ដល់សិទ្ធិទៅដល់ភាគីនៅក្នុងការជ្រើសយកនូវនីតិវិធី ( កថាខ័ណ្ឌទី ១ ) និងការវិនិច្ឆ័យនូវរឿងក្ដីចំនួនទឹកប្រាក់តិច ( កថាខ័ណ្ឌទី ២ ) ។

### កថាខ័ណ្ឌទី ១ ៖ ការកំណត់នីតិវិធីរឿងក្ដីចំនួនទឹកប្រាក់តិច

នៅក្នុងនីតិវិធីរឿងក្ដីចំនួនទឹកប្រាក់តិច គឺបានផ្ដល់នូវសិទ្ធិចំពោះភាគីដើមចោទ និងចុងចម្លើយនៅក្នុងការកំណត់យកនីតិវិធីបណ្ដឹងធម្មតា ឬមួយក៏យកនីតិវិធីរឿងក្ដីចំនួនទឹកប្រាក់តិចមកអនុវត្តនៅក្នុងវិវាទរបស់ខ្លួន លើសពីនេះទៅទៀត តុលាការក៏មានឆន្ទានុសិទ្ធិនៅក្នុងការកំណត់នីតិវិធីនេះបានផងដែរ ។

**១.ការកំណត់នីតិវិធីដោយដើមចោទ**

ចំពោះបណ្ដឹងទាមទារប្រាក់ ដែលមានតម្លៃមិនលើសពី១.០០០.០០០ រៀល នៅពេលដាក់ពាក្យបណ្ដឹង ដើមចោទមានសិទ្ធិជ្រើសរើសបាន ដោយសេរីនូវការទាមទារឱ្យធ្វើការវិនិច្ឆ័យ និងសម្រេចសេចក្ដី ដោយដោះស្រាយតាមនីតិវិធីនៃបណ្ដឹងរឿងក្ដីចំនួនទឹកប្រាក់ ឬទាមទារឱ្យធ្វើការវិនិច្ឆ័យនិងចេញសាលក្រមដោយប្រើប្រាស់តាមនីតិវិធីចណ្ដឹងធម្មតា ។ នេះបើតាម មាត្រា ២២៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដើមចោទ " **អាច** " ស្នើសុំការជំនុំជម្រះ និងសម្រេចសេចក្ដីតាមនីតិវិធីរឿងក្ដីចំនួនទឹកប្រាក់តិចបាន ។ ពាក្យ " **អាច** " គឺវាមិនមែនមានន័យថាត្រូវតែធ្វើដាច់ខាតដូចពាក្យ " **ត្រូវតែ** " នោះទេ ។ នៅពេលខ្លះទោះបីកម្មវត្ថុ នៃបណ្ដឹងស្ថិតនៅក្នុងប្រភេទនៃរឿងក្ដីចំនួនទឹកប្រាក់តិចក៏ដោយ ប៉ុន្ដែ បើដើមចោទមានបំណងចង់ឱ្យតុលាការវិនិច្ឆ័យដោយមានភាពប្រុងប្រយ័ត្ន ដើមចោទអាចស្នើសុំទៅតុលាការឱ្យដោះស្រាយបណ្ដឹង ដោយប្រើតាមនីតិវិធីធម្មតាបាន ដែលបញ្ហានេះជាសិទ្ធិរបស់ដើមចោទ ( នេះគឺជាគោលការណ៍ នៃសិទ្ធិចាត់ចែង ) នៅក្នុងការសម្រេចយកជម្រើសណាមួយក៏បាន ។

ក្នុងករណីដើចោទ មានបំណងឱ្យតុលាការធ្វើការដោះស្រាយវិវាទរបស់ខ្លួនតាមនីតិវិធីរឿងក្ដីចំនួនទឹកប្រាក់តិច នោះដើមចោទត្រូវធ្វើសេចក្ដីថ្លែងការណ៍ដើម្បីបញ្ជាក់ពីការស្នើសុំនេះនៅពេលដាក់ពាក្យបណ្ដឹងតែម្ដង ។ [44] ហើយច្បាប់បានផ្ដល់សិទ្ធិជាអទិភាពទៅដល់ដើមចោទនៅក្នុងការជ្រើសរើសយកនីតិវិធីក្នុងការវិនិច្ឆ័យទៅលើបណ្ដឹងរបស់ខ្លួន ។

[44] មាត្រា ២២៤ កថាខណ្ឌទី ២ ក្រមនីតិវិធីរដ្ឋប្បវេណី

## ២. ការកំណត់នីតិវិធីដោយចុងចម្លើយ

ដូចដែលបានរៀបរាប់នៅខាងលើ បើច្បាប់បានធ្វើការអនុញ្ញាតឱ្យដើមចោទ មានសិទ្ធិធ្វើការជ្រើសរើសនីតិវិធីបណ្តឹងធម្មតាបាន នោះច្បាប់គួរអនុញ្ញាតអោយចុងចម្លើយអាចជ្រើសរើសដូចគ្នា គឺដើម្បីអោយមានសមភាពរវាភាគីទាំងសងខាង ។

នៅក្រោយពេលដែលដើមចោទបានដាក់ពាក្យបណ្តឹងរួចហើយនោះ គឺពាក្យបណ្តឹងត្រូវបញ្ជូនទៅចុងចម្លើយជាចាំបាច់ ។[45] ហើយបើក្រោយមក ចុងចម្លើយមាន បំណងចង់ឱ្យតុលាការធ្វើការវិនិច្ឆ័យ និងធ្វើការសម្រេចសេចក្តីតាមនីតិវិធីបណ្តឹងធម្មតាដោយហេតុថា រឿងនេះជាប្រភេទរឿងដែលមានលក្ខណៈហាក់ដូចជាមានភាពស្មុគស្មាញ នោះចុងចម្លើយអាចធ្វើសេចក្តីថ្លែងការណ៍ឱ្យតុលាការធ្វើការផ្ទេរបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ទៅនីតិវិធីបណ្តឹងធម្មតាបាន ។[46] សេចក្តីថ្លែងការណ៍នេះ គឺត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ លើកលែងតែករណីដែលធ្វើនៅក្នុងកាលបរិច្ឆេទ ។ បន្ទាប់ពី ចុងចម្លើយបានធ្វើសេចក្តីថ្លែការណ៍ផ្ទេរបណ្តឹងពីប្រភេទរឿក្តីចំនួនទឹកប្រាក់តិច មកជាបណ្តឹងនៃនីវិធីបណ្តឹងធម្មតានោះ ក្រឡាបញ្ជី ត្រូវធ្វើការជូនតំណឹងនេះទៅដើមចោទភ្លាម អំពីការផ្ទេរនូវបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ទៅនីតិវីធីបណ្តឹងធម្មតាវិញ ដោយសេចក្តីថ្លែងការណ៍នេះ ។ តែបើចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍នៅកាលបរិច្ឆេទ ដែលដើមចោទបានបង្ហាញខ្លួន នោះមិនចាំបាច់ធ្វើការជូនដំណឹងទៅដើមចោទទេ ។ [47] ហើយនៅក្នុងករណីការផ្ទេរបណ្តឹងពីរនីតិវីធីរឿងក្តីចំនួនទឹកប្រាក់តិច ទៅនីតិវិធីបណ្តឹងធម្មតា តុលាការមិនចាំបាច់ចេញដីកាសម្រេចទើបបណ្តឹងមានការប្រែប្រួលនោះទេ ព្រោះដោយផ្អែកទៅលើស្មារតីដែលមានចែងនៅក្នុង មាត្រា ២៣៣ ពុំបានទាមទារឱ្យតុលាការត្រូវធ្វើការចេញដីកាសម្រេចនោះទេ ។ ការផ្តល់សិទ្ធិឱ្យចុងចម្លើយ ក្នុងការធ្វើសេចក្តីថ្លែងការណ៍ផ្ទេរបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ទៅនីតិវិធីធម្មតានោះ នឹងត្រូវបាត់បង់សិទ្ធិរបស់ខ្លួនឯងទៅវិញ នៅពេលដែលចុងចម្លើយបាន ឆ្លើយទាញហេតុផលនៅកាលបរិច្ឆេទដំបូងសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ។

## ៣. ការកំណត់នីតិវិធីដោយតុលាការ

តុលាការជាស្ថាប័នមានអំណាចនៅក្នុងការវិនិច្ឆ័យទៅលើរឿងក្តី នោះតុលាការ ក៍មានសិទ្ធិនៅក្នុងការកំណត់យក នីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច ឬមួយនីតិវិធីធម្មតា បើតុលាការ យល់ឃើញថាលក្ខខ័ណ្ឌណាមួយខាងក្រោមត្រូវបានបំពេញ ៖

[45] មាត្រា ៧៩ កថាខណ្ឌទី ១ នៃក្រមនីតិវីធីរដ្ឋប្បវេណី
[46] មាត្រា ២៣៣ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្បវេណី
[47] មាត្រា ២៣៣ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

១ : ពេលដែលដើមចោទបានស្នើសុំឱ្យជំនុំជម្រះ និងសម្រេចសេចក្តីតាមនីតិវិធីនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ដោយផ្ទុយពីបញ្ញត្តិនៃកថាខ័ណ្ឌទី១ នៃមាត្រា ២២៤ ( ល័ក្ខខ័ណ្ឌនៃរឿងក្តីចំនួនទឹកប្រាក់តិចជាអាទិ៍ ) ។

២ : នៅពេលដែលតុលារមិនអាចកោះហៅចុងចម្លើយ តាមកាលបរិច្ឆេទដំបូងសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ប្រសិនបើ ការកោះហៅនោះពុំធ្វើដោយការបញ្ជូនតាមការផ្សាយជាសារធារណៈ ។

៣ : នៅពេលដែលតុលាការយល់ឃើញថា ការជំនុំជម្រះ និងការសម្រេចសេចក្តីតាមនីតិវិធីនៃរឿងក្តីចំនួនទឹកប្រាក់តិចនោះមិនសមរម្យ ។ នៅក្នុងករណីមានការបំពេញលក្ខខ័ណ្ឌណាមួយខាងលើហើយនោះ តុលាការត្រូវចេញដីកាសម្រេចថា ការជំនុំជម្រះ និងសម្រេចសេចក្តីលើបណ្តឹងនោះ ត្រូវធ្វើតាមនីតិវិធីធម្មតា ។ ម្យ៉ាងទៀត ក្រឡាបញ្ជីត្រូវធ្វើការជូនដំណឹងអំពីហេតុការណ៍នេះទៅភាគីភ្លាមៗ ។[48]

### ៤ . អានុភាពនៃការផ្ទេរទៅនីតិវិធីបណ្តឹងធម្មតា

នៅក្រោយពេលដែលមានសេចក្តីថ្លែងការណ៍ដែលបានកំណត់នៅក្នុង កថាខ័ណ្ឌទី១ នៃមាត្រា ២៣៣ ( ការផ្ទេរបណ្តឹងទៅនីតិវិធីធម្មតា ដោយសេចក្តីថ្លែងការណ៍របស់ចុងចម្លើយ ) ឬ ដីកាសម្រេចដែលបានកំណត់នៅក្នុង កថាខ័ណ្ឌទី ១ នៃមាត្រា ២៣៤ ( ការផ្ទេរបណ្តឹងទៅនីតិវិធីធម្មតាដោយដីកាសម្រេចរបស់តុលាការ ) នៃក្រមនេះ នោះបណ្តឹងនិងផ្ទេរទៅនីតិវិធីធម្មតា ។ ហើយនៅពេលដែលបណ្តឹងត្រូវបានផ្ទេរទៅនីតិវិធីធម្មតា នោះកាលបរិច្ឆេទដែលបានកំណត់រួចហើយសម្រាប់បណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ត្រូវបានចាត់ទុកថា បានកំណត់សម្រាប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នៃនីតិវិធីធម្មតាវិញ ។[49]

## កថាខ័ណ្ឌទី២ ៖ ការជំនុំជម្រះទៅលើនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច

នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ចំពោះនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិចវា ក៏មិនមានភាពខុសគ្នាប៉ុន្មានទៅ និង នីតិវិធីធម្មតាដែរ គឺដំបូងភាគីដាក់ពាក្យបណ្តឹងដើម្បីឱ្យតុលាការធ្វើការវិនិច្ឆ័យ និងចេញសាលក្រម ។ យើងអាចនិយាយម្យ៉ាងទៀតបានថា ដើម្បីអាចចេញសាលក្រមទៅលើបណ្តឹងបាន តុលាការចាំបាច់ត្រូវឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់ ។[50] តែបើ

[48] មាត្រា ២៣៤ នៃក្រមនីតិវិធីរដ្ឋវេណី
[49] មាត្រា ២៣៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី
[50] មាត្រា ១១៤ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

តុលាការមិនបានឆ្លងកាត់ការទាញហេតុដោយផ្ទាល់មាត់ទេ នោះតុលាការមិនអាចចេញសាលក្រមបាននោះទេ ( តែមានបញ្ញត្តិលើកលែងមួយចំនួនផងដែរ ) ។

ហើយនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច កាលបើនៅពេលដែលមានការដាក់ពាក្យបណ្តឹង តុលាការត្រូវកំណត់កាលបរិច្ឆេទសម្រាប់ការទាញហេតុ ផលដោយផ្ទាល់មាត់ ឱ្យបានឆាប់រហ័ស និងត្រូវកោះហៅគូរភាគី ( ដូចដែលបានរៀបរាប់ខាងលើ ) ។ កាលវិច្ឆេទ ដែលបានកំណត់នេះត្រូវធ្វើនៅក្នុងអំឡុងពេល ៣០ (សាមសិប ) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានដាក់ពាក្យបណ្តឹង លើកលែងតែមានសភាពការណ៍ពិសេស ។[51]

ចំពោះរឿងក្តីចំនួនទឹកប្រាក់តិច តុលាការត្រូវធ្វើការជំនុំជម្រះនៅកាលបរិច្ឆេទដំបូងសម្រាប់ការទាញហេតុផលផ្ទាល់មាត់លើកទី១ និងតុលាការត្រូវធ្វើការបញ្ចប់នូវការជំនុំជម្រះនេះ លើកលែងតែមានសភាពការណ៍ពិសេស ។[52] សភាពការណ៍ពិសេសនេះមានជាអាទិ៍ អវត្តមានរបស់ភាគីដោយសារមូលហេតុ មានជម្ងឺ ឬ គ្រោះថ្នាក់ផ្សេងៗ ទើបនាំឱ្យភាគី អវត្តមាន ហើយកាលបើភាគីអវត្តមាននោះមានភាពមិនសុខចិត្ត ចំពោះសាលក្រមដែរសម្រេចនោះ ភាគីនោះអាចដាក់ពាក្យបណ្តឹងទាស់បាន ។ សាលក្រមដែលចេញដោយពុំមានវត្តមានរបស់ ភាគីម្ខាងទៀតនៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់នោះ គឺជាសាលក្រមកំបាំងមុខ ហើយនៅក្នុងនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច គឺបានបើកសិទ្ធិឱ្យធ្វើ បណ្តឹងទាស់ ។[53]

ម្យ៉ាងទៀត ភាគីត្រូវដាក់មធ្យោបាយតទល់ ( គឺជាសេចក្តីថ្លែងការណ៍ ដែលអះអាងអំពីសិទ្ធិដាក់ដោយដើមចោទ ) ឬ មធ្យោបាយការពារ ( គឺជាសេចក្តីថ្លែងការណ៍ដែលអះអាង តបចំពោះមូលហេតុនៃការទាមទាររបស់ដើមចោទ ) ទាំងអស់របស់ខ្លួននៅមុន ឬ នៅក្នុងកាលបរិច្ឆេទដែលបានកំណត់លើកដំបូងសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់ ។ ប៉ុន្តែ មធ្យោបាយតទល់ និង មធ្យោបាយការពារ ក៏ អាចត្រូវបានដាក់បន្ថែមទៀតបានផងដែរ ចំពោះករណីដែរការទាញហេតុផលដោយផ្ទាល់មាត់ត្រូវបានបន្ត ។[54]

ទោះបីជាភាគីមានអ្នកតំណាងដោយអាណត្តិ ក៏ដោយ ( ទោះជាមេធាវី ឬ មិនមែនជាមេធាវី ) ក៏តុលាការអាចបង្គាប់ឱ្យសមីភាគី ឬ អ្នកតំណាងដែលច្បាប់បានកំណត់ របស់ភាគីនោះ បង្ហាញខ្លួនបានដែរ ។[55]

[51] មាត្រា ២២៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី
[52] មាត្រា ២២៩ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី
[53] មាត្រា ២៣៨ វគ្គក្យខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី
[54] មាត្រា ២២៩ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី
[55] មាត្រា ២៣០ នៃក្រមនីតិវិធីរដ្ឋប្បវេណី

នៅក្នុងវិនិច្ឆ័យទៅលើរឿងក្តីចំនួនទឹកប្រាក់តិច តុលាការត្រូវវិនិច្ឆ័យទទួលស្គាល់ ឬមិនទទួលស្គាល់ថាការអះអាងអំពីអង្គហេតុមាន ឬ គ្មានភាពពិត ដោយគិតពិចារណាយ៉ាងហ្មត់ចត់នូវលទ្ធផលនៃការពិនិត្យ ភស្តុតាង និងដំណើការនិងខ្លឹមសារនៃការទាញហេតុផលដោយផ្ទាល់មាត់ ។ ហើយនៅក្នុងនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិចនេះ ការពិនិត្យភស្តុតាង អាចធ្វើបានចំពោះតែភស្តុតាងដែលអាចពិនិត្យបានភ្លាមៗ តែប៉ុណ្ណោះ ។ [56] ឬ យើងអាចនិយាយម្យ៉ាងទៀតថា ការពិនិត្យភស្តុតាងអាចធ្វើបានតាមរបៀបជាសេចក្តីបញ្ជាក់ដំបូង ។

ភស្តុតាងអាចមាន ភស្តុតាងជាឯកសារ ឬភស្តុតាងជាសាក្សី តែបើភស្តុតាងជាសាក្សី ភាគីមិនចាំបាច់ដាក់ឯកសារដែរកំណត់អំពីចំណុចដែលត្រូវសួរឡើយ នៅពេលដែលភាគីបានស្នើសុំសាកសួរសាក្សី ។ ហើយការសាកសួរសាក្សីនេះ តុលាការសួរដោយមិនចាំបាច់ឱ្យធ្វើសម្បថឡើយ ។ [57]

## កថាខ័ណ្ឌទី ៣ ៖ លក្ខណៈពិសេសនៃរឿងក្តីចំនួនទឹកប្រាក់តិច

ដូចដែលបានរៀបរាប់ខាងលើហើយថា នីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច គឺជានីតិវិធីពិសេសដែលមានលក្ខណៈខុសប្លែក ពីនីតិវិធីលើអង្គសេចក្តីធម្មតានៅត្រង់ថា ៖

### ១ . មិនមានធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល

ជាគោលការណ៍ចំពោះនីតិវិធីលើអង្គសេចក្តីធម្មតា តុលាការមុននិងធ្វើការទាញហេតុផលផ្ទាល់មាត់ នៅក្នុងគោលបំណងឈានដល់ការចេញសាលក្រមនោះ តុលាការគឺត្រូវធ្វើនីតិវិធី ត្រៀមសម្រាប់ការទាញហេតុផល ព្រោះគោលបំណងនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺតុលាការត្រូវរៀបចំនូវសេចក្តីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូរភាគីយល់មិនស្របគ្នា និងរៀបចំភស្តុតាងដែលទាក់ទងនិងចំណុចវិវាទនៃរឿងក្តី ។ ការធ្វើបែបនេះវាជួយសម្រួលទៅដល់គូភាគី និងតុលាការ អោយមានភាពងាយស្រួលនៅក្នុងវិនិច្ឆ័យសេចក្តី ។ តែការធ្វើនីតិវិធីត្រៀមបែបនេះ វានាំឱ្យការចំណាយពេលវេលា និង មានការខាតបង់ច្រើន ហេតុដូច្នេះហើយវាផ្ទុយទៅនឹងគោលបំណងនៃរឿងក្តីចំនួនទឹកប្រាក់តិច ដែលចង់ឱ្យមានការដោះស្រាយវិវាទដ៏ឆាប់រហ័សតាមនីតិវិធីសង្ខេប ។

ហេតុដូច្នេះហើយ ទើបបានជានៅក្នុងនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច មិនយកមកអនុវត្តនូវនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ។ [58]

[56] មាត្រា ២៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[57] មាត្រា ២៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[58] មាត្រា ២៣៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី

## ២ . មិនមានធ្វើនីតិវិធីផ្សះផ្សា

ការផ្សះផ្សា គឺធ្វើឡើងដោយតុលាការ ដែលតុលាការដើរតួរជាអន្តរការីនៅក្នុងការបញ្ចុះបញ្ចូលឱ្យភាគីមានគំនិត នៅការសះជានិងគ្នា ឬ ភាគីអាចមានការដកពាក្យបណ្តឹងទៅវិញ ។ ហើយជាធម្មតា នីតិវិធីផ្សះផ្សានេះ ច្រើនតែធ្វើនៅក្នុង នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ប៉ុណ្ណោះ យ៉ាងណាមិញ បើយើងធ្វើការបកស្រាយត្រឡប់នោះ បើក្នុងករណីមិនអាចធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលបានផងនោះ នីតិវិធីផ្សះផ្សា ក៏មិនអាចកើតមានបានផងដែរ ។

## ៣ . ការទាញហេតុផលដោយផ្ទាល់មាត់ធ្វើតែមួយថ្ងៃ

ការទាញហេតុផលដោយផ្ទាល់មាត់ធ្វើតែមួយថ្ងៃ គឺវាមានន័យថាធ្វើការទាញហេតុផលតែមួយលើក ហើយបើយើងធ្វើការសិក្សា ទៅលើនីតិវិធីបណ្តឹងធម្មតាវិញនោះ គឺបើយល់ឃើញថាបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់រួចហើយនោះ តុលាការនិងរៀបចំក្នុងការចេញសាលក្រមចុងក្រោយ តែបើយល់ឃើញថាមានការចាំបាច់ដើម្បីចេញសាលក្រមចុងក្រោយ តុលាការអាចបង្គាប់ឱ្យធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដែរត្រូវបានបញ្ចប់ហើយនោះ សារជាថ្មីឡើងវិញបាន ។ ហេតុដូច្នេះ ចំពោះនីតិវិធីបណ្តឹងធម្មតាការទាញហេតុផលដោយផ្ទាល់មាត់អាចធ្វើបានច្រើនលើក ។

តែដោយឡែក ចំពោះនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិចវិញ តុលាការត្រូវតែបញ្ចប់នូវការ ជំនុំជម្រះ នៅកាលបរិច្ឆេទដំបូងសម្រាប់ការទាញហេតុផលដោយផ្ទាល់មាត់លើកទី១ នេះចង់បង្ហាញថា នៅក្នុងនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច ការទាញហេតុផលដោយផ្ទាល់មាត់ គឺធ្វើបានតែមួយលើក និងក្រោយមក តុលាការត្រូវប្រកាសសាលក្រមភ្លាមៗ ក្រោយពេលដែលការទាញហេតុផលដោយផ្ទាល់មាត់នោះបានបញ្ចប់ ។

## ៤. ការហាមឃាត់ចំពោះការធ្វើបណ្តឹងតប

នៅក្នុងរឿងក្តីនៃនីតិវិធីបណ្តឹងធម្មតា កាលបើដើមចោទបានដាក់ពាក្យបណ្តឹងចំពោះចុងចម្លើយ ដែលទាមទារអំពីអត្ថិភាពនៃសិទ្ធិណាមួយនោះ ហើយបើចុងចម្លើយអាចបញ្ជាក់អំពីនត្ថិភាពនៃរបស់ខ្លួនចំពោះដើមចោទដែរនោះ នៅក្នុងករណីនេះ ចុងចម្លើយអាចដាក់ពាក្យបណ្តឹងតបវិញបាន ។ បណ្តឹងតប គឺជាបណ្តឹងដែលធ្វើឡើងដោយចុងចម្លើយចំពោះដើមចោទនៃបណ្តឹងដើមដែលកំពុងត្រូវបានចាត់ការ ។ ក្នុងករណីនេះ ចុងចម្លើយអាចប្តឹងតប ទៅតុលាការដែលកំពុងដែលចាត់ការបណ្តឹងដើម រហូតដល់ពេលចប់ការទាញហេតុផលដោយផ្ទាល់មាត់បាន លុះត្រាតែការទាមទារដែរជាកម្មវត្ថុនៃបណ្តឹងតបនោះទាក់ទងនឹងការទាមទារដែរជាកម្មវត្ថុនៃបណ្តឹងដើម ឬមធ្យោបាយការពារខ្លួនសម្រាប់បណ្តឹងដើម ។ វាមានន័យថា ដើមចោទបានដាក់ពាក្យបណ្តឹង ( អ្នកទិញ )

ដោយផ្អែកលើកិច្ចសន្យាលក់ទិញ ចំពោះចុងចម្លើយ( អ្នកលក់ ) ដោយទាមទារកម្មវត្ថុ (តាវកាលិក ) នៅក្នុងកិច្ចសន្យា ក្រោយមកចុងចម្លើយ ( អ្នកលក់ ) បានអះអាងថាមិនបានទទួលប្រាក់ ដូច្នេះ ចុងចម្លើយ ( អ្នកលក់ ) បានដាក់ពាក្យសុំទៅតុលាការដើម្បីឱ្យ ដើមចោទ ( អ្នកទិញ ) ប្រគល់ប្រាក់ ហើយពាក្យសុំនេះ គឺជាបណ្តឹងតប ។

បណ្តឹងតប នេះមិនត្រូវយកមកអនុវត្តឡើយចំពោះករណី ដែលការទាមទារជាកម្មវត្ថុនៃបណ្តឹងតបនោះ ស្ថិតនៅក្រោមសមត្ថកិច្ចផ្តាច់មុខរបស់តុលាការដ៏ទៃតាមច្បាប់កំណត់ ឬបណ្តឹងតបនោះនឹងធ្វើឱ្យមានការយឺតយ៉ាវយ៉ាងខ្លាំងក្នុងនីតិវិធីនៃបណ្តឹង ។

បណ្តឹងតប ជាបណ្តឹងដែលធ្វើឡើងដោយចុងចម្លើយ ចំពោះដើមចោទវិញ ដែលបណ្តឹងតបនេះវាធ្វើឱ្យមានការចំណាយពេលយូរ ដែលនាំឱ្យនីតិវិធីបណ្តឹងមានការយឺតយ៉ាវ និងមានភាពស្មុគស្មាញ ហេតុដូច្នេះហើយ បានជានៅក្នុងនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច ការប្តឹងតបមិនអាចធ្វើបានឡើយ ។[59]

### ៥ . ការហាមឃាត់ចំពោះការធ្វើបណ្តឹឧបាស្រ័យ

បណ្តឹងឧបាស្រ័យ គឺជាការប្តឹង ទៅតុលាការជាន់ខ្ពស់ដើម្បីអោយមានការសម្រេចជាថ្មី ទៅនិងការសម្រេចសេចក្តីរបស់តុលារការជាន់ទាប ឬយើងអាចនិយាយម្យ៉ាងទៀតថា ជាការប្តឹងមិនសុខចិត្ត និងសេចក្តីរបស់តុលាការជាន់ទាបដែលមិនទាន់ចូលជាស្ថាពរទៅតុលាការជាន់ខ្ពស់ ។

ប្រភេទនៃបណ្តឹងឧបាស្រ័យមានចំពោះសេចក្តីសម្រេច ដូចជាការប្តឹងឧទ្ធរណ៍ចំពោះសាលក្រមសាលាដំបូង ឬបណ្តឹងសាទុក្ខក្នុងករណីមានការព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍ ដោយរក្សាទុកនូវសិទ្ធិប្តឹងសារទុក្ខ នៅក្រោយពេលតុលាការសាលាដំបូងបានចេញសាលក្រមចុងក្រោយ និងសាលក្រមចុងក្រោយរបស់សាលាដំបូងនោះវិនិច្ឆ័យទៅលើរឿងក្តីរដ្ឋប្បវេណី ឬរឿងពាណិជ្ជកម្មដែលមានតម្លៃកម្មវត្ថុនៃបណ្តឹង មិនលើសពី ប្រាំលានរៀល ឬ

បណ្តឹងសាទុក្ខ ចំពោះ សាលដីការបស់តុលាការនៃបណ្តឹងឧទ្ធរណ៍ និង ចុងក្រោយ ជាការប្តឹងជំទាស់ចំពោះដីកាសម្រេច ហើយបណ្តឹងជំទាស់ គឺអាចធ្វើបាន លុះត្រាតែមានការអនុញ្ញាតដោយមានបញ្ញាត្តិនៅក្នុងច្បាប់ លើសពីនេះទៅទៀត ដីកាដែលសម្រេចលើបណ្តឹងជំទាស់ មិនអាចប្តឹងជំទាស់ទៀតបានទេ ។ វាមានន័យថា បើមានបណ្តឹងជំទាស់នៅ សាលាដំបូងនោះ សាលាឧទ្ធរណ៍ជាអ្នកសម្រេច បើមានបណ្តឹងជំទាស់នៅសាលាឧទ្ធរណ៍ នោះតុលាការកំពូលជាអ្នកសម្រេច ។

[59] មាត្រា ២២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី

បើកាលណាសាលាឧទ្ធរណ៍ បានសម្រេចទៅលើបណ្ដឹងជំទាស់ របស់សាលាដំបូងហើយ សេចក្ដីសម្រេចនោះមិនអាចប្ដឹងជំទាស់ទៅតុលាការកំពូលឱ្យធ្វើការសម្រេចម្ដងទៀតបានទេ ។[60]

ដោយសារការធ្វើបណ្ដឹងឧបាស្រ័យនេះមានភាពស៊ាំញ៉ាំ និងស្មុគស្មាញទៀតនោះ ហើយត្រូវចំណាយពេលវេលាច្រើន ដែលរយៈពេលនោះ រួមមានរយៈសម្រាប់ធ្វើឧបាស្រ័យ សាលាឧទ្ធរណ៍ និងទៅតុលាការកំពូល ត្រូវចំណាយពេល ១ ខែ និង ធ្វើបណ្ដឹងជំទាស់ ចំណាយរយៈពេល ១ សប្ដាហ៍ ។

ដោយឡែកនីតិវិធីរឿងក្ដីចំនួនទឹកប្រាក់តិច មានកម្មវត្ថុនៃបណ្ដឹងតិចតួច ម្យ៉ាងទៀតគោលបំណងគឺ ដើម្បីដោះស្រាយវិវាទដ៏ឆាប់រហ័ស តាមនីតិវិធីសង្ខេប ។ ហេតុដូច្នេះហើយ បានជានៅក្នុងនីតិវិធីចំនួនទឹកប្រាក់តិច បានបញ្ញត្តិថា ចំពោះសាលក្រមចុងក្រោយនៃរឿងក្ដីចំនួនទឹកប្រាក់តិចមិនអាចធ្វើឧបាស្រ័យបានឡើយ ។[61]

[60] មាត្រា ២៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[61] មាត្រា ២៣៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី

# ជំពូកទី៣ ៖ ការបញ្ចប់ នៃនីតិវិធីចំនួនទឹកប្រាក់តិច

ការដែលភាគីដាក់ពាក្យបណ្ដឹងមកតុលាការ គឺជាពេលចាប់ផ្ដើមនីតិវិធីដែលជាសមត្ថកិច្ចរបស់តុលាការ ម៉្យាងនៅពេលតុលាការបានចេញសេចក្ដីសម្រេច ដូចជា សាលក្រម នោះវាគឺជាការបញ្ចប់នីតិវិធីនៃបណ្ដឹង ( ផ្នែកទី១ ) ដោយឡែក ក្រោយពីការបញ្ចប់ទៅលើបណ្ដឹង ការអនុវត្តនូវសេចក្ដីសម្រេចនោះ ( ផ្នែកទី២ ) ជាស្ថាប័នតុលាការមួយផ្សេងទៀត ។

## ផ្នែកទី១ ៖ របៀបនៃការបញ្ចប់នីតិវិធីបណ្ដឹង

នៅក្នុងប្រព័ន្ធនីតិចំរុះ គឺច្បាប់នីតិវិធីរដ្ឋប្បវេណីនេះ ការបញ្ចប់នីតិវិធីនៃបណ្ដឹងគឺអនុវត្តដូចគ្នា មិនថានីតិវិធីបណ្ដឹងលើអង្គសេចក្ដីធម្មតា ឬនីតិវិធីរឿងក្ដីចំនួនទឹកប្រាក់តិចនោះទេ ។

នៅក្នុងនីតិវិធីរដ្ឋប្បវេណីរួមមាន ការបញ្ចប់នីតិវិធីបណ្ដឹងដោយស្វ័យប្រវត្តិ ( កថាខណ្ឌទី ១ ) ការបញ្ចប់នីតិវិធីបណ្ដឹងតាមរយៈតុលាការ គឺដោយការចេញសាលក្រមចុងក្រោយ( កថាខ័ណ្ឌទី ២ ) និងជាចុងក្រោយ គឺជាការបញ្ចប់នីតិវិធីបណ្ដឹងដោយសកម្មភាពរបស់ភាគី ( កថាខ័ណ្ឌទី ៣ ) ហើយការអនុវត្តនូវសេចក្ដីសម្រេចនេះគឺ ភាគីអាចយកនូវសេចក្ដីសម្រេចនេះទៅអនុវត្តដោយខ្លួនឯង ឬ ដាក់ពាក្យសុំអនុវត្តទៅតុលាការអនុវត្តឱ្យធ្វើការអនុវត្តដោយបង្ខំនូវសេចក្ដីសម្រេចនេះ ជំនួសក៏បាន ។

### កថាខ័ណ្ឌទី ១ ៖ ការបញ្ចប់នីតិវិធីបណ្ដឹងដោយស្វ័យប្រវត្តិ

ការបញ្ចប់នូវនីតិវិធីនៃបណ្ដឹងដោយស្វ័យប្រវត្តិនេះ គឺអាចយកទៅអនុវត្តបានតែក្នុងករណីដែលភាគីបានទទួលមរណភាព ឬបានរលត់ដោយការបញ្ចូលគ្នានូវនីតិបុគ្គល ហើយគ្មានអ្នកទទួលបន្តនូវសិទ្ធិ ឬកាតព្វកិច្ច ដែលជាកម្មវត្ថុនៃបណ្ដឹង ឬសិទ្ធិ ឬកាតព្វកិច្ចនោះ បានធ្លាក់ទៅលើបុគ្គលតែម្នាក់ នោះនីតិវិធីនៃបណ្ដឹងត្រូវបានបញ្ចប់ ។ [62] មាត្រានេះបានលើកឡើងពីការមរណភាពរបស់ភាគី និងសិទ្ធិ ឬកាតព្វកិច្ចបានធ្លាក់ទៅលើបុគ្គលតែម្នាក់ ។ កាលបើកើតមាននូវមរណភាពនោះសិទ្ធិ និងកាតព្វកិច្ច ត្រូវបានធ្លាក់ សន្តតិជន ជាអាទិ៍ នោះតុលាការត្រូវប្រកាសរកសន្តិជនដើម្បីឱ្យទទួលបន្តនូវនីតិវិធី តែបើក្នុងករណីគ្មានសន្តិជនជាអ្នកទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចនោះនីតិវិធីបណ្ដឹងនិងត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ ។

ដោយឡែកចំពោះសិទ្ធិ ឬកាតព្វកិច្ចវិញ គឺវាកើតមានតាមបទបញ្ញត្តិនៃក្រមនីតិរដ្ឋប្បវេណី ហើយវានិងរលត់ទៅវិញ ក៏ត្រូវតែស្របតាមក្រមរដ្ឋប្បវេណីនេះផងដែរ ការណាបើមានការ រលត់សិទ្ធិ ឬកាតព្វកិច្ច ហើយនោះការទៀមទារតាមនីតិវិធីនៃបណ្ដឹងក៏រលត់ដែរ។

[62] មាត្រា ១៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី

នៅក្នុងករណី ដែរសិទ្ធិលើបំណុល ឬកាតព្វកិច្ចបានធ្លាក់ទៅលើបុគ្គលតែម្នាក់ នោះសិទ្ធិលើបំណុល ឬកាតព្វកិច្ច នឹងត្រូវរលត់ដោយព្យាកុលភាព ។ [63]

អានុភាពនៃការបញ្ចប់នីតិវិធីបណ្ដឹងដោយស្វ័យប្រវត្តិនេះ គឺវាមានលក្ខណៈពិសេសនៅត្រង់ថាតុលាការមិនចេញជាដីកា ឬធ្វើកំណត់ហេតុ ណាមួយនោះទេ គឺតុលាការចេញសាលក្រមប្រកាសសម្រេចបញ្ចប់បណ្ដឹងនោះតែម្ដង ។ [64] លើសពីនេះទៅទៀត គឺជាសាលក្រមដែលប្រកាសនោះមិនអាចយកទៅអនុវត្តដោយបង្ខំបាននោះទេ ព្រោះថាវាមិនមែនជាសាលក្រមដែលបង្គាប់ឱ្យផ្ដល់តាវកាលិកដូចមានកំណត់នៅក្នុងមាត្រា ៣៥០ នៅកថាខ័ណ្ឌទី ២ ចំណុច ក ( សាលក្រម ឬសាលដីកាបង្គាប់ឱ្យផ្ដល់តាវកាលិកដែលបានចូលជាស្ថាពរ ) នោះទេ តែផ្ទុយទៅវិញ វាគឺជាសាលក្រមដែលប្រកាសក្នុងគោលបំណងឱ្យកើតមាននូវអាជ្ញាអស់ជំនុំទៅវិញ ។

## កថាខ័ណ្ឌទី ២ ៖ ការបញ្ចប់នីតិវិធីបណ្ដឹងតាមរយៈតុលាការ

ការបញ្ចប់នីតិវិធីបណ្ដឹងតាមរយៈតុលាការនេះ គឺមានន័យថាតុលាការជាអ្នកបញ្ចប់នីតិវិធីបណ្ដឹងដោយការប្រកាសសាលក្រមចុងក្រោយ ។ សាលក្រមចុងក្រោយនេះ កើតចេញពីលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ បើតុលាការមិនបានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ទេនោះ គឺមិនអាចចេញសាលក្រមបានឡើយ ។ ប៉ុន្តែ ចំពោះរឿងក្ដី ឬចំណុចណាដែលត្រូវសម្រេច ដោយដីកាសម្រេច នោះតុលាការត្រូវកំណត់ថា ត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ឬមិនធ្វើ។[65]

ម្យ៉ាងវិញទៀត តុលាការមិនអាចយកអង្គហេតុណាមកធ្វើការវិនិច្ឆ័យ ដោយភាគីណាមួយមិនបានអះអាង មកធ្វើជាមូលដ្ឋាននៃសាលក្រមឡើយ។[66] រាល់ការវិនិច្ឆ័យដើម្បីចេញសាលក្រមតុលាការ ត្រូវធ្វើការវិនិច្ឆ័យទទួលស្គាល់ ឬមិនទទួលស្គាល់ ថាការអះអាងអំពីអង្គហេតុនោះ មាន ឬគ្មានភាពពិតដោយគិតពិចារណា យ៉ាងហ្មត់ចត់ នូវលទ្ធផលនៃការពិនិត្យភស្តុតាង និងដំណើរការនិងខ្លឹមសារនៃការទាញហេតុផលដោយផ្ទាល់មាត់ ទៅតាមគោលការណ៍ជំនឿទុកចិត្តដោយសេរីរបស់ខ្លួន ។ [67]

ក្រោយពីការវិនិច្ឆ័យដោយផ្អែកទៅលើការពិនិត្យភស្តុតាង ដែលភាគីបានដាក់ជូនឱ្យតុលាការនិង ក្រោយពីទទួលបានលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ហើយនោះ តុលាការត្រូវ

[63] មាត្រា ៤៧៩ កថាខណ្ឌទី ១ នៃក្រមនីតិរដ្ឋប្បវេណី ឆ្នាំ ២០០៧

[64] មាត្រា ១៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[65] មាត្រា ១១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[66] មាត្រា ៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី

[67] មាត្រា ១៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ចេញសាលក្រម ចំពោះការទាមទារទាំងអស់ដែលភាគីបានស្នើសុំ ( នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់) ហើយតុលាការមិន អាចចេញសាលក្រមចំពោះចំណុចណាលដែលភាគីមិនបានស្នើរសុំឡើយ ។ តែមានការលើកលែងមួយ ដែលតុលាការ ត្រូវធ្វើការសម្រេចសេចក្តីអំពីករណីកិច្ចទទួលបន្ទុកប្រាក់ប្រដាប់ក្តី ទោះបីជាគ្មានពាក្យសុំរបស់ភាគីក៏ដោយ ។ តុលាការជាអ្នកសម្រេចអំពីអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តីតែចំនួនប្រាក់ប្រដាប់ក្តី ដែលត្រូវទទួលបន្ទុកបង់នោះគឺត្រូវកំណត់ដោយ ក្រឡាបញ្ជីនៃតុលាការ ជំនុំជំរះលើកទី១ តាមពាក្យសុំនៅក្រោយពេលដែលសេចក្តីសម្រេចអំពីបន្ទុកនោះបានបង្កើតអានុភាពនៃការអនុវត្ត ។

ហើយអានុភាពនៃសាលក្រម ឬសាលដីកា របស់តុលាការនេះអាចយកទៅអនុវត្តដោយបង្ខំបានតែចំពោះ សាលក្រមនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិចដែលបានចូលជាស្ថាពរ ឬ ប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន គឺមិនចាំបាច់ប្រើប្រាស់នូវរូបមន្តអនុវត្តនោះទេ ។

## កថាខ័ណ្ឌទី ៣ ៖ ការបញ្ចប់នីតិវិធីបណ្តឹងដោយភាគី

ការបញ្ចប់នីតិវិធីនៃបណ្តឹងដោយសកម្មភាពរបស់គូរភាគី គឺធ្វើឡើងដោយផ្អែកទៅលើឆន្ទៈរបស់គូរភាគីដោយផ្ទាល់ ។ ការធ្វើបែបនេះ គឺដោយសារ ច្បាប់គោរព និងទទួលស្គាល់ នូវគោលការណ៍ នៃ សិទ្ធិចាត់ចែង របស់បុគ្គលឯកជន ម៉្យាងទៀត គោលការណ៍នេះគេយកមកធ្វើជាមូលដ្ឋាននៅក្នុងការអនុវត្តយ៉ាងទូលំទូលាយនៅក្រមនីតិវិធីរដ្ឋប្បវេណីនេះ ។

ហើយការបញ្ចប់នីតិវិធីនៃបណ្តឹងដោយកម្មភាពរបស់ភាគីនេះរួមមាន ការដកពាក្យបណ្តឹង ការលះបង់ការទាមទារការទទួលស្គាល់ការទាមទារ និងការសះជាតាមផ្លូវបណ្តឹង ។

### ១ ៖ ការបញ្ចប់នីតិវិធីនៃបណ្តឹងដោយការដកពាក្យបណ្តឹង

បណ្តឹងត្រូវបានដាក់មកតុលាការដោយផ្អែកទៅលើ ឆន្ទៈរបស់ម្ចាស់បំណុល គឺជាអ្នកផ្តើមឱ្យមានបណ្តឹងកើតឡើងតាមផ្លូវតុលាការ ។ តែបើក្រោយមកម្ចាស់បំណុល បាត់បង់នូវឆន្ទៈ ឬបោះបង់ចោលនូវឆន្ទៈនោះ ម្ចាស់បំណុលអាចធ្វើការដកពាក្យបណ្តឹងវិញបាន ។

នៅក្នុងរណីដែលដើមចោទ បានផ្លាស់ប្តូរឆន្ទៈរបស់ខ្លួនដោយបង្ហាញតាមរយៈការដកពាក្យបណ្តឹង នោះដើមចោទអាច ធ្វើការដកនូវពាក្យទាំងមូល ឬមួយផ្នែកបានរហូតដល់ពេលដែលសាលក្រមចុងក្រោយបានចូលជាស្ថាពរ ។

ការដកពាក្យបណ្តឹងរបស់ដើមចោទ ទោះបីជាច្បាប់បានទទួលស្គាល់ គោលការណ៍ សិទ្ធិចាត់ចែងរបស់ បុគ្គលឯកជនក៏ដោយ ។ តែមានករណីខ្លះការដកពាក្យបណ្តឹងរបស់ដើមចោទវាធ្វើ

ឱ្យខាតបង់នូវផលប្រយោជន៍ របស់ចុងចម្លើយផងដែរ បើការដកពាក្យបណ្ដឹងនោះបានធ្វើនៅក្រោយពីចុងចម្លើយបានដាក់ឯកសារត្រៀម អំពីអង្គហេតុ ឬបានឆ្លើយក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលអំពីអង្គសេចក្ដី ឬបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់អំពីអង្គសេចក្ដីរួចហើយ នោះការដកពាក្យបណ្ដឹងមិនត្រូវមានអានុភាពឡើយ លើកលែងតែទទួលបានការយល់ព្រមពីចុងចម្លើយ ។

ការដកពាក្យបណ្ដឹង ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ។ ប៉ុន្តែ បើការដកពាក្យបណ្ដឹងនោះនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬនៅកាលបរិច្ឆេទនៃការផ្សះផ្សាការដកពាក្យបណ្ដឹងអាចធ្វើឡើងដោយផ្ទាល់មាត់បាន ។

បើការដក ពាក្យបណ្ដឹងមិនបានធ្វើនៅកាលបរិច្ឆេទនោះទេ ការដកពាក្យបណ្ដឹងត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ ក្រោយមកតុលាការត្រូវបញ្ជូនលិខិតនេះទៅចុងចម្លើយ ។ ម៉្យាងទៀត បើការដកពាក្យបណ្ដឹងបានធ្វើនៅកាលបរិច្ឆេទនៃនីតិវិធី តែពុំមាននូវវត្តមានរបស់ចុងចម្លើយនោះ តុលាការត្រូវបញ្ជូនឯកសារចម្លងនៃ កំណត់ហេតុនៅកាលបរិច្ឆេទនេះទៅឱ្យចុងចម្លើយ។ តែបើមានវត្តមានរបស់ចុងចម្លើយមិនបាច់ធ្វើការបញ្ជូនទេ ។

ការដកពាក្យបណ្ដឹង នៅក្នុងកាលបរិច្ឆេទខាងលើទាមទារអោយមានការយល់ព្រមពីចុងចម្លើយ ដូចនេះ ប្រសិនបើ មានការដកពាក្យបណ្ដឹងនៅកាលបរិច្ឆេទដែលមានវត្តមានរបស់ ចុងចម្លើយនោះ បើចុងចម្លើយមិនបានធ្វើការតវ៉ានៅក្នុង អំឡុងពេល ២ សប្ដាហ៍ គិតចាប់ពីកាលបរិច្ឆេទនោះ ត្រូវចាត់ទុកថាចុងចម្លើយបានយល់ព្រមចំពោះការដកពាក្យបណ្ដឹងនោះ ។ ម្យ៉ាងទៀត ប្រសិនបើ មានការដកពាក្យនៅពេលដែលពុំមានវត្តរបស់ចុងចម្លើយ នៅកាលបរិច្ឆេទនោះ ហើយតុលាការបានធ្វើការបញ្ជូនឯកសារចម្លងនៃកំណត់ហេតុអំពីការដកពាក្យបណ្ដឹងនោះ ទៅចុងចម្លើយ ហើយនៅអំឡុងពេល ២ សប្ដាហ៍ គិតចាប់ពីបានទទួលការបញ្ជូននោះ ត្រូវចាត់ទុកថាចុងចម្លើយបានយល់ព្រមចំពោះការដកពាក្យបណ្ដឹងរបស់ដើមចោទ ។[68]

ការដកពាក្យបណ្ដឹង គឺអាចធ្វើការដកទាំងមូល ឬមួយផ្នែកក៏បាន ហើយវានឹងកើតមានអានុភាពចំពោះពាក្យបណ្ដឹងនោះនៅត្រង់ថា ការដកពាក្យបណ្ដឹង ត្រូវចាត់ទុកថា ពាក្យបណ្ដឹងនោះមិនត្រូវបានចាត់ការតាំងពីដំបូង ចំពោះផ្នែកនៃបណ្ដឹង ឬ បណ្ដឹងទាំងមូលដែលត្រូវបានដកនោះ ។ ម៉្យាងទៀត ភាគីដែលបានដកពាក្យបណ្ដឹង ក្រោយពីបានចេញសាលក្រមចុងក្រោយអំពីអង្គសេចក្ដី មិនអាចដាក់ពាក្យបណ្ដឹងដូចគ្នាម្ដងទៀតនោះទេ ។

[68] មាត្រា ២១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី

**២ ៖ ការបញ្ចប់នីតិវិធីនៃបណ្តឹងដោយការលះបង់នូវការទាមទារ**

ការបញ្ចប់នីតិវិធីនៃបណ្តឹងតាមរបៀបនេះ វាកើតចេញពីឆន្ទៈរបស់ដើមចោទ ហើយការលះបង់នូវការទាមទារនេះ ដើមចោទត្រូវធ្វើសេចក្តីថ្លែងការណ៍ ថាខ្លួនលះបង់ការទាមទាររបស់ខ្លួននៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬកាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឬនៅកាលបរិច្ឆេទនៃការផ្សះផ្សា ។ ការដែលដើមចោទបានធ្វើការលះបង់ការទាមទារ ដោយទទួលស្គាល់ថាការទាមទារតាមផ្លូវបណ្តឹងរបស់ខ្លួន គ្មានមូលហេតុត្រឹមត្រូវ ឬគ្មានអត្ថិភាពនៃសិទ្ធិរបស់ខ្លួននៅក្នុងការទាមទារ ឬដើមចោទបានធ្វើការលះបង់ការទាមទាររបស់ខ្លួនទោះបីជាដើមចោទមានមូលហេតុត្រឹមត្រូវនិងទាមទារ ឬមានអត្ថិភាពនៃសិទ្ធិរបស់ខ្លួន ក៏ដោយ ពីព្រោះនេះវាគឺដោយឈរទៅលើ គោលការណ៍នៃសិទ្ធិចាត់ចែង ( មកធ្វើជាមូលដ្ឋាន ) របស់ដើមចោទ ។

ម៉្យាងទៀត ការលះបង់ការទាមទារនេះ វាធ្វើឱ្យមានការខូចខាតប្រយោជន៍របស់អ្នកដែលធ្វើការលះបង់ការទាមទារនោះ ហើយការ លះបង់ការទាមទារនេះជាទូទៅគឺ ធ្វើឡើងដោយដើមចោទ ។

ចំពោះនីតិវិធីនៅក្នុងការលះបង់នូវការទាមទារនេះ គឺតុលាការធ្វើការសម្រេចដោយមិនចេញសាលក្រមនោះទេ គឺត្រូវធ្វើជាកំណត់ហេតុ ហើយកំណត់ហេតុនេះមានអានុភាពដូចសាលក្រមដែរ ។

**៣ ៖ ការបញ្ចប់នីតិវិធីបណ្តឹងដោយការទទួលស្គាល់នូវការទាមទារ**

បណ្តឹងគឺធ្វើឡើងដោយដើមចោទ ចំពោះចុងចម្លើយ ហើយការបញ្ចប់នីតិវិធីនៃបណ្តឹងនេះ វាក៏អាចកើតចេញពីឆន្ទៈរបស់ចុងចម្លើយផងដែរ ហើយការបញ្ចប់នីតិវិធីបណ្តឹងបែបនេះ គឺចុងចម្លើយត្រូវធ្វើសេចក្តីថ្លែងការ ថាខ្លួនបានទទួលស្គាល់នូវ ការទាមទាររបស់ដើមចោទនៅកាលបរិច្ឆេទនៃនីតិវិធីត្រៀម សម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឬនៅកាលបរិច្ឆេទនៃការផ្សះផ្សា ។ ហើយម្យ៉ាងទៀត ចំពោះការទទួលស្គាល់នូវការទាមទារនេះ គឺជាទូទៅកើតមានចំពោះចុងចម្លើយ ដែលការធ្វើបែបនេះ វាធ្វើឱ្យមានការខូចផលប្រយោជន៍ របស់អ្នកដែលធ្វើការទទួលស្គាល់នូវការទាមទារនោះ ។ ដោយចុងចម្លើយបានទទួលស្គាល់ដោយគ្មានលក្ខខ័ណ្ឌ ដោយហេតុថា ការទាមទាររបស់ដើមចោទអំពីអត្ថិភាពនៃសិទ្ធិមានមូលហេតុ និង មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

ចំពោះនីតិវិធីនៅក្នុងការលះបង់នូវការទាមទារនេះ គឺតុលាការធ្វើការសម្រេចដោយមិនចេញសាលក្រមនោះទេ គឺត្រូវធ្វើជាកំណត់ហេតុហើយកំណត់ហេតុនេះវាមានអានុភាពដូចសាលក្រមដែរ ។

### ៤ ៖ ការបញ្ចប់នីតិវិធីនៃបណ្តឹងតាមរយៈការសះជាតាមផ្លូវបណ្តឹង

ការពីដំបូងភាគីដើមចោទបានដាក់ពាក្យបណ្តឹងទាមទារ អំពីអត្ថិភាពនៃសិទ្ធិ ណាមួយដែរ ខ្លួនមានចំពោះចុងចម្លើយ ។ នៅពេលដែលតុលាការបានធ្វើចំណាត់ការលើពាក្យបណ្តឹងនោះ តុលាការ ត្រូវធ្វើការផ្សះផ្សា ហើយការផ្សះផ្សានេះ គឺតុលាការអាចសាកល្បងធ្វើការផ្សះផ្សាបាន ទោះបីជាបណ្តឹងស្ថិតនៅក្នុងដំណាក់កាលណាក៏ដោយ ។ [69] ហើយការផ្សះផ្សានេះ ក៏អាចធ្វើនៅក្រៅទីតាំងតុលាការក៏បានដែរ ប្រសិនបើ តុលាការយល់ឃើញថាសមរម្យ ។ ការផ្សះផ្សានេះ ជាហេតុនាំភាគីមានការសះជានិងគ្នាតាមផ្លូវបណ្តឹង ។

ការសះជាតាមផ្លូវបណ្តឹង ជាការលះបង់រៀងៗខ្លួន ( ជាការសម្បទានឱ្យគ្នាទៅវិញទៅមក ) នូវការអះអាងអំពី អត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ហើយជាការព្រមព្រៀងគ្នាបញ្ចប់វិវាទ រវាងដើមចោទ និងចុងចម្លើយ ដែលបានធ្វើនៅក្នុងនីតិវិធីនៃបណ្តឹង និងបានថ្លែងការណ៍ឯកភាពគ្នាអំពីការសះជានោះ នៅចំពោះមុខតុលាការ ។

ការសះជា គឺជាលទ្ធផលដែលកើតចេញពីឆន្ទៈរបស់គូរភាគី ហើយតុលាការត្រូវគោរពនូវឆន្ទៈរបស់គូរភាគី ព្រោះជាសិទ្ធិរបស់ភាគីនៅក្នុងចាត់ចែងទៅលើវិវាទរបស់ខ្លួន និង នាំឱ្យមានការចាត់ចែងលើកម្មវត្ថុនៃបណ្តឹង ។

ការសះជាតាមនីតិវិធីបណ្តឹង វាបានផ្តល់ផលប្រយោជន៍យ៉ាងច្រើនចំពោះ ភាគីទាំងសងខាង និងក៏ដូចជា បានផ្តល់ផលប្រយោជន៍ចំពោះរដ្ឋផងដែរ ។

ចំពោះនីតិវិធីនៅក្នុងការសះជាតាមផ្លូវបណ្តឹងនេះ គឺតុលាការធ្វើការសម្រេចដោយមិនចេញសាលក្រមនោះទេ គឺត្រូវធ្វើជាកំណត់ហេតុហើយកំណត់ហេតុនេះមានអានុភាពដូចសាលក្រមដែរ ។

## ផ្នែកទី ២ ៖ ការអនុវត្តនូវសេចក្តីសម្រេចបញ្ចប់បណ្តឹង

ក្រោយពី បណ្តឹងត្រូវបានទទួល និងត្រូវបានវិនិច្ឆ័យចប់ហើយនោះ តុលាការនិងចេញសេចក្តីសម្រេចបញ្ចប់នីតិវិធីបណ្តឹង ដែលជាវិវាទរបស់គូរភាគី ។ ហើយភាគីដែលទទួលបានការសម្រេចឱ្យឈ្នះក្តីតាមរយៈសេចក្តីសម្រេច គឺអាចយកនូវសេចក្តីសម្រេចនោះទៅអនុវត្តបាន ។ ដោយឡែកការអនុវត្តនេះ ភាគីអាចអនុវត្តដោយស្ម័គ្រចិត្ត (កថាខ័ណ្ឌទី១ ) ឬការអនុវត្តនេះអាចធ្វើការអនុវត្តដោយបង្ខំដោយឱ្យតុលាការអនុវត្តធ្វើការអនុវត្តជំនួសបាន ( កថាខ័ណ្ឌទី២ ) ។

[69] មាត្រា ៩៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី

ហើយ សាលក្រមរបស់តុលាការ និងកើតមានអានុភាពដោយការប្រកាស ។ ចំពោះការប្រកាសសាលក្រម ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ខែ គិតពីថ្ងៃ ដែលបានបញ្ចប់នូវការទាញហេតុផលដោយផ្ទាល់មាត់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនយកមកអនុវត្តឡើយ ចំពោះរឿងក្តីដែលមានភាពស្មុគស្មាញខ្លាំង ឬមានកាលៈទេសៈពិសេសផ្សេងទៀត ។

តួយ៉ាង ដូចជានៅក្នុងនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច ក្រោយពីតុលាការបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់រួចហើយនោះ តុលាការ ត្រូវធ្វើការប្រកាសសាលក្រម ភ្លាមៗ នៅក្រោយពីការធ្វើការទាញហេតុផលដោយផ្ទាល់មាត់ លើកលែងតែករណីមិនសមរម្យ ។ [70] ហើយការប្រកាសសាលក្រម អាចធ្វើឡើងបាន ដោយមិនចាំបាច់ផ្អែកលើច្បាប់ដើមនៃមូលសាលក្រមឡើយ ។ នៅក្នុងករណីនេះ តុលាការត្រូវប្រកាសសាលក្រម ដោយប្រាប់ពីសេចក្តីសម្រេចបញ្ចប់ និង ខ្លឹមសារនៃសំអាងហេតុ ។ តុលាការត្រូវឱ្យ ក្រឡាបញ្ជីកត់ត្រានៅ ក្នុងកំណត់ហេតុនៃកាលបរិច្ឆេទសម្រាប់ការទាញហេតុផលដោយ ផ្ទាល់មាត់ ដែលតុលាការប្រកាសសាលក្រម ជំនួសការធ្វើលិខិតសាលក្រមនូវហេតុដែលបានកំណត់នៅក្នុងចំណុចនីមួយៗ ដូចខាងក្រោមនេះ ៖

ក. ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកដំណាងដែលច្បាប់បានកំណត់ ។

ខ. សាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ ។

គ. សេចក្តីសម្រេចបញ្ចប់ ។

ហើយនៅលើសាលក្រមនៃរឿងក្តីចំនួនទឹកប្រាក់តិច ឬកំណត់ហេតុជំនួសលិខិតសាលក្រមនោះ គឺត្រូវសរសេរថាជាសាលក្រមនៃរឿងក្តីចំនួនទឹកប្រាក់តិច ។

## កថាខណ្ឌទី ១ ៖ ការអនុវត្តនូវសេចក្តីសម្រេចដោយស្ម័គ្រចិត្ត

សេចក្តីសម្រេចនៅក្នុងន័យនេះ គឺជាសាលក្រម ឬមួយកំណត់ហេតុ ដែលជាលទ្ធផលនៃឆន្ទៈរបស់ភាគីនៅក្នុងការបញ្ចប់នីតិវិធីបណ្តឹង ។ ហើយកំណត់ហេតុ ក៏អាចយកទៅអនុវត្តបានដោយសារវា គឺជាលទ្ធផលនៃឆន្ទៈរបស់គូរភាគី ដូច្នេះហើយតុលាការត្រូវតែគោរពតាមឆន្ទៈនោះ ព្រោះដោយសារតុលាការ គឺអកម្មនៅក្នុងរឿងនីតិឯកជនបែបនេះ ។

ចំពោះវិវាទ នៅក្នុងនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិចនេះ គឺភាគច្រើនកើតមានទៅលើតែប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រ មានភាពលំបាក ទោះបីជាខ្លួនមានបំណងចង់សងបំណុលក៏ដោយ

[70] មាត្រា ២៣៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី

តែដោយសារតែកត្តាជីវភាព ជាអ្នកតម្រូវឱ្យធ្វើបែបនេះ ។ ហេតុដូច្នេះ ការអនុវត្តនូវសេចក្តីសម្រេចរឿងក្តីចំនួនទឹកប្រាក់តិច គឺមានលក្ខណៈខុសគ្នាទាំងស្រុងជាមួយនឹងការអនុវត្តនូវសេចក្តីសម្រេចនៅក្នុងនីតិវិធីនៃបណ្តឹងធម្មតា ។ ដោយការអនុវត្តនោះ គឺត្រូវស្របតាមមាត្រា ២៣៧ នៃក្រមនីតិវិធីដែលបានកំណត់ដូចខាងក្រោម ៖

១ ៖ នៅក្នុងនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច បើក្នុងករណីតុលាការចេញសាលក្រមទទួលស្គាល់ការទាមទាររបស់ដើមចោទ និងបើយល់ឃើញថា មានភាពចាំបាច់ពិសេស ដោយគិតពិចារណានូវលទ្ធភាពទ្រព្យធន និងស្ថានភាពផ្សេងៗ ទៀតរបស់ចុងចម្លើយនោះ តុលាការអាចកំណត់ចំណុច ក ឬចំណុច ខ ឬកំណត់ចំណុច គ ដោយកំណត់ជាមួយគ្នានឹងចំណុច ក ឬចំណុច ខ ចំពោះការសងប្រាក់ អំពីការទាមទារដែលតុលាការទទួលស្គាល់នោះ ក្នុងអំឡុងពេលមិនលើសពី ៣ ( បី ) ឆ្នាំ បន្ទាប់ពីថ្ងៃដែលប្រកាសសាលក្រមៈ

ក. កំណត់ពេលបង់ប្រាក់

ខ. កំណត់ពេលបងប្រាក់ដោយកាត់បណ្តើរៗ

គ. នៅពេលដែលសងតាមបញ្ញត្តិ ក ឬពេលដែលសងដោយមិនបាត់បង់តាមបញ្ញត្តិនៃកថាខ័ណ្ឌទី ២ ខាងក្រោមនេះ នូវផលប្រយោជន៍នៃកំណត់ពេលដែលបានកំណត់នៅចំនុច ខ កំណត់អនុគ្រោះ ចំពោះកាតព្វកិច្ច នៃការសងការខូចខាតដោយសារការយឺតយ៉ាវ ក្រោយពេលដាក់បណ្តឹង ។

២ ៖ នៅពេលដែលធ្វើការកំណត់ការបងប្រាក់ ដោយកាត់បណ្តើរៗ ដែលបានកំណត់នៅក្នុងចំណុច ខ ខាងលើនេះ តុលាការត្រូវកំណត់អំពីការបាត់បង់ផលប្រយោជន៍ នៃពេលកំណត់ក្នុងករណីដែលចុងចម្លើយ មិនសង ។ ការដែលតុលាការធ្វើការសម្រេចបែបនេះ នៅក្នុងបំណង ចង់ឱ្យចុងចម្លើយអាចអនុវត្តដោយស្ម័គ្រចិត្ត ដោយងាយស្រួល ចំពោះកាតព្វកិច្ចដែលត្រូវបានចង់ភ្ជាប់ដោយសាលក្រម ហើយវាក៏ជាផលប្រយោជន៍ទៅដល់ភាគីដើមចោទផងដែរ ។

បើសិនជាគូរភាគី បានទទួលនូវលិខិតសាលក្រម ឬ កំណត់ហេតុ ដែលកើតចេញពីលទ្ធផលនៃឆន្ទៈរបស់ខ្លួននោះ ហើយភាគីចុងចម្លើយបានក្លាយទៅជា កូនបំណុល ( ករណីដែលខ្លួនចាញ់ក្តី ) ហើយបានអនុវត្តតាមសេចក្តីសម្រេចនោះ ចំពោះដើមចោទ ( ម្ចាស់បំណុល ) ដោយស្ម័គ្រ នោះវិវាទនិងត្រូវបាន បញ្ចប់ ដោយសន្តិវិធី គឺ មិនចាំបាច់រំខាន ដល់តុលាការអនុវត្ត នោះទេ ។

## កថាខ័ណ្ឌទី ២ ៖ ការអនុវត្តសេចក្ដីសម្រេចដោយតុលាការអនុវត្ត

នៅក្នុងករណីដែលភាគីដែលឈ្នះក្ដីបានទទួលសេចក្ដីសម្រេច ជាសាលក្រម ឬ កំណត់ហេតុ ដែលកើតចេញពីឆន្ទៈរបស់ភាគីនោះ ភាគីត្រូវតែអនុវត្តតាម បើសិនជាភាគីណាមិនព្រមអនុវត្តតាម សេចក្ដីសម្រេចនោះទេ នោះភាគីម្ខាងទៀតអាចដាក់ពាក្យទៅតុលាការអនុវត្ត ឱ្យធ្វើការអនុវត្តនូវសេចក្ដីសម្រេចនោះជំនួសខ្លួនបាន ។

មិនថានៅក្នុងនីតិវិធីនៃបណ្ដឹងធម្មតានោះទេ ដោយឡែកនៅក្នុងនីតិវិធីនៃបណ្ដឹងរឿងក្ដីចំនួនទឹកប្រាក់តិច ក៏សុទ្ធតែអាចធ្វើការអនុវត្តដោយបង្ខំបានដែរ ទោះបីនីតិវិធីនៃបណ្ដឹងរឿងក្ដីចំនួនទឹកប្រាក់តិចនេះ មានតម្លៃកម្មវត្ថុនៃការទាមទារមានចំនួនមមិនលើសពី ១.០០០.០០០. ( មួយលាន ) រៀលក៏ដោយ ។

ហើយការដែលភាគីចាញ់ក្ដី មិនអនុវត្តដោយស្ម័គ្រនូវសេចក្ដីសម្រេចនោះ ភាគីដែលឈ្នះក្ដី ( ម្ចាស់បំណុល ) មិនអាចទៅធ្វើការដកហូតយកទ្រព្យ ( តាវកាលិក ) ពីរកូនបំណុលមកបានដោយខ្លួនឯងនោះទេ ដោយមូលហេតុថាគាត់ឈ្នះក្ដី ដោយយកសំអាងទៅលើសាលក្រម ដែលតុលាការបានប្រកាសឱ្យគាត់ ( ម្ចាស់បំណុល ) ឈ្នះក្ដីនោះទេ គឺគាត់អាច ដាច់ពាក្យសំទៅតុលាការអនុវត្ត ឱ្យធ្វើការអនុវត្តដោយបង្ខំដោយផ្អែកទៅលើលិខិតសាលក្រម នោះបាន ។ ទោះបីជាលិខិតសាលក្រមនោះបានប្រកាស ចូលជាស្ថាពរ ឬលិខិតសាលក្រមនោះ ត្រូវបានតុលាការបានប្រកាសឱ្យធ្វើការអនុវត្តជាបណ្ដោះអាសន្នក៏ដោយ ។

អោយតែមានសាលក្រម ឬសាលដីកា ឬដីកាដែលបានបង្គាប់ឱ្យផ្ដល់តាវកាលិកបានចូលជាស្ថាពរ ឬត្រូវបានតុលាការបានធ្វើការប្រកាសឱ្យអនុវត្តបណ្ដោះអាសន្ន គឺអាចយកទៅអនុវត្តដោយបង្ខំបាន ចំពោះនីតិវិធីនៃរឿងក្ដីចំនួនទឹកប្រាក់តិច គឺវាមានលក្ខណៈពិសេសជាង នីតិវិធីនៃបណ្ដឹងធម្មតានៅត្រង់ថា: ការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយកថាភូតនៃលិខិតអនុវត្ត ដែលភ្ជាប់ជាមួយ និងរូបមន្តអនុវត្ត ។ ប៉ុន្តែ ក្នុងករណីដែលមានឯកសារដែលកំណត់ដូចខាងក្រោមនេះ ជាលិខិតអនុវត្ត ការអនុវត្តដោយបង្ខំ ដោយយកភាគីដោយបានកំណត់ក្នុងលិខិតអនុវត្តនោះជាម្ចាស់បំណុល ឬកូនបំណុលនៃការអនុវត្ត ត្រូវធ្វើឡើងដោយផ្អែកលើលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តនោះ ៖

១ សាលក្រមនៃបណ្ដឹងរឿងក្ដីចំនួនទឹកប្រាក់តិច ដែលបានចូលជាស្ថាពរ ។[71]

[71] មាត្រា ៣៥៤ កថាខណ្ឌទី១ ចំណុច ក ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី

២ សាលក្រមនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ដែលភ្ជាប់ការប្រកាសឱ្យអនុវត្តបណ្តោះអាសន្ន ។

ប៉ុន្តែចំពោះរឿងក្តីចំនួនទឹកប្រាក់តិច ដែលត្រូវបានបញ្ចប់ ដោយ ការទទួលស្គាល់ការទាមទារ ឬ តាមរយៈការសះជា ហើយការបញ្ចប់បែបនេះតុលាការ ត្រូវធ្វើកំណត់ហេតុ ហើយនៅពេលដែលយកទៅអនុវត្តដោយបង្ខំនោះទាមទារឱ្យមានរូបមន្តអនុវត្តដែរ ឬ មិនចាំបាច់ទេ ? នៅក្នុងបទបញ្ញត្តិនៃការអនុវត្តដោយបង្ខំ គឺ មិនបានបញ្ញត្តិអំពីបញ្ហារនេះទេ តែ ជាមធ្យោបាយដើម្បីដោះស្រាយបញ្ហានេះ គឺ យើងត្រូវ យកទ្រឹស្តីថា បើច្បាប់មិនបានចែងមិនអាចយកមកអនុវត្តបានទេ ហេតុដូច្នេះ ការបញ្ចប់បណ្តឹតាមវិធីនេះ គឺ ទាមទារឱ្យមានលិខិតអនុវត្ត ភ្ជាប់មកជាមួយ ទើបអាចអនុវត្តដោយបង្ខំបាន ។

ក្រៅពីរចំណុចនេះចេញការ អនុវត្តដោយបង្ខំនៅក្នុងនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច គឺ ត្រូវអនុវត្ដ ដូចគ្នាទៅនឹងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះបណ្តឹងលើអង្គសេចក្តីធម្មតា ផងដែរ គឺអនុវត្តតាម គន្ថីទី៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ស្តីអំពី៉ ការអនុវត្តដោយបង្ខំ៉ ។

# សេចក្តីសន្និដ្ឋាន

នីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច គឺជាប្រភេទមួយនៃបណ្តឹងរដ្ឋប្បវេណីមានលក្ខណៈពិសេសខុសពីបណ្តឹងផ្សេងៗទៀតត្រង់ថា បណ្តឹងនេះធ្វើបានទាល់តែបំពេញល័ក្ខខណ្ឌអំពីការកំណត់កម្មវត្ថុនៃបណ្តឹងគឺត្រូវក្រោម ១.០០០.០០០ រៀល ទើបអាចជំនុំជម្រះតាមនីតិវិធីនេះបាន ។ ហើយការដើម្បីអាចឱ្យតុលាការធ្វើការយកបណ្តឹងនេះមកវិនិច្ឆ័យបាន គឺទាល់តែធ្វើការប្តឹងទៅតុលាការ ។ ជាងនេះទៅទៀត ដើម្បីធ្វើបណ្តឹងនេះបានត្រឹមត្រូវតាមច្បាប់ និង ដើម្បីឱ្យតុលាការទទួលយកបណ្តឹងនេះមកវិនិច្ឆ័យបាន លុះណាតែបណ្តឹងនោះបានធ្វើឡើងដោយបំពេញនូវលក្ខខណ្ឌសុពលនៃបណ្តឹងឱ្យត្រឹមត្រូវ ដែលលក្ខខណ្ឌ នោះរួមមាន កម្មវត្ថុនៃបណ្តឹង សមត្ថភាពនៅក្នុងការធ្វើសកម្មភាពបណ្តឹង និងសមត្ថកិច្ចតុលាការ ហើយជាចុងក្រោយ គឺមានការបញ្ជូន នូវពាក្យបណ្តឹងបើមិនបំពេញនូវលក្ខខណ្ឌនេះទេតុលាការមិនអាចយកពាក្យបណ្តឹងនោះមកវិនិច្ឆ័យបានឡើយ ។ លើសពីនេះទៅទៀត ការដាក់ពាក្យបណ្តឹងភាគីអាចដាក់ពាក្យបណ្តឹងមកតុលាការតាមរយៈការដាក់ពាក្យដោយសរសេរជាលាយល័ក្ខអក្សរ និងភាគីក៏អាចដាក់ពាក្យបណ្តឹដោយផ្ទាល់មាត់បានផងដែរ នេះជាលក្ខណៈពិសេសនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចនេះ ។ ម្យ៉ាងទៀត ច្បាប់ក៏បានធ្វើការផ្តល់សិទ្ធិទៅឱ្យ ភាគីដើមចោទ និង ទាំងភាគីចុងចម្លើយ ធ្វើការជ្រើសរើសនីតិវិធីបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច ឬមួយក៏នីតិវិធីបណ្តឹងលើអង្គសេចក្តីធម្មតាផងដែរ និងបូករួមជាមួយតុលាការ ក៏ច្បាប់បានផ្តល់សិទ្ធិឱ្យមានការកំណត់យកនីតិវិធីសម្រាប់វិនិច្ឆ័យសេចក្តីនេះដែរ ។ ហើយចំពោះសមាសភាព នៃចៅក្រមដែលធ្វើការវិនិច្ឆ័យលើបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចនេះមិនមានការប្រែប្រួលដូចនីតិវិធីនៃការជំនុំជម្រះលើបណ្តឹងអង្គសេចក្តីធម្មតានោះ ពោលគឺការ**ជំនុំជម្រះដោយមានសមាសភាពចៅក្រម ដែលមានចៅក្រម ០១ រូប ។** ដោយហេតុថាការសម្រេចសេចក្តីនេះវាមិនមានភាពលំបាក ឬ បានភាពស្មុគស្មាញដែលមិនតំរូវឱ្យមានការវិនិច្ឆ័យ ដោយក្រុមប្រឹក្សាជំនុំជម្រះនោះឡើយ ។ ហើយសាលក្រម ដែលសំរេចដោយចៅក្រមទោលនោះវាគឺជាសេចក្តីសម្រេចចុងក្រោយ ដែលភាគីមិនអាចធ្វើឧបាស្រ័យទៅតុលាការនៃសាលាឧទ្ធរណ៍ ឬបណ្តឹងជំទាស់ទៅនិងដីកាណាមួយ លើសពីនេះទៅទៀតភាគីដែលមិនសុខចិត្តទៅនិងសាលក្រមនោះ ក៏មិនអាចទៅតុលាការកំពូលតាមរយៈបណ្តឹងសារទុក្ខបានឡើយ ។ ជាគោលការណ៍ក្នុងរឿងក្តីចំនួនទឹកប្រាក់តិចការធ្វើវិនិច្ឆ័យគឺធ្វើតែក្នុងរយៈពេលមួយថ្ងៃ គឺវាចង់ញ្ជាក់ថាធ្វើតែមួយលើក ។ ហើយនៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នោះភាគី ត្រូវតែដាក់ភស្តុតាង ដែលអាចពិនិត្យភ្លាមៗជូនតុលាការដោយមិនមានការយឺតយ៉ាវឡើយ បើពុំនោះទេតុលាការមិនទទួលយកមកពិនត្យឡើយ ។ ហើយអ្វីដែលពិសេសជាងនេះទៅទៀតនោះ គឺ សាលក្រមនៃនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិចនេះ នៅពេល

ប្រកាសត្រូវបញ្ជាក់ថា វាជាសាលក្រមនៃ បណ្ដឹងរឿងក្ដីចំនួនទឹកប្រាក់តិចផងដែរ ហើយសាលក្រមរឿងក្ដីទឹកប្រាក់តិចនេះ នៅក្រោយពេលប្រកាសហើយ គឺអាចយកទៅអនុវត្តបាន ភ្លាមៗតែម្ដង ។

# អនុសាសន៍

ដោយសង្កេតឃើញស្ថានភាពជាក់ស្តែងប្រទេសជាតិយើងមានការរីកចម្រើនលើគ្រប់វិស័យ ពិសេសវិស័យច្បាប់ វាគឺជាវិស័យមួយដែលដើរតួនាទីយ៉ាងសំខាន់សំរាប់រក្សាស្ថិរភាព និងការអភិវឌ្ឍសង្គមជាតិ ហើយវាក៏បានចូលរួមការគ្រប់គ្រងប្រទេសជាតិ ឱ្យមានសុខសន្តិភាព សណ្តាប់ធ្នាប់និងរបៀបរៀបរយល្អ ។ ជាពិសេសនោះគឺចៅក្រមដែលមានតួនាទីជាអ្នកកាត់សេចក្តី តំណាង ឱ្យស្ថាប័នតុលាការត្រូវជៀសឱ្យឆ្ងាយអំពី អគតិទាំង៤ នៅក្នុងពេលដែលខ្លួនធ្វើការវិនិច្ឆ័យ និងសម្រេចសេចក្តីឡើយ ។ អគតិទាំងនោះរួមមាន **ឆន្ទាគតិ** សេចក្តីលំអៀងព្រោះស្រលាញ់ **ទោសាគតិ** សេចក្តីលំអៀងព្រោះស្អប់ **មោហាគតិ** សេចក្តីលំអៀងព្រោះល្ងង់ **ភយាគតិ** សេចក្តីលំអៀងព្រោះខ្លាចបុណ្យខ្លាចអំណាច ឬខ្លាចគតិ ។ ការដែលតំរូវឱ្យចៅក្រមត្រូវតែជៀសឱ្យផុតពី អគតិទាំង៤នេះ គឺព្រោះតែចៅក្រមមានកត្តាព្វកិច្ចត្រូវតែវិនិច្ឆ័យឱ្យបានសុក្រិត ព្រោះដើម្បីឱ្យប្រជាពលរដ្ឋមានជំនឿជាក់ទៅលើតុលាការ កានតែខ្លាំងថែមទៀត ។ ម្យ៉ាងទៀត តុលាការមិនត្រូវគិតអំពីតម្លៃនៃកម្មវត្ថុ ថាតើ កម្មវត្ថុនោះតិច ឬ មួយក៏ច្រើននោះទេ គឺខ្លួនតែត្រូវវិនិច្ឆ័យនោះទេ គឺតុលាការត្រូវវិនិច្ឆ័យដោយយកចិត្តទុកដាក់ និង ហ្មត់ចត់ ដោយផ្អែកលើស្មារតីនៃច្បាប់ ។ ដោយឡែកច្បាប់ក៏បានកំណត់ អំពីនីតិវិធីនៃការវិនិច្ឆ័យទៅកម្មវត្ថុនៃបណ្តឹងដែលមានចំនួនតិចផងដែល ។ នីតិវិធីនេះគឺជា នីតិវិធីរឿក្តីចំនួនទឹកប្រាក់តិច ដែលច្បាប់កំណត់អំពីទឹកប្រាក់ដែលជាកម្មវត្ថុនៃបណ្តឹងគឺ ១.០០០.០០០ រៀល និង របៀបនៃការដោះស្រាយ រួមជាមួយគោលគំនិតរបស់នីតិវិធីនេះ ។ ការដែលច្បាប់បានកំណត់នីតិវិធីបែបនេះ គឺ មានគោលបំណងជួយដោះស្រាយវិវាទជូនដល់ប្រជាពលរដ្ឋដែលមានវិវាទទៅលើចំនួនទឹកប្រាក់តិចនេះ ម្យ៉ាងទៀត វិវាទរឿងក្តីប្រភេទនេះភាគច្រើនកើតមានតែចំពោះប្រជាជនដែលមានជីវភាពក្រីក្រ និង មិនសូវមានការយល់ដឹងខាងផ្នែកច្បាប់នោះទេ ជាភាគច្រើនជាប្រជាជនរស់នៅតំបន់ដាច់ស្រយាល ។ ច្បាប់បានធ្វើការកំណត់បែបនេះ គឺ វាផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនចំពោះប្រជាពលរដ្ឋ និង តុលាការផងដែរ ។ ការដែលច្បាប់កំណត់បែបនេះ វាធ្វើឱ្យមានទំនាក់ទំនងកាន់តែជិតស្និត រវាងស្ថាប័នតុលាការ ជាមួយប្រជាពលរដ្ឋ ។ ហើយនាពេលបច្ចុប្បន្ននេះ គ្រប់តុលាការទាំងអស់នៅក្នុងប្រទេសកម្ពុជា មិនទាន់បានទទួលពាក្យបណ្តឹង និង ដោះស្រាយ ចំពោះវិវាទ នៃរឿងក្តីចំនួនទឹកប្រាក់តិចនេះនៅឡើយទេ ដោយហេតុថា នីតិវិធីបណ្តឹងនេះ មិនត្រូវទាន់បានប្រជាពលរដ្ឋ ឬ អ្នកច្បាប់មួយចំនួន បានយល់ដឹងពីអត្ថប្រយោជន៍របស់វានៅឡើយទេ ។ ការដែលសរសេរសារណា អំពីប្រធានបទនេះ គឺ ចង់ធ្វើការផ្សព្វផ្សាយ ឱ្យមានការយល់ដឹងអំពីនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិចនេះ លើសពីនេះទៅទៀត គឺ ចង់ឱ្យប្រជាពលរដ្ឋ និង អ្នកច្បាប់លើកយកនីតិវិធីនេះមកប្រើប្រាស់ព្រោះវាមានភាពឆាប់រហ័ស និង ចំណេញពេលវាលា និង ថវិការចំពោះភាគី រួមជាមួយស្ថប័ន្នតុលាការផងដែរ នេះវាកត្តាជំរុញឱ្យកើតមានគំនិតសរសេរសារណាទៅ លើ ប្រធានបទ នីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច នេះឡើងមក ។

# ឯកសារយោង

## ❖ ឯកសារជាភាសាខ្មែរ

១-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

៣-ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

៤-ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

៦-សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ភាគ១ ស្តីពីនីតិវិធីបណ្តឹង ឆ្នាំ២០០៨

៧-សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

# ឧបសម្ព័ន

# ឧបសម្ព័ន១

**លក្ខណៈខុសគ្នារវៀងនីតិវិធីបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច និង នីតិវិធីនៃបណ្តឹងធម្មតា**

| នីតិវិធីនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិច | នីតិវិធីនៃបណ្តឹងលើអង្គសេចក្តីធម្មតា |
|---|---|
| ១ . នីតិវិធីនៃបណ្តឹងរឿងចំនួនទឹកប្រាក់តិច គឺជានីតិវិធីដែលមានគោលបំណងដោះស្រាយវិវាទ ឱ្យមានភាពឆាប់រហ័ស និង សង្ខេប ។ | ១.ជានីតិវិធីនៃបណ្តឹងដែលមានគោលបំណងតុលាការត្រូវប្រឹងប្រែងដើម្បីរ៉ាបរងបណ្តឹងឱ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌និងឆាប់រហ័ស. |
| ២. ជានីតិវិធីបណ្តឹងដែលមានជម្រើស ពីរ នៅក្នុងដាក់ពាក្យបណ្តឹង គឺ អាចធ្វើជាលាយល័ក្ខណ៍-អក្សរ ឬ អាច ដាក់ពាក្យបណ្តឹងដោយផ្ទាល់មាត់បាន ។ | ២. ជានីតិវិធីបណ្តឹងដែលមានល័ក្ខខណ្ឌ មួយជាកំណត់ដាច់ខាត នៅក្នុងការដាក់ពាក្យបណ្តឹង គឺ បណ្តឹង ត្រូវតែធ្វើជាលាយល័ក្ខណ៍អក្សរទើបច្បាប់ទទួលស្គាល់ ថាត្រឹមត្រូវ ។ |
| ៣ . អ្នកតំណាងដោយអាណាត្តិ គឺ មិនចាំបាច់ទាល់តែជាមេធាវីនោះទេ ឱ្យតែមានការអនុញ្ញាតិពីតុលាការជាការគ្រប់គ្រាន់ ។ | ៣ . ចំពោះអ្នកតំណាងដោយអាណាត្តិ គឺចាំបាច់ទាល់តែជាមេធាវីទើបច្បាប់ មានការអនុញ្ញាតិឱ្យ ធ្វើជាអ្នកតំណាងដោយអាណាត្តិ ។ |
| ៤ . ជានីតិវិធីបណ្តឹងដែល ច្បាប់ហាមឃាត់មិនធ្វើ នីតិវិធីផ្សះផ្សា នៅក្នុងនីតិវិធីត្រៀម ។ | ៤ . ជានីតិវិធីបណ្តឹងដែល ច្បាប់បើកសិទ្ធិអោយតុលាការមានការធ្វើ នីតិវិធីផ្សះផ្សា នៅក្នុងនីតិវិធីត្រៀម ឬនៅគ្រប់តំណាក់កាលនៃនីតិវិធីបណ្តឹង។ |
| ៥ . ជានីតិវិធីបណ្តឹងដែល ច្បាប់ហាមឃាត់មិនធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។ | ៥ . ជានីតិវិធីបណ្តឹងដែល ច្បាប់ហាមឃាត់មិនធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ។ |
| ៦ . ជានីតិវិធីបណ្តឹង ដែលច្បាប់មានការរិតត្បិតនៅក្នុង ការពិនិត្យភស្តុតាង គឺ ការពិនិត្យភស្តុតាងអាចធ្វើបានតែភស្តុតាងដែរអាចត្រូវបានពិនិត្យភ្លាមៗ ឬជាសេចក្តីបញ្ជាក់ដំបូង នៅពេលទាញហេតុផលផ្ទាល់មាត់តែប៉ុណ្ណោះ ។ | ៦ . ជានីតិវិធីបណ្តឹង ដែលមិនមានការរិតត្បិតនៅក្នុង ការពិនិត្យភស្តុតាងទេ គឺ អាចដាក់ភស្តុតាងឱ្យតុលាការ ពិនិត្យចាប់តាំងពីនីតិវិធីត្រៀមទាញហេតុផល រហូតដល់ ពេលទាញហេតុផលផ្ទាល់មាត់ តែការដាក់ភស្តុតាងនោះកុំឱ្យតែមានការយឺតយ៉ាវដល់នីតិវិធី ។ |

| | |
|---|---|
| ៧ . ភាគីមិនចាំបាច់ដាក់ឯកសារកំណត់អំពីចំណុចដែរត្រូវសាកសួរឡើយ នៅពេលដែលស្នើសុំសាកសួរសាក្សី ។ សាក្សីដែលបានសាកសួរនោះមិនចាំបាច់ធ្វើសម្បថ ឡើយ ។ | ៧ . ភាគី ចាំបាច់ដាក់ឯកសារកំណត់អំពីចំណុចដែរត្រូវសាកសួរ នៅពេលដែលស្នើសុំសាកសួរសាក្សី ។ សាក្សីដែលបានសាកសួរនោះ ចាំបាច់ត្រូវតែធ្វើសម្បថ ឡើយ ។ |
| ៨ . ជានីតិវិធីបណ្តឹង ដែលការទាញហេតុផលដោយផ្ទាល់មាត់ ធ្វើបានតែមួយដង ។ និង ត្រូវចេញសាលក្រមភ្លាមៗ នៅក្រោយពេលដែលធ្វើការទាញហេតុផលដោយផ្ទាល់មាត់នោះបញ្ចប់។ | ៨ . ជានីតិវិធីបណ្តឹង ដែលការទាញហេតុផលដោយផ្ទាល់មាត់ អាចធ្វើបានច្រើនមួយដងបើសិនជាចាំបាច់ ។ និង មានរយៈពេលកំណត់ស្រាប់ការប្រកាសសាលក្រមនៅក្រោយពេលដែលធ្វើការទាញហេតុផលដោយផ្ទាល់មាត់នោះបានបញ្ចប់ ។ |
| ៩ . ជានីតិវិធីបណ្តឹងដែលច្បាប់បានធ្វើការហាមឃាត់ ចំពោះភាគីនៅក្នុងការធ្វើបណ្តឹងឧបាស្រ័យ ទៅតុលាការជាន់ខ្ពស់ចំពោះការមិនសុកចិត្ត ទៅនិងសេចក្តីសម្រេចរបស់សាលាដំបូង ។ | ៩ . ជានីតិវិធីបណ្តឹងដែលច្បាប់បើកសិទ្ធិឱ្យភាគី អាចធ្វើបណ្តឹងឧបាស្រ័យ ទៅតុលាការជាន់ខ្ពស់ចំពោះការមិនសុខចិត្ត និងសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមបាន ។ |
| ១០ . មានការហាមឃាត់ ចំពោះភាគីនៅក្នុងការធ្វើបណ្តឹងតប ។ | ១០ . បើកសិទ្ធិឱ្យភាគីមានការ ធ្វើបណ្តឹងតបបើបណ្តឹងតបនោះវាមានប្រយោជន៍ចំពោះខ្លួនមិនធ្វើឱ្យយឺតយ៉ាវដល់នីតិវិធី។ |
| ១១ . ការអនុវត្ត ដោបង្ខំចំពោះនីតិវិធីរឿងក្តីចំនួនទឹកប្រាក់តិច គឺ មិនទាមទារឱ្យមាននូវ រូបមន្តអនុ-វត្ត ដើម្បីធ្វើជា ល័ក្ខខណ្ឌ ចាំបាច់សម្រាប់ធ្វើការអនុវត្តដោយបង្ខំនោះទេ ។ | ១១ . ការអនុវត្ត ដោយបង្ខំចំពោះនីតិវិធីនៃបណ្តឹងធម្មតា គឺ ទាមទារឱ្យមាននូវ រូបមន្តអនុវត្ត ដើម្បីធ្វើជា ល័ក្ខខណ្ឌ ចាំបាច់សម្រាប់ធ្វើការអនុវត្តដោយបង្ខំ ។ |
| ១២ . នៅក្នុងនីតិវិធីនៃរឿងក្តីចំនួនទឹកប្រាក់តិច ការវិនិច្ឆ័យ គឺ ត្រូវតែធ្វើការជំនុំជម្រះដោយចៅក្រមមួយរូប ។ | |

# សារាចរ

# ស្តីពី

# សេចក្តីណែនាំអំពីនីតិវិធីរដ្ឋប្បវេណី

**សាធារណរដ្ឋប្រជាមានិតកម្ពុជា**

**ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល**

ទីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធមិ

លេខ : ០៤ សរច ៨៤ ភ្នំពេញថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ១៩៨៤

**សារាចរ**

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ជំរាបមក**

សមមិត្តប្រធានតុលាការប្រជាជនខេត្ត ក្រុង

សមមិត្តរដ្ឋអាជ្ញាអមតុលាការប្រជាជនខេត្ត ក្រុង

**កម្មវត្ថុ :** សេចក្តីណែនាំអំពីនីតិវិធីរដ្ឋប្បវេណី

ក្នុងរយៈពេលជាងពីរឆ្នាំកន្លងមកនេះ អយ្យការ និងតុលាការប្រជាជនខេត្ត ក្រុង បានដំណើរការ និងបានអនុវត្តភារកិច្ចរបស់ខ្លួនប្រកបដោយជោគជ័យ ។ ក្នុងវិស័យព្រហ្មទណ្ឌ ការចោទប្រកាន់ និងការបើកសវនាការជំនុំជំរះ បាននាំមកនូវឥទ្ធិពលយ៉ាងល្អប្រពៃ ក្នុងការរួមចំណែកការពារ និងកសាងមាតុភូមិ ជាពិសេសក្នុងការការពារសន្តិសុខសង្គម របៀបរៀបរយសាធារណៈ ការពារទ្រព្យសម្បត្តិរដ្ឋ ការពារអាយុជីវិត និងទ្រពសម្បត្តិស្របច្បាប់របស់ពលរដ្ឋ ។

ក្នុងវិស័យរដ្ឋប្បវេណី អាពាហ៍ពិពាហ៍ និងគ្រួសារ តុលាការប្រជាជនខេត្ត ក្រុងក៏បានដំណើរការផ្សះផ្សារគូភាគីឱ្យជានា និងគ្នាឡើងវិញ បានជាច្រើនរឿង សំដៅធ្វើឱ្យប្រជាជនមានសាមគ្គីភាព ឯកភាពគ្នា រួមកំលាំងគ្នាជំរុញការបង្កបង្កើនផល និងថែរក្សាស្ថេរភាពនៃការរស់នៅរបស់ខ្លួន ។

ប៉ុន្តែទទ្ទឹម និងលទ្ធផលដ៏ប្រពៃដែលអយ្យការ និងតុលាការប្រជាជនខេត្ត ក្រុង ដណ្តើមបាននោះ ក្រសួងយុត្តិធមិក៏បានមើលឃើញការលំបាក និងភាពស្មុគស្មាញមួយចំនួន ក្នុងការងាររបស់តុលាការប្រជាជន ផ្នែករដ្ឋប្បវេណីដែរ ។ តុលាការប្រជាជនផ្នែករដ្ឋប្បវេណី ពុំទាន់បានបើកសវនាការជំនុំជំរះរឿងរដ្ឋប្បវេណី រឿងអាហ៍ពិពាហ៍ និងគ្រួសារឡើយ ធ្វើឱ្យរឿងប្រភេទនេះដែលផ្សះផ្សារពុំបានសំរេចនោះ នៅសល់កាន់តែច្រើនឡើង ៗ ។ បាតុភាពនេះបើមានតទៅទៀតជាហេតុមួយនាំអោយប្រជាជន ថ្នាំងថ្នាក់ចិត្ត និងអស់ជំនឿលើតុលាការប្រជាជន ក្នុងដំណោះស្រាយរឿងទំនាស់របស់គេ ។

ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងយុត្តិធមិសំរេចចេញសេចក្តីណែនាំអំពីនីតិវិធីរដ្ឋប្បវេណី ដែលមានដូចខាងក្រោមនេះ :

**I.អំពីការផ្សះផ្សា :**

ក្រោយពីបានទទួលបណ្តឹងពីសាម៉ីជនដោយផ្ទាល់ ឬពីអង្គការយុត្តិធមិមូលដ្ឋាន ឬអង្គការណាមួយ ប្រធានតុលាការត្រូវចាត់អោយចុះបណ្តឹងនោះ ក្នុងសៀវភៅទទួលបណ្តឹង ។ ប្រធានតុលាការត្រូវពិនិត្យមើល ថាតើរឿងដែលប្តឹងនោះស្ថិត

នៅក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួនដែរ ឬទេ ?

ប្រសិនបើរឿងនោះមានលក្ខណៈជារឿងរដ្ឋបាល ត្រូវផ្ទេររឿងនោះទៅឱ្យអង្គការរដ្ឋបាល ដែលមានសមត្ថកិច្ចដើម្បីដោះស្រាយ ។

ប្រសិនបើរឿងនោះ មានលក្ខណៈជារឿងព្រហ្មទណ្ឌ ត្រូវផ្ទេររឿងនោះទៅឱ្យអយ្យការ ដើម្បីដោះស្រាយ ។

ប្រសិនបើបណ្តឹងនោះ មានលក្ខណៈជារឿងរដ្ឋប្បវេណី ឬអាពាហ៍ពិពាហ៍ និងគ្រួសារ ប្រធានតុលាការត្រូវចាត់ឱ្យចៅក្រមម្នាក់ ទទួលបន្ទុកពិនិត្យសំណុំរឿង ដើម្បីធ្វើការផ្សះផ្សាជាបន្ទាន់ ។ ភារកិច្ចផ្សះផ្សារនេះ ប្រធានតុលាការត្រូវធ្វើដោយខ្លួនឯង កាលបើពិនិត្យឃើញថា ជាការចាំបាច់ ។

នៅថ្ងៃកំណត់ធ្វើការផ្សះផ្សារ ប្រសិនបើភាគីម្ខាងមិនបានទទួលលិខិតអញ្ជើញនោះ គឺត្រូវអញ្ជើញភាគីទាំងអស់ឱ្យចូលមកសាជាថ្មីម្តងទៀត នៅថ្ងៃណាមួយផ្សេងទៀត ។

ប្រសិនបើដើមចោទ បានទទួលលិខិតអញ្ជើញហើយ ហើយមិនបានចូលមកដោយគ្មានមូលហេតុចំនួន ២លើកនោះ ត្រូវចាត់ទុកថាភាគីនេះបោះបង់បណ្តឹងរបស់ខ្លួន ។ ក្នុងករណីនេះចៅក្រម ត្រូវធ្វើដីកាចំណាយរឿងចេញពីបញ្ជី ។

នៅថ្ងៃកំណត់ធ្វើការផ្សះផ្សាបើភាគីទាំងអស់បានចូលមក ចៅក្រម ត្រូវណែនាំសំរុះសំរួលយ៉ាងឱ្យគូភាគីបានជា និងគ្នាវិញ ដោយវិចារណញ្ញាណ ។ ណែនាំអោយគូភាគីមើលឃើញនូវផលវិបាកទាំងឡាយ ដែលកើតចេញមកពីការទាស់ទែងគ្នា ការបាក់បែកសាមគ្គី និងការខាតពេលវេលា និងផលប្រយោជន៍ក្នុងការបន្តរឿងក្តីវែងអន្លាយតទៅទៀត ។

ចៅក្រម មិនត្រូវធ្វើការគៀបសង្កត់ គំរាមកំហែង ឬបង្ខិតបង្ខំអោយភាគីណាមួយសំរេចចិត្តយ៉ាងនេះ ឬយ៉ាងនោះឡើយ ។ ក្នុងការផ្សះផ្សា ដាច់ខាតត្រូវអោយស្របច្បាប់ផងដែរ ។ ការផ្សះផ្សារមិនស្របច្បាប់ត្រូវហាមឃាត់ ឧទាហរណ៍- អ្នកលេងបៀឈ្នះ ប្តឹងអោយអ្នកលេងចាញ់សងប្រាក់មកអោយខ្លួន ឬការប្តឹងលែងលះគ្នា ប្តីសុំអោយប្រពន្ធប្រគល់កូននៅបៅដោះ មកឱ្យខ្លួនចិញ្ចឹម ។ ករណីទាំងនោះតុលាការ មិនត្រូវដោះស្រាយទេ ។

ជាពិសេស ក្នុងដំណាក់ការផ្សះផ្សា ចៅក្រមមិនត្រូវពិនិត្យដល់អង្គសេចក្តីនៃរឿងទេ បានន័យថាមិនត្រូវពិនិត្យរកហេតុផល រកភស្តុតាង ថាភាគីនេះត្រូវឈ្នះ ភាគីនោះត្រូវចាញ់ឡើយ ។

ក្នុងការផ្សះផ្សា ទោះជាបានសំរេចក្តី មិនបានសំរេចក្តី ត្រូវតែធ្វើកំណត់ហេតុចុះទាំងស្រុងក្នុងសៀវភៅកំណត់មួយពិសេស សំរាប់ការផ្សះផ្សា ។

បើគូភាគីយល់ព្រមជានិងគ្នាវិញ នោះកំណត់ហេតុ ត្រូវបញ្ជាក់អោយបានត្រឹមត្រូវនូវកិច្ចសន្យា ដែលគូភាគីទទួលយល់ព្រម ពីព្រោះកិច្ចសន្យានេះចងភ្ជាប់គូភាគីកុំអោយប្រកែកកែប្រែបាន ។ ចៅក្រម ត្រូវចេញដីកាសំរេចលាតត្រដាងឡើងវិញនូវកិច្ចសន្យានោះ ។ ដីកានោះមានតម្លៃស្មើ និងសាលក្រមស្ថាពរដែរ ។

បើគូក្តីមិនព្រមជានិងគ្នា ឬ បើចុងចម្លើយបានទទួលលិខិតអញ្ជើញហើយ ហើយមិនបានចូលខ្លួនមកដោយគ្មានមូលហេតុ ចំនួនពីរលើក នោះចៅក្រមត្រូវចាត់អោយធ្វើកំណត់ហេតុពីករណីនេះ ដាក់ចូលក្នុងសំណុំរឿង ហើយត្រូវចាត់វិធានការធ្វើការស៊ើបអង្កេតស៊ើបសួរ គឺត្រូវចាត់ចែងរៀបចំសំណុំរឿងឱ្យបានសព្វគ្រប់មុននឹងដាក់រឿងនោះទៅជំនុំជំរះ ។

ចំពោះរឿងលែងលះគ្នា ការផ្សះផ្សា ត្រូវធ្វើនីតិវិធី ដែលមានចែងក្នុងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារនៅពេលដែល

ច្បាប់នេះចូលជាធរមាន ។

នៅពេលសវនាការ មុនពេលជំនុំជំរះដល់អង្គសេចក្តីនៃរឿង តុលាការអាចធ្វើការផ្សះផ្សាម្តងទៀតបាន ។

ក្នុងរឿងខ្លះដែលមានភាគីតែម្ខាង គឺមានតែដើមបណ្តឹង ដូចជាបណ្តឹងសុំកែប្រែ ឬសុំចុះកំណើត សុំកែប្រែ ឬសុំចុះមរណភាព ប្តឹងសុំសាលក្រមប្រកាសបាត់ខ្លួន នៃសហព័ទ្ធជាដើម តុលាការមិនបាច់ធ្វើការផ្សះផ្សាទេ តុលាការត្រូវចេញសាលក្រមសំរេចតែម្តង ។

ត្រូវកត់សំគាល់ថា មុននឹងធ្វើការអង្កេតស៊ើបសួរ ត្រូវបង្គាប់អោយដើមចោទបង់ប្រាក់ក្រឡាក្រម ដែលនឹងកំណត់ក្នុងច្បាប់ ។

## II.**អំពីការអង្កេតស៊ើបសួរ :**

បើការផ្សះផ្សាពុំអាចប្រព្រឹត្តទៅបាន ឬបានប្រព្រឹត្តទៅ តែពុំបានទទួលផល ចៅក្រមត្រូវធ្វើការអង្កេតស៊ើបសួរ និងពិនិត្យឱ្យបានល្អិតល្អន់ អំពីខ្លឹមសារនៃរឿង និងនីតិវិធីចាំបាច់ក្នុងការដោះស្រាយ ។ ការអង្កេតស៊ើបសួរ ក្នុងនីតិវិធីរដ្ឋប្បវេណី មានលក្ខណៈខុសប្លែកពីការអង្កេតស៊ើបសួរ ក្នុងនីតិវិធីព្រហ្មទណ្ឌ ។ ក្នុងរឿងព្រហ្មទណ្ឌ គឺស្ថាប័នសន្តិសុខ នគរបាល អយ្យការ ជាអង្គការទទួលបន្ទុកធ្វើការអង្កេតស៊ើបសួរ ។

រីឯក្នុងរឿងរដ្ឋប្បវេណី ចៅក្រមជាអ្នកទទួលបន្ទុកធ្វើការអង្កេតស៊ើបសួរស្រាវជ្រាវរកគ្រប់ភស្តុតាង និងមូលដ្ឋានច្បាប់ ដើម្បីរៀបចំសំណុំរឿងនោះទៅជំនុំជំរះ ។ បញ្ហានេះអាចនាំឱ្យមានបាតុភាពមួយខាងសតិអារម្មណ៍កើតឡើង គឺចៅក្រមច្រើនមើលស្រាលក្នុងការពិនិត្យឡើងវិញនូវនីតិវិធី និងខ្លឹមសារនៃរឿង ដោយទុកចិត្តថា ក្នុងពេលផ្សះផ្សា ខ្លួនបានពិនិត្យគ្រប់ជ្រុងជ្រោយហើយ ។ ដើម្បីចៀសវាងនូវបាតុភាពនេះ ត្រូវយកចិត្តទុកដាក់លើបញ្ហាដូចខាងក្រោមនេះ :

១-ចៅក្រម ត្រូវមើលអំពីទំនាក់ទំនងគតិយុត្ត រវាងដើមចោទ និងចុងចម្លើយ ដូចជាក្នុងរឿងអាពាហ៍ពិពាហ៍ត្រូវកំណត់អោយច្បាស់ អំពីចំណងទាក់ទងបុរស និងស្ត្រី ដែលប្តឹងសុំចប់សមគ្គសង្វាសគ្នា ថាតើបុរស និងនារីនោះមានចំណងអាពាហ៍ពិពាហ៍ឬទេ? និងអំពីចំណងទាក់ទង រវាងឪពុក ឬម្តាយជាមួយ និងកូន ។ ទន្ទឹមនឹងនោះក៏ត្រូវកំណត់ឱ្យច្បាស់អំពីទំនាក់ទំនងក្នុងវិស័យទ្រព្យសម្បត្តិថែមទៀត ។

ការកំណត់ទំនាក់ទំនងគតិយុត្តិក្នុងរឿងរដ្ឋប្បវេណី មានសារៈសំខាន់ ក្នុងពេលអង្កេតស្រាវជ្រាវ ធ្វើសំណុំរឿងឱ្យគ្រប់ជ្រុងជ្រោយ ក៏ដូចជាក្នុងពេលជំនុំជំរះ ពីព្រោះដោយផ្អែកលើកត្តានេះហើយ ដែលចៅក្រម ឬតុលាការអាចប្រមូលរកភស្តុតាងជាមូលដ្ឋានបាន ដើម្បីដោះស្រាយរឿងនោះឱ្យបានត្រឹមត្រូវ ។

២-ក្រោយពីបានកំណត់ទំនាក់ទំនងគតិយុត្តិហើយ ចៅក្រម ត្រូវចាត់ឱ្យលេខាធិការក្រឡាបញ្ជីកោះអញ្ជើញភាគី និងសាក្សីទាំងឡាយ មកបង្ហាញខ្លួន ហើយសួរយកចម្លើយពីជនទាំងនោះ ។ ទន្ទឹមនឹងនេះ ក៏ត្រូវជូនដំណឹងដល់មេធាវីរបស់គូភាគីផងដែរ អំពីវិធានការស៊ើបសួរ ហើយមេធាវីនោះមានសិទ្ធិ ចូលរួមក្នុងការអង្កេតស៊ើបសួរគ្រប់ពេលវេលា និងមានសិទ្ធិប្តឹងជំនួសកូនក្តីបាន បើកូនក្តីបានប្រគល់សិទ្ធិនេះឱ្យខ្លួន ។ មេធាវី អាចជូនសេចក្តីសន្និដ្ឋាន និងសារណាទាំងឡាយចាប់តាំងពីពេលដែលគូក្តីបានពឹងខ្លួន រហូតដល់ពេលបញ្ចប់ការសួរដេញដោលមុនពេលចេញសាលក្រម ។

តាំងពីពេលដាក់ពាក្យបណ្តឹងរហូតដល់ពេលដេញដោល ដើមបណ្តឹងមានសិទ្ធិបន្ថែម ឬបន្ថយពាក្យបណ្តឹងរបស់ខ្លួន ។

រីឯចុងចម្លើយក៏មានសិទ្ធិដាក់ពាក្យប្តឹងតបវិញដែរ  ប៉ុន្តែបណ្តឹងតបនេះ  ត្រូវមានទំនាក់ទំនងគ្នា  និងបណ្តឹងដើមមានមូលហេតុក្នុងបណ្តឹងដើម ឬជាមធ្យោបាយការពារទល់ និងបណ្តឹងដើម ។

ក្នុងការធ្វើកំណត់ហេតុផ្សះផ្សាក៏ដូចជាការស្រង់ចម្លើយរបស់ភាគី  ឬសាក្សីនៅពេលអង្កេតស៊ើបសួរ  ត្រូវសរសេរឱ្យច្បាស់  គ្មានការឆូតលុប ហើយជួសបន្ថែមពាក្យឡើយ ។

បើលុប  ឬបន្ថែមពាក្យ  ត្រូវដាក់និទ្ទេស  "យល់ព្រម"  ឬ"  យល់ព្រមបន្ថែម"  រួចចៅក្រមលេខាធិការក្រឡាបញ្ជី និងជន ដែលបានឆ្លើយ ត្រូវចុះហត្ថលេខានៅក្រោមនិទ្ទេសនេះ ។

ការអង្កេតស៊ើបសួរ  ត្រូវធ្វើចំពោះមុខគូភាគី  និងចំពោះមុខអ្នកការពាររបស់គូភាគីប្រសិនបើមាន  ។ ត្រូវសួរសាក្សីម្នាក់ម្តង ទោះចំពោះមុខគូភាគីក្តី កំបាំងមុខក្តី ។

ក្នុងការចាំបាច់ ដើម្បីរកការពិត ចៅក្រម អាចសួរចម្លើយតទល់រវាងសាក្សី ឬរវាងភាគី និងសាក្សីបាន ។

៣-ចៅក្រម  ត្រូវបង្គាប់ឱ្យដាក់ចូលក្នុងសំណុំរឿង  នូវលិខិតទាំងឡាយដែលមានប្រយោជន៍  ដើម្បីបំភ្លឺតុលាការ  ។ ចៅក្រម ត្រូវពិនិត្យមើលតែភស្តុតាងទាំងឡាយ ដែលគូក្តីជូនមកអាងនោះ គ្រប់គ្រាន់ហើយឬនៅ?  ។ បើពិនិត្យឃើញថា ភស្តុតាងនោះនៅមានខ្វះចន្លោះត្រង់ចំណុចណាមួយ   នោះចៅក្រមគប្បីចាត់ការអង្កេតស្រាវជ្រាវថែមទៀត   ឬក៏ចាត់ឱ្យភាគីដែលលើកបញ្ហាណាមួយមកអាងនោះ យកភស្តុតាងមកដាក់ក្នុងសំណុំរឿងក៏បាន ។

បើក្នុងសំណុំរឿងមានកើតបញ្ហាដែលជាចាំបាច់ត្រូវមានអ្នកជំនាញជួយពិនិត្យវិភាគ    និងកំណត់នោះចៅក្រមគប្បីចាត់តាំងអោយមានអ្នកជំនាញ ធ្វើកោសល្យវិច័យបញ្ជាក់ជាលាយលក្ខអក្សរ និងចុះហត្ថលេខាត្រឹមត្រូវ ។ លទ្ធផលនៃការសន្និដ្ឋានរបស់អ្នកជំនាញក្នុងលិខិតកោសល្យវិច័យ  ពុំមែនជាកត្តាកំណត់  ដែលចៅក្រម  ឬតុលាការប្រជាជន  ត្រូវតែសំរេចតាមនោះទេ   ។  ចៅក្រមទទួលបន្ទុកអង្កេតស៊ើបសួរ   អាចចាត់តាំងឱ្យមានអ្នកជំនាញផ្សេងទៀតធ្វើកោសល្យវិច័យថែមកាលបើចៅក្រមយល់ឃើញថា ការសន្និដ្ឋានក្នុងលិខិតកោសល្យវិច័យមុន នៅមានភាពពុំទាន់ច្បាស់លាស់ ។

ក្នុងរយៈពេលស៊ើបអង្កេតស្រាវជ្រាវភស្តុតាង  ចៅក្រមចាំបាច់ត្រូវពិនិត្យយ៉ាងល្អិតល្អន់លើវត្ថុ  (ឯកសារ  សំបុត្រ  ឬវត្ថុផ្សេងៗ)  ចំលើយរបស់ភាគីចម្លើយរបស់សាក្សី  លិខិតកោសល្យវិច័យ  និងឯកសារដទៃទៀត  ដែលអង្គការរដ្ឋ  ឬអង្គការមហាជនផ្ញើ និងប្រគល់អោយ  ។

ភស្តុតាងនីមួយៗ ត្រូវយកមកប្រៀបធៀបនឹងភស្តុតាងឯទៀត ដើម្បីវាយតម្លៃសរុបអោយឃើញថា ភស្តុតាងទាំងនោះ  បានស្របនិងគ្នាហើយ   ហើយបញ្ជាក់អោយឃើញការពិតគ្រប់ជ្រុងជ្រោយប្រាកដមែន   ។  ប្រសិនបើភស្តុតាងទាំងអស់ដែលប្រមូលបានក្នុងសំណុំរឿងនៅមិនទាន់ច្បាស់ត្រង់ចំណុចណាមួយនោះ ចៅក្រមអាចធ្វើការអង្កេតបន្ថែម ដោយចុះទៅដល់ទីកន្លែងកើតហេតុ ដើម្បីរកអោយឃើញភាពជាក់ស្តែងថែមទៀត ។

៤-ក្រោយពិនិត្យលើភស្តុតាងសព្វគ្រប់ហើយ  ចៅក្រម  ត្រូវយកភស្តុតាងទាំងនោះ និងសំណូមពររបស់គូភាគីធ្វើជាមូលដ្ឋាន    ហើយស្រាវជ្រាវរកមើលតើមូលដ្ឋាននោះសមស្របតាមច្បាប់កំណត់    តាមគោលនយោបាយរបស់បក្សដែរឬទេ?  ក្នុងករណីនេះ  ចៅក្រមត្រូវយកអត្ថបទដែលមានចែង  អំពីបញ្ហានៃរឿងនោះ  មកពិនិត្យយ៉ាងល្អិតល្អន់  គឺត្រូវជៀសវាងកុំអាងទៅលើការចាំរបស់ខ្លួន ឬទំលាប់របស់ខ្លួន ដែលបានធ្វើពីមុនមក ។

៥-ក្រោយពីអង្កេតស៊ើបសួរចម្លើយចប់សព្វគ្រប់ហើយ ចៅក្រមត្រូវធ្វើរបាយការណ៍ភ្ជាប់ជាមួយសំណុំរឿង បញ្ជូនទៅតុលាការជំនុំជំរះ ។

ប្រធានតុលាការ ត្រូវចេញដីកា ចាត់តាំងចៅក្រមម្នាក់ ឬចាត់តាំងខ្លួនឯងធ្វើជាប្រធានក្រុមប្រឹក្សាជំនុំជំរះ ។

## III.អំពីការត្រៀមបំរុង មុននឹងដាក់សំណុំរឿងជំនុំជំរះ

ចៅក្រម ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ មានភារកិច្ចដូចតទៅ :

### ១.-ការសុំយោបល់ពីតំណាងអយ្យការ

ចៅក្រម ត្រូវដាក់ជូនរដ្ឋអាជ្ញា ពិនិត្យ និងផ្តល់យោបល់ជាលាយលក្ខណ៏អក្សរនូវសំណុំរឿងទាំងឡាយដែលទាក់ទងដល់របៀបរៀបរយសាធារណៈ ឬទ្រព្យសម្បត្តិរដ្ឋ ជាប់ជំពាក់ដល់ផលប្រយោជន៏អនីតិជន ឬអសមត្ថជន ។ ក្នុងករណីនេះ រដ្ឋអាជ្ញា ត្រូវធ្វើអន្តរាគមន៍ដោយតាំងខ្លួនជាគូក្តីដើម ហើយចាំបាច់ត្រូវចូលរួមក្នុងសវនាការ ។

ក្រៅពីសំណុំរឿងខាងលើនេះ ចៅក្រម ត្រូវដាក់ជូនរដ្ឋអាជ្ញាផងដែរ នូវសំណុំរឿងណាមួយ ដែលរដ្ឋអាជ្ញាសុំយកមកពិនិត្យ និងធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៏អក្សរលើរឿងនោះ ។

ចំពោះរឿងណាដែលចៅក្រម ឃើញថាមានលក្ខណៈជារឿងព្រហ្មទណ្ឌនោះចៅក្រម ត្រូវផ្ទេររឿងមកអោយអយ្យការ ដើម្បីធ្វើការចោទប្រកាន់ ។

ប៉ុន្តែតំណាងអយ្យការ ក្រោយពីបានពិនិត្យសំណុំរឿង ឃើញថារឿងនេះមានលក្ខណៈជារឿងរដ្ឋប្បវេណី ឬរឿងគ្រួសារទៅវិញ នោះអង្គការទាំងពីរត្រូវលើកមតិមិនឯកភាពគ្នានោះ ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ពិនិត្យ និងសំរេច ។

### ២.ការសំរេចយករឿងដាក់ជំនុំជំរះ

ក-បន្ទាប់ពីបានបំពេញភារកិច្ចខាងលើសព្វគ្រប់ហើយ ចៅក្រម ត្រូវចេញដីកា សំរេចដាក់រឿងទៅជំនុំជំរះក្នុងដីការនោះ ត្រូវសរសេរឱ្យច្បាស់ :

-នាមត្រកូល អាយុ របររកស៊ី និងអាស័យដ្ឋាន របស់គូភាគី (ដើមចោទ និងចុងចម្លើយ) និងកម្មវត្ថុនៃរឿងដូចជាការសុំដាច់សមគ្គសង្វាស ការសុំអោយចិញ្ចឹមអាហារកិច្ច ការសុំអោយសងប្រាក់តាមកិច្ចសន្យា ។ល ។

-ឈ្មោះអ្នកការពារដើមចោទ ឬអ្នកការពារចុងចម្លើយ ប្រសិនបើមាន

-សំណូមពររបស់តុលាការប្រជាជន ដល់តំណាងសហគ្រាស ក្រុមសាមី ឬតំណាងអង្គ ការមហាជនចំពោះរឿងណាដែលតុលាការពិនិត្យឃើញថា ចាំបាច់ត្រូវតំណាងនៃអង្គការទាំងនោះ មកឆ្លើយបំភ្លឺតុលាការ ឬការពារផលប្រយោជន៏របស់អង្គការទាំងនោះ ។

-ឈ្មោះអ្នកជំនាញ ដែលធ្វើកោសល្យវិច័យ ប្រសិនបើមាន ។

-ឈ្មោះអ្នកបកប្រែភាសា ប្រសិនបើមាន ។

-ពេលវេលា និងទីកន្លែងបើកសវនាការ ។

-វត្ថុតាងដែលសាមីជនត្រូវនាំយកមកបង្ហាញតុលាការ នៅពេលសវនាការ ។

-គ្រប់ដីកាសំរេចយករឿងដាក់ជំនុំជំរះ ត្រូវចម្លងមួយសន្លឹកជូនតំណាងអយ្យការដើម្បីជ្រាប ។

ខ- លេខាធិការ-ក្រឡាបញ្ជី ដោយអនុវត្តតាមដីកាខាងលើនេះ ត្រូវធ្វើលិខិតអញ្ជើញជនដែលទាក់ទងក្នុងរឿង ដែលទាក់ទងក្នុងរឿង ឱ្យចូលរួមទាំងអស់ក្នុងសវនាការ ។ លេខធិការ-ក្រឡាបញ្ជី ជៀសវាងកុំអញ្ជើញតាមអត្តនោម័ត របស់ខ្លួន ហើយឈានដល់មានកង្វះ ដូចជាអញ្ជើញសាក្សីមិនគ្រប់ អញ្ជើញសាក្សីមិនចាំបាច់ ឬពុំបានប្រាប់សាមីជនឱ្យយក វត្ថុតាងមកចំពោះមុខតុលាការ នៅពេលសវនាការ ។

គ-ក្នុងលិខិតអញ្ជើញ ត្រូវសរសេរឱ្យច្បាស់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់សាមីជន ហើយត្រូវធ្វើជាពីរច្បាប់ គឺមួយ ច្បាប់ប្រគល់អោយសាមីជន មួយច្បាប់ទៀត អ្នកប្រគល់លិខិតអញ្ជើញ ត្រូវបង្វិលអោយតុលាការវិញដើម្បីដាក់ក្នុងសំណុំ រឿង ។

លិខិតអញ្ជើញ ត្រូវចេញដោយគិតដល់ពេលវេលា ដែលសាមីជនត្រូវទទួល ហើយអាចមកចូលរួមក្នុងសវនាការ បាន ។

ឃ-យោងតាមករណីនីមួយៗ បុគ្គលិករបស់តុលាការ អាចប្រគល់លិខិតអញ្ជើញអោយដល់សាមីជន ឬប្រគល់ ភារកិច្ចរបស់តុលាការ អាចប្រគល់លិខិតអញ្ជើញអោយដល់សាមីជន ឬប្រគល់ភារកិច្ចនោះ អោយទៅសមាជិកយុត្តិធម៌ ឃុំ ឬសង្កាត់ ។ ប្រសិនបើសាមីជនជាកម្មាភិបាល បុគ្គលិក កម្មករ ក្នុងអង្គភាពណាមួយនោះ លិខិតអញ្ជើញអាចផ្ញើទៅ ដល់សាមីជនតាមរយៈប្រធានអង្គភាពនោះ ។

**៣-ការចាត់តាំងទីប្រឹក្សាប្រជាជន :**

ក្រោយពេលចេញដីកាសំរេច ដាក់រឿងទៅជំនុំជំរះចៅក្រមត្រូវចេញដីកាចាត់តាំងទីប្រឹក្សាប្រជាជន ២រូប ក្នុងចំ ណោមទីប្រឹក្សាដែលមានឈ្មោះក្នុងបញ្ជីរាយនាមទីប្រឹក្សាប្រជាជន ។ ទីប្រឹក្សាប្រជាជនទាំងពីររូបនេះត្រូវបានអញ្ជើញ មកពិនិត្យសំណុំរឿងយ៉ាងតិចណាស់ ៣ថ្ងៃ មុនថ្ងៃបើកសវនាការ ដោយមិនគិតថ្ងៃឈប់សំរាក និងថ្ងៃបុណ្យ ។

ចំពោះរឿងណាដែលមានលក្ខណៈស្មុគស្មាញ ចៅក្រមត្រូវអធិប្បាយពន្យល់ទីប្រឹក្សាប្រជាជន អោយបានជ្រាបអំពី ខ្លឹមសារនៃរឿង បញ្ញត្តិ និងគោលនយោបាយរបស់បក្ស ដើម្បីឱ្យទីប្រឹក្សាមានលទ្ធភាពរួមចំណែកក្នុងពេលជំនុំជំរះបានលទ្ធ ភាពល្អប្រសើរ ។

ចំណុចសំខាន់ ចៅក្រមត្រូវចេញណែនាំទីប្រឹក្សាអោយស្គាល់សិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន ដែលមានស្មើ និងចៅក្រម សំដៅពង្រឹងសិទ្ធិធ្វើជាម្ចាស់របស់ប្រជាជន និងពង្រឹងនីត្យានុកូលភាពប្រជាធិបតេយ្យ ។

ជាពិសេសចៅក្រម និងទីប្រឹក្សាប្រជាជន មានកាតព្វកិច្ចរក្សាការសម្ងាត់របស់រដ្ឋ គឺមិនត្រូវឱ្យជនដទៃដឹងនូវរឿង ដែលនឹងត្រូវជំនុំជំរះនោះទេ ។

ចៅក្រម ត្រូវព្រាងសំណួរ សំរាប់សួរបញ្ជាក់ដល់អ្នកចូលរួមក្នុងនីតិវិធីនៅពេលសវនាការខាងមុខ ។

## IV.អំពីការងារនៅពេលសវនាការ

ការបើកសវនការ របស់តុលាការប្រជាជន មានគោលដៅជំនុំជំរះរឿងអោយបានល្អិតល្អន់ និងត្រឹមត្រូវបំផុតតាម បញ្ញត្តិច្បាប់ និងតាមគោលនយោបាយរបស់បក្ស ។ ដូចនេះ នៅពេលសវនាការ តុលាការប្រជាជនត្រូវសួរចម្លើយ អ្នកចូល រួមក្នុងនីតិវិធីទាំងអស់សារឡើងវិញទាំងស្រុង ហើយបង្ហាញភស្តុតាងអោយបានសព្វគ្រប់ដើម្បីផ្អែកលើនោះ តុលាការអាច

នឹងចេញសេចក្តីប្រកាសសាលក្រមមួយ មានលក្ខណៈគ្រប់ជ្រុងជ្រោយ និងត្រឹមត្រូវ ។ ម្យ៉ាងវិញទៀតនៅពេលបើកសវនាការជំនុំជំរះ តុលាការ ត្រូវធ្វើយ៉ាងណាអោយការងារជំនុំជំរះ ក្លាយទៅជាការងារមួយអប់រំដល់សាមីជនផង អប់រំដល់ប្រជាជនទូទៅផង អំពីសម្បជញ្ញៈ អំពីការអនុវត្តន៏ច្បាប់ និងគោលមាគ៌ារបស់បក្ស ។

តុលាការប្រជាជន គួរចៀសវាង និងកុំយល់ច្រឡំថា ខ្លួនបានធ្វើការផ្សះផ្សាជាច្រើនលើក ហើយការអង្កេតស៊ើបសួរក៏បានល្អិតល្អន់ ហើយសំណុំរឿងរៀបចំក៏បានគ្រប់ជ្រុងជ្រោយហើយ ដូច្នេះការបើកសវនាការ គ្រាន់តែជារូបភាពមួយថ្មីកំណត់ការដោះស្រាយប៉ុណ្ណោះ ។ ទស្សនៈភ័ន្តច្រឡំនេះ អាចនាំដល់ការមើលស្រាលលើការសួរដេញដោលនៅពេលសវនារការ ការស្រាវជ្រាវពិនិត្យវត្ថុតាង និងមតិរបស់អ្នកចូលរួមក្នុងនីតិវិធីដូចជាមតិរបស់តំណាងអង្គការរដ្ឋ អង្គការសង្គម ឬ របស់អ្នកជំនាញ ។ នៅពេលសវនាការប្រធានក្រុមប្រឹក្សាជំនុំជំរះជាប្រធានសវនាការ ។ មានន័យថា ប្រធានក្រុមប្រឹក្សាជំនុំជំរះ មានអំណាចឆន្ទានុសិទ្ធិក្នុងការដឹកនាំសវនាការ គឺធានាអោយបានសណ្តាប់ធ្នាប់ក្នុងសវនាការ ។ បើមានជនណាម្នាក់ប្រព្រឹត្តខុស និងបទបញ្ជាផ្ទៃក្នុងនៃសវនាការ នោះប្រធានក្រុមប្រឹក្សាជំនុំជំរះ មានសិទ្ធិព្រមាន ឬបង្គាប់ឱ្យអ្នករក្សាសណ្តាប់ធ្នាប់បង្ខំអោយជននោះ ចេញមួយរយៈ ឬរហូតពីបន្ទប់ជំនុំជំរះជាបន្ទាន់ ។

ប្រសិនបើមានបទល្មើសព្រហ្មទណ្ឌណាមួយ កើតមានក្នុងបរិវេណនៃបន្ទប់ជំនុំជំរះ ហើយក្នុងអំឡុងពេលជំនុំជំរះ ប្រធានក្រុមប្រឹក្សាជំនុំជំរះ ត្រូវបញ្ជាឱ្យលេខាធិការ-ក្រឡាបញ្ជីធ្វើកំណត់ហេតុបញ្ជូនជនល្មើស និងវត្ថុតាងទៅអយ្យការដើម្បីចាត់វិធានការ ស៊ើបអង្កេត និងចោទប្រកាន់តាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

ក្នុងករណីត្រូវរក្សាការសម្ងាត់របស់រដ្ឋ ឬសីលធម៌សង្គម ការជំនុំជំរះអាចធ្វើជាសម្ងាត់បាន តែសាលក្រមត្រូវប្រកាសជាសាធារណៈ ។ តុលាការត្រូវប្រកាសជាជំនុំជំរះជាសម្ងាត់ដោយសេចក្តីសំរេចមានមូលហេតុ ។

ទោះបីការជំនុំជំរះ ត្រូវធ្វើជាសាធារណៈក៏ដោយក៏មិនត្រូវអនុញ្ញាត្តិអោយអនីតិជន គឺជនអាយុតិចជាង ១៨ឆ្នាំ ចូលរួមស្តាប់ក្នុងសវនាការទេ លើកលែងតែអនីតិជននេះត្រូវតុលាការកោះមកសួរជាសាក្សី ។

សវនាការរបស់តុលាការប្រជាជន ត្រូវប្រព្រឹត្តទៅដូចខាងក្រោមនេះ :

**១-មុនពេលបើកសវនាការ :**

លេខាធិការ-ក្រឡាបញ្ជី មានភារកិច្ច :

ក-អានបទបញ្ជាផ្ទៃក្នុងនៃបន្ទប់ជំនុំជំរះ

ខ-ពិនិត្យវត្តមាននៃអ្នកចូលរួមក្នុងសវនាការទាំងអស់ ។ ក្នុងករណីអវត្តមាននៃសាមីជនណាម្នាក់នោះត្រូវពិនិត្យរកមូលហេតុ ។

**២.ពេលបើកសវនាការ :**

-លេខាធិការ-ក្រឡាបញ្ជី អញ្ជើញអ្នកចូលរួមក្នុងនីតិវិធីទាំងអស់ មកកាន់បន្ទប់សវនាការ

-ស្នូកណ្តឹង ៣ដង ជាសញ្ញាប្រាប់អំពីការចូលបន្ទប់សវនាការនៃក្រុមប្រឹក្សាជំនុំជំរះ

-លេខាធិការ-ក្រឡាបញ្ជី អញ្ជើញសាធារណៈជនក្រោកឈរ

-ក្រុមប្រឹក្សាជំនុំជំរះ ចូលមកកាន់កន្លែង ។ ប្រធានអញ្ជើញសាធារណជនអង្គុយរួចក្រុមប្រឹក្សាជំនុំជំរះក៏អង្គុយ

ភ្លាមដែរ ។

-ប្រធានក្រោកឈរប្រកាសបើកការជំនុំជំរះ និងប្រកាសកម្មវត្ថុនៃរឿងហេតុព្រមទាំងឈ្មោះនៃគូភាគី ។

-ប្រធានបង្គាប់ឱ្យលេខាធិការ-ក្រឡាបញ្ជី រាយការណ៍ពីវត្តមាន និងអវត្តមាននៃអ្នកដែលត្រូវចូលរួមក្នុងនីតិវិធី ។

-លេខាធិការ-ក្រឡាបញ្ជី ក្រោកឈរ ហើយរាយការណ៍ ។ បើមានអ្នកចូលរួមណាមួយអវត្តមាន ឬបើមានសំណូមពរពីគូភាគីណាស្នើផ្អាកសវនាការក្រុមប្រឹក្សាជំនុំជំរះ ត្រូវពិភាក្សា និងសំរេចថា តើគួរបន្តសវនាការ ឬបង្អង់ទៅថ្ងៃក្រោយ ។

-ប្រធានក្រោកឈរប្រកាសសមាសភាពតុលាការ ហើយសួរអត្តសញ្ញាណ គឺនាមត្រកូល និងឈ្មោះ អាយុ សញ្ជាតិ លំនៅដ្ឋានបច្ចុប្បន្ន របររកស៊ី ឈ្មោះ ប្តីប្រពន្ធ រួចប្រាប់សិទ្ធិ និងកាតព្វកិច្ចដល់គូភាគី ។ បន្ទាប់មកប្រធាន សួរដល់ភាគីម្នាក់ៗ តើសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាជំនុំជំរះរូបណាមួយទេ ។ ប្រសិនបើមានក្រុមប្រឹក្សាជំនុំជំរះទាំងមូលជាអ្នកពិនិត្យ និងសំរេចតាមមតិភាគច្រើន ក្រោយពីបានយោបល់ពីតំណាងអយ្យការ ក្នុងករណីដែលរដ្ឋអាជ្ញាតាំងខ្លួនជាគូក្តីដើម ។ ការប្តឹងសុំផ្លាស់ប្តូរ និងទុកជាបានការ លុះត្រាតែបណ្តឹងនោះមានមូលហេតុត្រឹមត្រូវ ។

-ប្រធាន ប្រាប់ដល់អ្នកចូលរួមឯទៀត ដូចជាសាក្សី អ្នកជំនាញដែលបានធ្វើកោសល្យវិច័យ អ្នកបកប្រែ អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន ។

**៣.ការសួរដេញដោល**

ក្នុងដំណាក់កាលសួរដេញដោល ប្រធានក្រុមប្រឹក្សាជំនុំជំរះ សួរដេញដោលដើមចោទមុន បន្ទាប់មកចុងចម្លើយ និង អ្នកចូលរួមឯទៀត ។

-ក្នុងពេលប្រធានសួររួច ប្រធានត្រូវប្រគល់សំដី អោយទីប្រឹក្សាសួរបន្ថែម

-បន្ទាប់ពីទីប្រឹក្សាប្រជាជន តំណាងអយ្យការ អ្នកការពារ មានសិទ្ធិតាំងសំណួរបានប្រសិនបើមាន ។

-បើក្នុងសំណុំរឿងមានបណ្តឹងរបស់តំណាងអយ្យការ ដែលតាំងខ្លួនជាគូក្តីដើម ប្រធានសវនាការត្រូវអធិប្បាយដោយសង្ខេបនូវខ្លឹមសារនៃបណ្តឹងរបស់តំណាងអយ្យការ ។ បន្ទាបមក់ប្រធានក្រុមប្រឹក្សាជំនុំជំរះត្រូវបង្គាប់អោយលេខាធិការក្រឡាបញ្ជី អានទាំងស្រុងនូវបណ្តឹងរបស់តំណាងអយ្យការ ។ ប្រធានអញ្ជើញតំណាងអយ្យការ មានមតិបន្ថែម ។

ប្រធាន អាចបង្គាប់អោយលេខាធិការ-ក្រឡាបញ្ជី អានចម្លើយរបស់អ្នកវត្តមាន ដែលគេបានឆ្លើយនៅពេលអង្កេតស៊ើបសួររួចហើយ ។

គូភាគី សាក្សី ដែលជាជនជាតិមានសិទ្ធិប្រើភាសារបស់ខ្លួនបានពេលជំនុំជំរះ តែត្រូវឱ្យមានអ្នកបកប្រែភាសា ។

កំណត់សំគាល់ប្រធាន ត្រូវចេះឆក់ឱកាសក្នុងពេលសួរសាម៉ីជនបញ្ចេញវត្ថុតាង ឬឯកសារនានា ដែលទាក់ទង និងសាម៉ីជននោះ ហើយសួរបញ្ជាក់តើគេទទួលស្គាល់ឯកសារ ឬវត្ថុតាងទាំងនោះប្រាកដមែន ឬទេ ។

**៤-ការសួរតទល់គ្នា :**

-ក្នុងតំណាក់ការសួរតទល់គ្នា ប្រធានក្រុមប្រឹក្សាជំនុំជំរះ ត្រូវទុកសិទ្ធិឱ្យដើមចោទចុងចម្លើយ និងអ្នកចូលរួមឯ

ទៀត ជជែកតទល់ចំពោះចំណុចទាំងឡាយណាដែលគេពុំឯកភាពគ្នា ។ ប្រធានត្រូវធ្វើការណែនាំឱ្យសាម៉ីជននោះចេះអធិប្បាយវែកញែកហេតុផលនៃដំណើររឿង ដើម្បីការពារសិទ្ធិ និងប្រយោជន៍ស្របច្បាប់របស់គេ ហើយប្រធានត្រូវចេញកាត់សំដីណា ដែលវែងអន្លាយ ឬការជជែកគ្នាខុសខ្លឹមសារនៃរឿង ។

-ក្នុងករណីដែលតំណាងអយ្យការ តាំងខ្លួនជាគូក្តីដើម តំណាងអយ្យការអាចជជែកតទល់ជាមួយចុងចម្លើយ និងសាក្សីរបស់ចុងចម្លើយ ។

-បន្ទាប់មកប្រធាន ត្រូវអញ្ជើញអ្នកការពារសិទ្ធិដើមចោទ ធ្វើសេចក្តីសន្និដ្ឋាន រួចទើបអញ្ជើញ អ្នកការពារសិទ្ធិចុងចម្លើយ ធ្វើសេចក្តីសន្និដ្ឋានតបវិញប្រសិនបើមាន ។

-ចុងក្រោយបង្អស់ប្រធានសវនាការ អញ្ជើញតំណាងអយ្យការ សន្និដ្ឋានវាយតម្លៃ និងធ្វើសំណូមពរ ។

-ប្រធាន ប្រកាសបញ្ចប់ដំណាក់កាលសួរតទល់

-ក្រុមប្រឹក្សាជំនុំជំរះ ថយចូលក្នុងបន្ទប់ពិភាក្សាវិញ ។

**៥-ការពិភាក្សាក្នុងបន្ទប់សម្ងាត់ :**

ក្រុមប្រឹក្សាជំនុំជំរះ ត្រូវពិនិត្យនូវបញ្ហាខាងក្រោមនេះ :

ក-ទំនាក់ទំនងគតិយុត្តិ រវាងដើមចោទ និចុងចម្លើយ និងសាម៉ីជនឯទៀត

ខ-ភស្តុតាងគ្រប់គ្រាន់ហើយ ឬនៅ?

គ-សិទ្ធិ និងកាតព្វកិច្ច របស់សាម៉ីជនម្នាក់ ៗ ដែលត្រូវដោះស្រាយតាមបញ្ញត្តិច្បាប់ និងគោលនយោបាយរបស់បក្ស ។

ប្រធានមានភារកិច្ចអធិប្បាយបញ្ហានីមួយៗ និងបញ្ញត្តិច្បាប់ គោលនយោបាយរបស់បក្ស ជូនសមាជិកក្រុមប្រឹក្សាជំនុំជំរះ ត្រូវផ្តល់មតិមុន រួចទើបប្រធានក្រុមប្រឹក្សាជំនុំជំរះ សំរេចតាមមតិភាគច្រើន ។ ក្នុងករណីមានមតិមិនឯកភាពគ្នាប្រធាន ត្រូវធ្វើកំណត់ហេតុដាក់ក្នុងសំណុំរឿង រីឯអ្នកមានមតិមិនឯកភាព ក៏មានសិទ្ធិសរសេរមតិរបស់ខ្លួនដាក់ចូលក្នុងសំណុំរឿងដែរ ។

នៅពេលពិភាក្សា គ្មានជនណាម្នាក់មានសិទ្ធិចូលក្នុងបន្ទប់សម្ងាត់ ក្រៅពីក្រុមប្រឹក្សាជំនុំជំរះឡើយ ។

**៦-ការប្រកាសសាលក្រម :**

ស្នូរកណ្តឹង ៣ដង

-ក្រុមប្រឹក្សាជំនុំជំរះ ចេញពីបន្ទប់សម្ងាត់ មកកាន់បន្ទប់សវនាការវិញ ។

-ប្រធានក្រោកឈរ ដើម្បីអានសាលក្រម ។ ព្រមជាមួយនោះលេខាធិការ-ក្រឡាបញ្ជី អញ្ជើញសាធារណជនក្រោកឈរ ។

-លុះអានចប់សមាសភាពតុលាការហើយ ប្រធាន អញ្ជើញសាធារណជនអង្គុយ ។

-ក្នុងពេលតុលាការប្រកាសសេចក្តីវិនិច្ឆ័យ លេខាធិការ ក្រឡាបញ្ជី អញ្ជើញសាធារណជនក្រោកឈរ ។

-លុះប្រកាសសាលក្រមចប់ ប្រធាន អញ្ជើញសាធារណជនអង្គុយ ។ ប្រធានក៏អង្គុយដែរ ។

-ប្រធាន ប្រាប់ទៅគូភាគី បើមិនសុខចិត្ត និងសាលក្រមនេះទេ អាចធ្វើពាក្យបណ្តឹងទៅក្រសួងយុត្តិធម៌បាន ។

-ប្រធានក្រោកឈរ ប្រកាសបិទសវនាការ ។

V.ក្រោយពេលសវនាការ :

-ប្រធានសវនាការ ត្រូវពិនិត្យឡើងវិញ នូវកំណត់ហេតុក្នុងសៀវភៅសវនាការ ។ កំណត់ហេតុសវនាការ ឆ្លុះបញ្ចាំង និងបញ្ជាក់សព្វគ្រប់ អំពីការដែលកើតមានក្នុងពេលសវនាការ ។

កំណត់ហេតុសវនាការ ត្រូវមានហត្ថលេខា របស់លេខាធិការ-ក្រឡាបញ្ជីកត់ត្រា និងក្រុមប្រឹក្សាជំនុំជំរះ ។

-លេខាធិការ-ក្រឡាបញ្ជី ត្រូវចម្លងកំណត់ហេតុសវនាការ រួចយកមកទុកក្នុងសំណុំរឿង ។

-ក្រោយពេលសវនាការ ចៅក្រម ត្រូវចាត់ឱ្យលេខាធិការ-ក្រឡាបញ្ជីចម្លងសាលក្រម ជូនតំណាងអយ្យការ និងក្រសួងយុត្តិធម៌ជាបន្ទាន់ ព្រមទាំងធ្វើសំរង់សាលក្រម ឬចម្លងសាលក្រមជូនភាគី និងអង្គការមានសមត្ថកិច្ចដើម្បីអនុវត្ត ។

-ការអនុវត្តន៍សាលក្រម ត្រូវប្រព្រឹត្តទៅតាមសារាចរ លេខ ១០២៦ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៨២ របស់ក្រសួងយុត្តិធម៌ ដែលបានផ្ញើជូនដល់អយ្យការ និងតុលាការប្រជាជនខេត្ត ក្រុងរួចហើយ ។

## កំណត់សំគាល់

### I.ការប្តឹងជំទាស់ និងការជំនុំជំរះសារឡើងវិញ

#### ១.ការប្តឹងជំទាស់

សាលក្រមរដ្ឋប្បវេណី របស់តុលាការប្រជាជនខេត្ត ក្រុងដែលសំរេចចំពោះមុខមានអនុភាពអនុវត្តភ្លាមៗ ។ សាលក្រមកំបាំងមុខ គ្មានអនុភាពអនុវត្តចំពោះមុខភាគីអវត្តមានបានទេ ។ ភាគីអវត្តមានអាចប្តឹងជំទាស់ និងសាលក្រមនេះ បានក្នុងរយៈពេល ១៥ថ្ងៃ គិតពីថ្ងៃដែលបានអោយដំណឹងពីសាលក្រមនោះដល់សាមីខ្លួនផ្ទាល់ ឬដល់ទីលំនៅរបស់សាមីខ្លួន ។

បើផុតរយៈពេលនេះ ភាគីអវត្តមាន ដែលបានទទួលដីកាឱ្យដំណឹងហើយ តែមិនប្តឹងជំទាស់ នោះសាលក្រមកំបាំងមុខ និងទៅជាសាលក្រមស្ថាពរ ។

បើភាគីអវត្តមាន ប្តឹងជំទាស់ក្នុងរយៈពេលកំណត់ នោះប្រធានតុលាការត្រូវកោះហៅអ្នកប្តឹងជំទាស់ព្រមទាំងភាគីដទៃទៀត ឱ្យចូលខ្លួនមកនៅពេលជំនុំជំរះ ដែលនឹងកំណត់ធ្វើនៅថ្ងៃណាមួយខាងមុខ ។

បើអ្នកប្តឹងទាស់មិនព្រមចូលខ្លួនមកទៀត ក្រោយពីបានទទួលដីកាកោះត្រឹមត្រូវហើយ នោះការប្តឹងជំទាស់របស់សាមីខ្លួន ត្រូវទុកជាអសារឥតការ ។ ក្នុងករណីនេះ សាលក្រមកំបាំងមុខ ត្រូវទៅជាសាលក្រមស្ថាពរហើយត្រូវយកទៅអនុវត្ត ។

#### ២ការជំនុំជំរះសារឡើងវិញ

បើរដ្ឋអាជ្ញាយល់ឃើញថា សាលក្រមរដ្ឋប្បវេណីរបស់តុលាការប្រជាជនខេត្ត ក្រុងសំរេចដោយមានការភាន់ច្រ

ឡើ រដ្ឋអាជ្ញា ត្រូវរាយការណ៍ជូនរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ ដើម្បីពិនិត្យ និងសំរេច ។

ក្នុងនីតិវិធីជំនុំជំរះសារឡើងវិញ ក្រុមប្រឹក្សាជំនុំជំរះ ត្រូវមានចៅក្រម ២នាក់ ដែលម្នាក់ជាប្រធាន និងទីប្រឹក្សាប្រជាជន ៣នាក់ ហើយសុទ្ធតែអ្នកដែលមិនបានចូលរួមក្នុងការជំនុំជំរះលើកមុន ។

សាលក្រមរបស់តុលាការប្រជាជនខេត្ត ក្រុង ដែលជំនុំជំរះសារឡើងវិញ ទោះបីសំរេច កំបាំងមុខក៏ដោយ ក៏មិនអាចឱ្យមានការប្តឹងជំទាស់ ឬតវ៉ាទៀតឡើយ ។

## II.ឧប្បត្តិហេតុក្នុងអំឡុងនីតិវិធី

### ១.វិធានការបណ្តោះអាសន្ន

ចាប់តាំងពីពេលទទួលពាក្យបណ្តឹង រហូតដល់ពេលជំនុំជំរះ ចៅក្រមមានសិទ្ធិចេញដីកាសំរេចជាការប្រញាប់ តាមសំណូមពររបស់ភាគី ប្រសិនបើយល់ឃើញថាចាំបាច់ ។ ដីកាសំរេចនេះមានគោលដៅបង្កាការអន្តរាយផ្សេងៗ ដែលអាចកើតមានជាយថាហេតុ ដូចជាដីកាសំរេចឱ្យប្តី និងប្រពន្ធ ដែលសុំលះលែងគ្នា បែកលំនៅពីគ្នាជាបណ្តោះអាសន្ន ដីកាសំរេចឱ្យភាគីម្ខាងចិញ្ចឹមអាហារកិច្ចកូនជាបណ្តោះអាសន្ន ។ ដីកាសំរេចឱ្យកត់ទ្រព្យសម្បត្តិ និងប្រគល់សិទ្ធិដល់ជនណាម្នាក់ឱ្យថែរក្សាជាបណ្តោះអាសន្ន នូវទ្រព្យសម្បត្តិដែលមានទំនាស់ ឬទ្រព្យសម្បត្តិសំរាប់ការពារផលប្រយោជន៍របស់គូភាគី ។

ចៅក្រម ចេញដីកាសំរេចជាការប្រញាប់បាន ចំពោះតែកិច្ចការជាបណ្តោះអាសន្ន ដែលមិនបានប៉ះពាល់ទៅដល់អង្គសេចក្តី ។ ដីកាសំរេចនេះ មិនអាចប្តឹងជំទាស់បានឡើយ ។

### ២.ការបញ្ចូលតតិយជនមកជាគូក្តី

នៅពេលធ្វើការសួរដេញដោល បើមានតតិយជនណាជាប់ទាក់ទងក្នុងរឿងដែលតុលាការកំពុងជំនុំជំរះ នោះតុលាការអាចបញ្ចូលឈ្មោះតតិយជននោះ មកជាគូក្តីខាងដើមចោទ ឬខាងចុងចំលើយ យោលទៅតាមផលប្រយោជន៍របស់ភាគីនីមួយៗ ។

### ៣.ការធ្វើបន្តធ្វើឡើងវិញនូវការជំនុំជំរះ

នៅពេលធ្វើការជំនុំជំរះ ប្រសិនបើដើមចោទទទួលអនិច្ចកម្ម នោះតុលាការត្រូវស្រាវជ្រាវរកដោយគ្រប់មធ្យោបាយនូវទាយាទទាំងឡាយនៃសព ។ ទាយាទទាំងឡាយនោះត្រូវកោះហៅមកចំពោះមុខតុលាការ ហើយតុលាការត្រូវសួរឱ្យដឹងថា ទាយាទទាំងនោះមានបំណងបន្តក្តីទៅទៀត ឬក៏បោះបង់ត្រឹមនេះ ។

ក្នុងករណីទី១ វិនាទកម្មត្រូវធ្វើឡើងវិញ ក្នុងនាមទាយាទទាំងនោះ តុលាការត្រូវបញ្ចូលឈ្មោះទាយាទទាំងនោះ មកជាគូក្តីខាងដើមចោទ ។

ក្នុងករណីទី២ វិនាទកម្មត្រូវតែរំលាយចោល ហើយប្រដាប់ប្តឹងទាំងឡាយ ដែលបង់រួចហើយ ត្រូវទុកឱ្យអ្នកទទួលមតិក របស់ដើមចោទ ។

នៅពេលជំនុំជំរះ ប្រសិនបើចុងចម្លើយបានទទួលអនិច្ចកម្ម ហើយដើមចោទ ប្តឹងសុំឱ្យទាយាទរបស់ចុងចំលើយ ជួសជួលសំណងនោះ តុលាការត្រូវស្រាវជ្រាវរកដោយគ្រប់មធ្យោបាយនូវទាយាទទាំងនោះ រួចបញ្ចូលឈ្មោះទាយាទទាំងនោះ មកជាគូក្តីខាងចុងចំលើយដើម្បីតក្តី ។

**៤.ការតំកល់រឿងទុកមិនចាត់ការ**

ចៅក្រម អាចតំកល់រឿងទុកមិនចាត់ការ ក្នុងករណីដូចខាងក្រោម :

ក. មានប្តឹងគ្នាម្តងរួចមកហើយ តុលាការបានសំរេចម្តងរួចមកហើយស្រាប់តែមានប្តឹងទៀតនូវរឿងដដែល

ខ. នៅមុនពេលជំនុំជំរះ ដើមចោទសុខចិត្តដកពាក្យបណ្តឹងរបស់ខ្លួន ហើយបណ្តឹងនេះសោតក៏គ្មានប៉ះពាល់ដល់ប្រយោជន៍ដល់អង្គការរដ្ឋ ឬអង្គការមហាជនណាមួយឡើយ ។

អ្នកចំណាយក្តី អាចឈប់ប្តឹងជំនួសកូនក្តីបាន លុះត្រាតែមានសំបុត្រប្រគល់សិទ្ធិជាពិសេសពីកូនក្តីរបស់ខ្លួនដែលអនុញ្ញាត្តិឱ្យឈប់ប្តឹង ។

**៥.ការបង្អង់រឿងទុកមួយអន្លើ ការបង្អង់ការជំនុំជំរះ**

តុលាការអាចបង្អង់ទុកមួយអន្លើ នូវរឿងដូចខាងក្រោម :

ក. នៅពេលជំនុំជំរះ ស្រាប់តែភាគីណាមួយមានជំងឺវិកលចរិក ។ ក្នុងករណីនេះត្រូវរងចាំឱ្យភាគីនេះជាស្រលះសិនសឹមជំនុំជំរះ ។

ខ. ដើមចោទអវត្តមានយូរ ហើយមិនបានប្រគល់សិទ្ធិអោយជនណាម្នាក់ប្តឹងជំនួសខ្លួន ឬពុំដឹងអាស័យដ្ឋានពិតប្រាកដរបស់ជននោះ ។

ករណីនេះតុលាការអាចនឹងជំនុំជំរះបាន លុះត្រាតែដើមចោទនោះត្រឡប់មកវិញ ។

គ.នៅពេលជំនុំជំរះ បើឃើញថាក្នុងរឿងរដ្ឋប្បវេណីនេះ មានភាគីណាមួយប្តឹងបទព្រហ្មទណ្ឌនៅមន្ទីរអយ្យការ ហើយអយ្យការក៏បានចោទប្រកាន់រួចហើយដែរនោះ តុលាការត្រូវបង្អង់ការជំនុំជំរះសិន ។

តុលាការរដ្ឋប្បវេណី អាចជំនុំជំរះទៅទៀតបាន លុះត្រាតែតុលាការព្រហ្មទណ្ឌបានសំរេចសេចក្តីអំពីបណ្តឹងរបស់គូភាគីនោះរួចស្រេចជាស្ថាពរ ។

ក្រសួងយុត្តិធមិសង្ឃឹមថា សេចក្តីណែនាំខាងលើនេះ អាចជួយដល់សមមិត្តប្រធាន អនុប្រធានចៅក្រម និងរដ្ឋអាជ្ញា នៅគ្រប់តុលាការប្រជាជនខេត្ត ក្រុង ក្នុងការអនុវត្តភារកិច្ចរៀងៗខ្លួន ។ ក្នុងករណីជួបការលំបាកសូមសមមិត្តលើកជាមតិស្នើឡើងក្រសួងយុត្តិធមិ ក្រសួងយុត្តិធមិ នឹងធ្វើការណែនាំបន្ថែមតាមសំណូមពរ ។

ហត្ថលេខា និងត្រា

**អ៊ុក ប៊ុនឈឿន**